## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# គោលការណ៍ណែនាំ
## ស្តីពី
## នីតិវិធីនិងវិធាននៃការតាក់តែង
## សេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត

**បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ**
**នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាន នៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤

## សម្រេច

**មាត្រា១ .-**

ត្រូវបានដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដូចមានខ្លឹមសារជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រប់ក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាល។

**មាត្រា៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៣ រោច ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# គោលការណ៍ណែនាំ

# ស្តីពី

# នីតិវិធីនិងវិធាននៃការតាក់តែង

# សេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត

**បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ**

**នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤**

# មាតិកា


| | ទំព័រ |
|---|---|
| **អារម្ភកថា** | |
| **សេចក្តីផ្តើម** | |
| **ក- គោលការណ៍ទូទៅ** | ១ |
| **ខ- គោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត** | ១ |
| **១- ដំណើរការនៃការរៀបចំសេចក្តីព្រាងដើមនៃសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត** | ១ |
| ១.១- សេចក្តីព្រាងដើមដំណាក់កាលទី១ | ១ |
| ១.២- សេចក្តីព្រាងដើមដំណាក់កាលទី២ | ១ |
| **២- ការរៀបចំសេចក្តីថ្លែងហេតុឬកំណត់មូលហេតុសង្ខេប** | ២ |
| ២.១- សេចក្តីថ្លែងហេតុ | ២ |
| ២.២- កំណត់មូលហេតុសង្ខេប | ៣ |
| **៣- វិធាននៃការតែងសេចក្តីនិងទម្រង់នៃសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត** | ៤ |
| ៣.១- វិធាននៃការតែងសេចក្តី | ៤ |
| ៣.១.១- ក្បាលលិខិត | ៤ |
| ៣.១.២- មូលបទ | ៤ |
| ៣.១.៣- ខ្លឹមសារនៃអត្ថបទ | ៤ |
| ៣.២- ទម្រង់ | ៦ |
| ៣.២.១- ទម្រង់នៃសេចក្តីព្រាងច្បាប់ | ៦ |
| ៣.២.២- ទម្រង់នៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ | ២១ |
| ៣.២.៣- ទម្រង់នៃអនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្តីស្នើច្បាប់ | ៣០ |
| ៣.២.៤- ទម្រង់នៃព្រះរាជក្រម | ៣៥ |
| ៣.២.៥- ទម្រង់នៃព្រះរាជក្រឹត្យ | ៤៦ |
| ៣.២.៦- ទម្រង់នៃព្រះរាជក្រឹត្យស្តីពីការកែសម្រួលព្រះរាជក្រឹត្យ | ៩៤ |
| ៣.២.៧- ទម្រង់នៃអនុក្រឹត្យ អនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យ សេចក្តីសម្រេច សេចក្តីសម្រេចស្តីពីការកែសម្រួលសេចក្តីសម្រេច បទបញ្ជា និងសារាចររបស់រាជរដ្ឋាភិបាល | ១០៤ |
| ៣.២.៧.១- ទម្រង់នៃអនុក្រឹត្យ | ១០៤ |
| ៣.២.៧.២- ទម្រង់នៃអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យ | ១៣៤ |
| ៣.២.៧.៣- ទម្រង់នៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល | ១៤២ |
| ៣.២.៧.៤- ទម្រង់នៃសេចក្តីសម្រេចស្តីពីការកែសម្រួលសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល | ១៥៣ |
| ៣.២.៧.៥- ទម្រង់នៃបទបញ្ជារបស់រាជរដ្ឋាភិបាល | ១៥៧ |
| ៣.២.៧.៦- ទម្រង់នៃសារាចររបស់រាជរដ្ឋាភិបាល | ១៥៩ |
| ៣.២.៨- ទម្រង់នៃប្រកាស ប្រកាសអន្តរក្រសួង ប្រកាសរួម សេចក្តីសម្រេច សារាចរ និងសារាចរអន្តរក្រសួងរបស់ក្រសួង ស្ថាប័ន | ១៦១ |
| ៣.២.៨.១- ទម្រង់នៃប្រកាស | ១៦១ |
| ៣.២.៨.២- ទម្រង់នៃប្រកាសអន្តរក្រសួង | ១៧៣ |

៣.២.៨.៣- ទម្រង់នៃប្រកាសរួម ១៧៤
៣.២.៨.៤- ទម្រង់នៃសេចក្តីសម្រេចរបស់ក្រសួង ស្ថាប័ន ១៧៩
៣.២.៨.៥- ទម្រង់នៃសារាចររបស់ក្រសួង ស្ថាប័ន ១៨២
៣.២.៨.៦- ទម្រង់នៃសារាចរអន្តរក្រសួង ១៨៤
**៤- ការបញ្ជូនសំណុំឯកសារទៅទីស្តីការគណៈរដ្ឋមន្ត្រី** ១៨៦
៤.១- សេចក្តីស្នើច្បាប់ដែលស្នើសុំឱ្យរាជរដ្ឋាភិបាលផ្តល់អនុសាសន៍ ១៨៦
៤.២- សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ ១៨៦
៤.៣- សេចក្តីស្នើច្បាប់ឬសេចក្តីព្រាងច្បាប់ដែលទាក់ទងនឹងវិស័យតុលាការ ១៨៦
**៥- ការពិនិត្យសំណុំឯកសារនៅទីស្តីការគណៈរដ្ឋមន្ត្រី** ១៨៦
៥.១- ការពិនិត្យដោយអង្គប្រជុំជំនាញបច្ចេកទេស ១៨៦
៥.២- ការពិនិត្យដោយអង្គប្រជុំអន្តរក្រសួង ១៨៧
៥.៣- ការពិនិត្យដោយអង្គប្រជុំត្រួតពិនិត្យចុងក្រោយ ១៨៧
៥.៤- ការពិនិត្យដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ១៨៧
៥.៥- ការពិនិត្យនិងការផ្តល់អនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្តីស្នើច្បាប់ ១៨៧
**៦- ការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតក្រោយការប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងការចុះហត្ថលេខាអម** ១៨៧
៦.១- សេចក្តីព្រាងច្បាប់ ១៨៧
៦.២- ព្រះរាជក្រឹត្យ ១៨៨
៦.២.១- ព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ ១៨៨
៦.២.២- ព្រះរាជក្រឹត្យមានលក្ខណៈជាឯកត្តភូត ដែលនាយករដ្ឋមន្ត្រីប្រើធន្ទានុសិទ្ធិស្នើឡើង ១៨៨
៦.២.៣- ព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោសនិង/ឬការលើកលែងទោស ១៨៨
៦.២.៤- ព្រះរាជក្រឹត្យស្តីពីការតែងតាំង/ផ្លាស់ប្តូរ/... ចៅក្រមនិងព្រះរាជអាជ្ញា ១៨៨
៦.២.៥- ព្រះរាជក្រឹត្យស្តីពីការផ្តល់គ្រឿងឥស្សរិយយស ១៨៨
៦.៣- អនុក្រឹត្យ ១៨៨
៦.៣.១- អនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ ១៨៨
៦.៣.២- អនុក្រឹត្យមានលក្ខណៈជាឯកត្តភូត ១៨៩
**៧- ការបញ្ជូនសំណុំឯកសារទៅរដ្ឋសភា** ១៨៩
**៨- ការប្រគល់ភារកិច្ចឱ្យទៅការពារសេចក្តីព្រាងច្បាប់នៅរដ្ឋសភានិងព្រឹទ្ធសភា** ១៨៩
**៩- នីតិវិធីនិងវិធាននៃការសុំធ្វើវិសោធនកម្មច្បាប់និងសេចក្តីព្រាងច្បាប់** ១៨៩
៩.១- ការធ្វើវិសោធនកម្មច្បាប់ជាធរមាន ១៨៩
៩.២- ការធ្វើវិសោធនកម្មសេចក្តីព្រាងច្បាប់ដែលគណៈរដ្ឋមន្ត្រីបានឯកភាព ហើយដែលស្ថិតនៅក្នុងរបៀបវារៈរបស់អង្គប្រជុំរដ្ឋសភា ១៨៩
៩.៣- ការធ្វើវិសោធនកម្មសេចក្តីព្រាងច្បាប់ដែលគណៈរដ្ឋមន្ត្រីបានឯកភាព ហើយដែលស្ថិតនៅក្នុងគណៈកម្មការនៃរដ្ឋសភា ១៩០
**១០- ការចូលជាធរមាននៃច្បាប់ក្រោយពីការអនុម័តនិងការយល់ព្រមរបស់ស្ថាប័ននីតិប្បញ្ញត្តិ និងការចុះរាជកិច្ច** ១៩០

# អារម្ភកថា

គោលការណ៍ណែនាំស្ដីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្ដីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ត្រូវបានដាក់ឱ្យអនុវត្តដោយសារាចរបស់រាជរដ្ឋាភិបាលលេខ០៣ សរ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ ក្នុងគោលបំណងដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងបង្កលក្ខណៈងាយស្រួលក្នុងការរៀបចំ ព្រមទាំងធានាឱ្យបាននូវការឯកភាពនិងសង្គតិភាព លើទម្រង់និងខ្លឹមសារក្នុងការតាក់តែងសេចក្ដីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

ចាប់តាំងពីឆ្នាំ២០១៣ រហូតមកដល់បច្ចុប្បន្ននេះ សេចក្ដីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដែលបណ្ដាក្រសួង ស្ថាប័ន បានស្នើសុំការយល់ព្រមនិងបញ្ជូនទៅសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ ឬស្នើសុំព្រះរាជក្រឹត្យពីព្រះមហាក្សត្រ ឬការសម្រេចពីនាយករដ្ឋមន្ត្រី ដោយដាក់ឆ្លងយន្តការទីស្ដីការគណៈរដ្ឋមន្ត្រីកន្លងមក តាមរយៈកិច្ចប្រជុំជំនាញបច្ចេកទេស កិច្ចប្រជុំអន្តរក្រសួង កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ និងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដូចមានកំណត់ក្នុងសារាចររបស់រាជរដ្ឋាភិបាលលេខ០៣ សរ ឆ្នាំ២០១៣ ជាលទ្ធផលបានឆ្លុះបញ្ចាំងឱ្យឃើញថាការតាក់តែងសេចក្ដីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តមានសង្គតិភាពទាំងទម្រង់និងខ្លឹមសារ។

គោលការណ៍ណែនាំស្ដីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្ដីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលបានអនុវត្តអស់រយៈពេលជាង១០ឆ្នាំកន្លងមកនេះ ត្រូវបានគិតគូរក្នុងការរៀបចំនិងកែសម្រួលឡើងវិញ ពីព្រោះនៅមានចំណុចខ្វះខាតមួយចំនួនលើទិដ្ឋភាពទម្រង់នៃការតាក់តែង និងមានបញ្ញត្តិខ្លះលែងមានសុពលភាពអនុវត្តតាមវឌ្ឍនភាពសង្គម ហើយតម្រូវឱ្យមានការរៀបចំបញ្ញត្តិមួយចំនួននិងគំរូទម្រង់នៃការតាក់តែងមួយចំនួនទៀត ដើម្បីបំពេញការខ្វះខាត ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងថែមទៀតលើការតាក់តែងសេចក្ដីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ឆ្លើយតបទៅនឹងស្ថានភាពវិវត្តនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។

គោលការណ៍ណែនាំនេះ ត្រូវបានរៀបចំឡើងដោយឈរលើទស្សនវិជ្ជានីតិរដ្ឋ (Rule of Law) ដែលរដ្ឋនីមួយៗត្រូវតែមានក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់និងគ្រប់ជ្រុងជ្រោយ ដែលធានាបាននូវសិទ្ធិ សេរីភាព កម្មសិទ្ធិឯកជននិងសាធារណៈ ការពារបាននូវតម្លៃនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស សមភាពនៅចំពោះមុខច្បាប់ ធ្វើឱ្យការគ្រប់គ្រងវិស័យសេដ្ឋកិច្ច សង្គមកិច្ច ឧស្សាហកម្ម ពាណិជ្ជកម្ម កសិកម្ម និងទេសចរណ៍ ប្រព្រឹត្តទៅដោយរលូននិងមានប្រសិទ្ធភាព។ លើសពីនេះទៅទៀត រដ្ឋនីមួយៗត្រូវរៀបចំឱ្យមានប្រព័ន្ធនៃការតាមដាននិងត្រួតពិនិត្យការអនុវត្តច្បាប់ឱ្យបានហ្មត់ចត់ ដើម្បីធានាឱ្យមានយុត្តិធម៌ក្នុងសង្គម។ ក្នុងន័យនេះ ការរៀបចំតាក់តែងសេចក្ដីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលបម្រើឱ្យនីតិរដ្ឋ ត្រូវឈរលើគោលការណ៍ណែនាំមួយដែលក្រសួង ស្ថាប័ន ទាំងអស់នៃរាជរដ្ឋាភិបាលយកទៅអនុវត្ត ដើម្បីធានាថា ច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងនោះមានគុណភាព សង្គតិភាព អនុលោមភាព សាមញ្ញភាព ចីរភាព សន្តិសុខគតិយុត្ត និងប្រសិទ្ធភាព។

នៅឆ្នាំ២០១៩ ទីស្ដីការគណៈរដ្ឋមន្ត្រីដែលជាសេនាធិការជូនរាជរដ្ឋាភិបាលបានផ្ដួចផ្ដើមឱ្យមានការគិតគូរពីការធ្វើបច្ចុប្បន្នកម្មលើគោលការណ៍ណែនាំស្ដីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្ដីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតនេះ និងបានបង្កើតក្រុមការងារជំនាញដោយមានសមាសភាពចូលរួមពីក្រុមប្រឹក្សាអ្នកច្បាប់ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ អគ្គនាយកដ្ឋានទាំង៨ចំណុះឱ្យទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី ព្រមទាំងគណៈកម្មការភាសាវិទ្យាខ្មែរ។ តាមរយៈក្រុមការងារជំនាញបានធ្វើការពិនិត្យនិងកែសម្រួលចំនួន២៥លើក និងបានធ្វើការកែសម្រួលគោលការណ៍ណែនាំ

ស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត រហូតសម្រេចបានជាសេចក្តីព្រាងគោលការណ៍ណែនាំកែសម្រួលថ្មីមួយ។ ប៉ុន្តែ កិច្ចការងារនេះត្រូវបានក្រុមការងារសម្រេចផ្អាកនិងពន្យារពេលបន្តិច ដោយសារវិបត្តិនៃជំងឺកូវីដ-១៩ អស់រយៈពេលជាង៣ឆ្នាំ។

នាដើមរាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ទីស្តីការគណៈរដ្ឋមន្ត្រីបានបន្តយកសេចក្តីព្រាងគោលការណ៍ណែនាំដែលកែសម្រួលដោយក្រុមការងារជំនាញ មកធ្វើការពិនិត្យនិងកែសម្រួលបន្ថែមទៀតចំនួន២៦លើក តាមរយៈកិច្ចប្រជុំផ្ទៃក្នុងក្រុមប្រឹក្សាអ្នកច្បាប់ចំនួន៧លើក កិច្ចប្រជុំជំនាញបច្ចេកទេសចំនួន៥លើក និងបន្តពិនិត្យបន្ទាប់ពីកិច្ចប្រជុំជំនាញបច្ចេកទេសដោយក្រុមការងារចង្អៀតរបស់ក្រុមប្រឹក្សាអ្នកច្បាប់ចំនួន៦លើក កិច្ចប្រជុំអន្តរក្រសួងចំនួន២លើក កិច្ចប្រជុំអន្តរក្រសួងចង្អៀតចំនួន១លើក កិច្ចប្រជុំចង្អៀតក្រុមប្រឹក្សាអ្នកច្បាប់ចំនួន៣លើក និងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយចំនួន២លើក និងបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤។

គោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ត្រូវបានរៀបចំឡើងដោយផ្អែកលើតម្រូវការនៃការអភិវឌ្ឍសង្គមនិងគោលនយោបាយកំណែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ក្រោមយុទ្ធសាស្ត្រស្តីពីការធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់ ដើម្បីលើកកម្ពស់គុណភាពប្រសិទ្ធភាពការងារស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ មុំទី៤ «ការលើកកម្ពស់និងការពង្រឹងប្រសិទ្ធភាពនៃច្បាប់និងប្រព័ន្ធយុត្តិធម៌» និងធានាបាននូវឯកភាពក្នុងការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

ខ្ញុំជឿជាក់ថា គោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលប្រមូលផ្តុំនូវគោលការណ៍និងគំរូទម្រង់សំខាន់ៗឈានទៅរកឯកភាពលើនីតិវិធីនិងវិធានក្នុងការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតនឹងក្លាយជាមគ្គុទ្ទេសក៍ដ៏សំខាន់សម្រាប់ក្រសួង ស្ថាប័នទាំងអស់ ក្នុងការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងនោះ ដើម្បីធានាបាននូវឯកភាពផ្នែករដ្ឋបាលដែលជាកត្តាមួយយ៉ាងសំខាន់នៃឯកភាពជាតិ។

ថ្ងៃ អង្គារ ៣រោច ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ កក្កដា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និងជាប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់**

**វង្សី វិស្សុត**

# សេចក្តីផ្តើម

គោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ត្រូវបានរៀបចំនិងតាក់តែងក្នុងគោលបំណងលើកកម្ពស់គុណភាពនិងប្រសិទ្ធភាព បង្កលក្ខណៈងាយស្រួល និងធានាឱ្យមានឯកភាពក្នុងការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតនៅព្រះរាជាណាចក្រកម្ពុជា។

គោលការណ៍ណែនាំនេះត្រូវបានបែងចែកជាផ្នែកទៅតាមខ្លឹមសារសំខាន់ៗដែលមានសេចក្តីណែនាំលម្អិតក្នុងការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដើម្បីជៀសវាងភាពមិនស៊ីចង្វាក់គ្នាដែលមានកន្លងមក។

ខ្លឹមសារបឋមឆ្លុះបញ្ចាំងនូវដំណាក់កាលនីមួយៗនៃការផ្តួចផ្តើមគំនិតជាសារវន្តរបស់ក្រសួង ស្ថាប័ន ដែលរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដោយមានការចូលរួមពីសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន ស្របតាមសភាពការណ៍ជាក់ស្តែងនៃសេដ្ឋកិច្ច សង្គម និងវប្បធម៌ ព្រមទាំងសេចក្តីថ្លែងហេតុនិងកំណត់មូលហេតុសង្ខេបដែលជាឯកសារអម។

ខ្លឹមសារបន្ទាប់ដែលជាផ្នែកសំខាន់និងជាកម្មវត្ថុចម្បងនៃការដាក់ចេញនូវគោលការណ៍ណែនាំនេះ អត្ថាធិប្បាយពីវិធាននៃការតែងសេចក្តីនិងទម្រង់នៃសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដោយមានភ្ជាប់ជាមួយនូវគំរូទម្រង់ដែលជាគោលគំនិតទូទៅសម្រាប់យកទៅអនុវត្តជាក់ស្តែង។

ខ្លឹមសារចុងក្រោយរៀបរាប់ជាអាទិ៍ពីដំណើរការនៃការពិនិត្យសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតនៅទីស្តីការគណៈរដ្ឋមន្ត្រី ការរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោយការប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ការបញ្ជូនសំណុំឯកសារទៅរដ្ឋសភា ការការពារសេចក្តីព្រាងច្បាប់ចំពោះមុខអង្គនីតិប្បញ្ញត្តិ និងការចូលជាធរមាននៃច្បាប់។

គោលការណ៍ណែនាំនេះត្រូវបានចាត់ទុកជាត្រីវិស័យសម្រាប់តម្រង់ទិសក្រុមការងារ ក្រុមជំនាញរបស់ក្រសួង ស្ថាប័នឱ្យមានស្មារតីទទួលខុសត្រូវ ស្គាល់ភារកិច្ចរបស់ខ្លួន ចំណេញពេលវេលា និងធានាឱ្យមានឯកភាពក្នុងការរៀបចំនិងតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

## ក- គោលការណ៍ទូទៅ

ដើម្បីពង្រឹងនិងលើកកម្ពស់គោលការណ៍នីតិរដ្ឋ សន្តិសុខគតិយុត្ត ព្រមទាំងគុណភាពនិងប្រសិទ្ធភាពនៃច្បាប់ឆ្លើយតបនឹងវឌ្ឍនភាពសេដ្ឋកិច្ចនិងសង្គម និងតម្រូវការជាអាទិភាពនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

១- រៀបចំផែនការកសាងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលត្រូវឆ្លើយតបនឹងវឌ្ឍនភាពសេដ្ឋកិច្ចនិងសង្គម និងតាមតម្រូវការជាអាទិភាពនៃបេសកកម្ម តួនាទី និងភារកិច្ចរបស់ខ្លួន។ ដោយឡែកចំពោះសេចក្តីព្រាងច្បាប់និងសេចក្តីព្រាងព្រះរាជក្រឹត្យដែលមានលក្ខណៈជាបទបញ្ញាទូទៅ ត្រូវភ្ជាប់មកជាមួយឯកសារទស្សនាទានរួមមួយ ដែលបញ្ជាក់ពីតម្រូវការចាំបាច់ គោលបំណង អត្ថប្រយោជន៍ ផលប៉ះពាល់ផ្នែកសង្គម សេដ្ឋកិច្ច និងនយោបាយជាតិនិងអន្តរជាតិ រួចបញ្ជូនមកគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ដើម្បីពិនិត្យនិងសម្រេច ជាមុន លើកលែងតែករណីបន្ទាន់ចាំបាច់តាមការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាល។

២- បន្ទាប់ពីទទួលបានការឯកភាពពីគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ គ្រប់ក្រសួង ស្ថាប័ន ត្រូវរៀបចំតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតរបស់ខ្លួន រួចបញ្ជូនមកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីចាត់ចែងតាមនីតិវិធី។

## ខ- គោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត

ដើម្បីឱ្យការរៀបចំនិងការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតមានឯកភាពនៅទូទាំងព្រះរាជាណាចក្រកម្ពុជា គោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ត្រូវបានកំណត់ដូចតទៅ៖

### ១-ដំណើរការនៃការរៀបចំសេចក្តីព្រាងដើមនៃសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត

ជាទូទៅ សេចក្តីព្រាងដើមនៃសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលត្រូវឆ្លងទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវបានក្រសួង ស្ថាប័នទទួលបន្ទុកប្រគល់ភារកិច្ចឱ្យអង្គភាពនីតិកម្មរបស់ខ្លួន សហការជាមួយនាយកដ្ឋានជំនាញ រៀបចំជា២ដំណាក់កាល៖

#### ១.១- សេចក្តីព្រាងដើមដំណាក់កាលទី១

សេចក្តីព្រាងដើមដំណាក់កាលទី១ត្រូវសរសេរលើក្រដាសពណ៌សដែលមានក្បាលលិខិតរបស់ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំ ដោយកត់ត្រាទុកឱ្យបានច្បាស់លាស់នូវ៖

- ឈ្មោះរបស់អង្គភាពទទួលភារកិច្ចរៀបចំសេចក្តីព្រាងនិងអង្គភាពពាក់ព័ន្ធរបស់ក្រសួង ស្ថាប័នដែលបានចូលរួម
- ឈ្មោះរបស់រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬអគ្គនាយកដែលទទួលបន្ទុកតាមដានកិច្ចការរៀបចំសេចក្តីព្រាង
- ឈ្មោះរបស់អ្នកជំនាញការនិងចំណងជើងអត្ថបទជាភាសាខ្មែរ ភាសាបារាំង និង/ឬភាសាអង់គ្លេស ដែលជាមូលដ្ឋានបង្អែក(ប្រសិនបើមាន) និងឈ្មោះរបស់អ្នកច្បាប់ដែលជួយរៀបចំសេចក្តីព្រាង
- លេខទូរសព្ទ និង/ឬសារអេឡិចត្រូនិករបស់អង្គភាពនិងអ្នកដែលទទួលបន្ទុករៀបចំខាងលើ។

ចំពោះការរៀបចំសេចក្តីព្រាងដើមដំណាក់កាលទី១ ក្រសួង ស្ថាប័នសាមីអាចពិគ្រោះយោបល់ក្នុងករណីចាំបាច់ជាមួយសង្គមស៊ីវិល និងផ្នែកឯកជន ដោយយោងទៅលើវិសាលភាពដែលទាក់ទងនឹងបញ្ហាសង្គម បញ្ហាសេដ្ឋកិច្ច និងបញ្ហាថវិកា និងត្រូវសុំយោបល់ពីក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្តដែលពាក់ព័ន្ធ ហើយត្រូវធ្វើការកែសម្រួលសេចក្តីព្រាងដើមដំណាក់កាលទី១ឱ្យបានសព្វគ្រប់សម្រាប់ការពិនិត្យពិភាក្សានៅដំណាក់កាលទី២។

#### ១.២- សេចក្តីព្រាងដើមដំណាក់កាលទី២

ក្រសួង ស្ថាប័នសាមីត្រូវសុំយោបល់ឡើងវិញពីក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្តដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលលើសេចក្តីព្រាងដើមដំណាក់កាលទី១ និងអាចធ្វើការពិគ្រោះយោបល់ក្នុងករណីចាំបាច់ ជាមួយតំណាង

គណបក្សនយោបាយនានាដែលបានចុះបញ្ជីស្របច្បាប់ សង្គមស៊ីវិល និងផ្នែកឯកជន តាមរយៈលិខិត ឬតាមរយៈអង្គប្រជុំ ឬតាមរយៈការរៀបចំជាសិក្ខាសាលាឬវេទិកាពិគ្រោះយោបល់ជាសាធារណៈឱ្យបានគ្រប់ជ្រុងជ្រោយលើទិដ្ឋភាពបច្ចេកទេស សេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន និងនយោបាយ ដើម្បីស្រង់មតិឬប្រតិកម្មរបស់ភាគីពាក់ព័ន្ធទាំងនោះ។ បន្ទាប់មក ក្រសួង ស្ថាប័នសាមីត្រូវធ្វើរបាយការណ៍អំពីលទ្ធផលដូចខាងក្រោម៖

- មតិរបស់បណ្ដាក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្តដែលពាក់ព័ន្ធ និងភាគីពាក់ព័ន្ធដែលបានពិគ្រោះយោបល់
- មតិរបស់ក្រុមការងាររៀបចំសេចក្ដីព្រាងអត្ថបទ ដោយគូសបញ្ជាក់នូវ៖
    - រាល់ចំណុចខ្វែងគំនិតគ្នា
    - យោបល់សម្របសម្រួលរបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត និងយោបល់របស់ភាគីពាក់ព័ន្ធដែលបានផ្ដល់យោបល់ ព្រមទាំងជំហររបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្តដែលមិនព្រមធ្វើការកែប្រែតាម។

ក្រោយពីការសុំនិងពិគ្រោះយោបល់ខាងលើ ក្រសួង ស្ថាប័នសាមីត្រូវពិនិត្យកែសម្រួលសេចក្ដីព្រាងដើមដំណាក់កាលទី១ឱ្យទៅជាសេចក្ដីព្រាងដើមដំណាក់កាលទី២ ព្រមទាំងកែសម្រួលសេចក្ដីថ្លែងហេតុឬកំណត់មូលហេតុសង្ខេបឡើងវិញ រួចធ្វើរបាយការណ៍ភ្ជាប់ជាមួយសំណុំឯកសារបញ្ជូនទៅទីស្ដីការគណៈរដ្ឋមន្ត្រី។

សំណុំឯកសារដែលត្រូវបញ្ជូនទៅទីស្ដីការគណៈរដ្ឋមន្ត្រី មាន៖

- ឯកសារទស្សនាទានចុងក្រោយ (សម្រាប់សេចក្ដីព្រាងច្បាប់និងសេចក្ដីព្រាងព្រះរាជក្រឹត្យដែលមានលក្ខណៈជាបទបញ្ញាទូទៅ)
- សេចក្ដីព្រាងអត្ថបទ ពុម្ពអក្សរខ្មែរយូនីកូដ
- សេចក្ដីថ្លែងហេតុចំពោះសេចក្ដីព្រាងអត្ថបទដែលត្រូវសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ ឬកំណត់មូលហេតុសង្ខេបចំពោះសេចក្ដីព្រាងអត្ថបទដែលត្រូវសុំព្រះរាជតម្រិះពីព្រះមហាក្សត្រឬសុំការសម្រេចពីប្រមុខរដ្ឋស្ដីទី ឬពីនាយករដ្ឋមន្ត្រី
- របាយការណ៍វាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(សម្រាប់សេចក្ដីព្រាងច្បាប់ក្នុងវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ សង្គមកិច្ច និងបរិស្ថាន)
- ឯកសារពាក់ព័ន្ធសំខាន់ៗ
- ឯកសារសុសកូពី។

សំណុំឯកសារនេះត្រូវបញ្ជូនទៅទីស្ដីការគណៈរដ្ឋមន្ត្រីតាមលិខិតបញ្ជូនដែលរដ្ឋមន្ត្រីឬប្រធានស្ថាប័នចុះហត្ថលេខា។

## ២- ការរៀបចំសេចក្ដីថ្លែងហេតុឬកំណត់មូលហេតុសង្ខេប

### ២.១- សេចក្ដីថ្លែងហេតុ

សេចក្ដីថ្លែងហេតុជាអត្ថបទដែលត្រូវភ្ជាប់ជាមួយសេចក្ដីព្រាងច្បាប់ ដែលត្រូវសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ។

សេចក្ដីថ្លែងហេតុត្រូវសរសេរឱ្យមានន័យច្បាស់លាស់ ចំបញ្ហា ខ្លី ហើយងាយយល់ ដោយមានការលើកឡើងអំពី៖

- គោលបំណងនិងស្មារតីរបស់សេចក្ដីព្រាងអត្ថបទ ដោយពន្យល់ឱ្យបានច្បាស់លាស់អំពីខ្លឹមសារជាសារវន្ត ព្រមទាំងផលប្រយោជន៍ដែលទទួលបានពីការដាក់ចេញនូវសេចក្ដីព្រាងទាំងនោះឬមូលហេតុដែលនាំឱ្យមានការកែប្រែច្បាប់ឬបទប្បញ្ញត្តិជាធរមាន
- ដំណើរការនៃការរៀបចំសេចក្ដីព្រាង
- ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- ភាពគតានរបស់សេចក្ដីព្រាងអត្ថបទចំពោះសមិទ្ធកម្មនៃរដ្ឋធម្មនុញ្ញ ច្បាប់ជាធរមាននានា ផែនការសកម្មភាព និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងស្ថានភាពជាក់ស្ដែងរបស់ប្រទេសជាតិ
- ខ្លឹមសារសង្ខេបអំពីជំពូកសំខាន់ៗ ជាពិសេស ទោសប្បញ្ញត្តិ ចំពោះសេចក្ដីព្រាងច្បាប់។ ក្នុងករណីមានការប្រែប្រួលចំណងជើងសេចក្ដីព្រាងច្បាប់ ចំណងជើងជំពូក ចំណងជើងផ្នែក ចំណងជើង... ឬចំនួនជំពូក ចំនួនមាត្រា ក្រោយពីកិច្ចប្រជុំណាមួយ ក្រសួង ស្ថាប័នសាមីត្រូវរៀបចំសេចក្ដីថ្លែងហេតុជាថ្មី។

សេចក្ដីថ្លែងហេតុដែលត្រូវភ្ជាប់ជាមួយសេចក្ដីព្រាងអត្ថបទដែលត្រូវបញ្ជូនទៅទីស្ដីការគណៈរដ្ឋមន្ត្រីសម្រាប់ដាក់សុំឆ្លងអង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យចុងក្រោយឬនីតិវិធីផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីឬតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី ត្រូវសរសេរក្នុងនាមរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី (ពុំចាំបាច់ចុះហត្ថលេខាលើសេចក្ដីថ្លែងហេតុ) ដោយមានលិខិតស្នើរបស់រដ្ឋមន្ត្រីឬប្រធានស្ថាប័ននោះផ្ញើជូននាយករដ្ឋមន្ត្រី។ បន្ទាប់ពីសេចក្ដីព្រាងអត្ថបទត្រូវបានគណៈរដ្ឋមន្ត្រីឯកភាពរួចក្នុងសម័យប្រជុំពេញអង្គឬកិច្ចប្រជុំគណៈអចិន្ត្រៃយ៍គណៈរដ្ឋមន្ត្រី ក្រសួង ស្ថាប័នសាមីត្រូវសហការជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់រៀបចំសេចក្ដីថ្លែងហេតុរបស់រាជរដ្ឋាភិបាល ដោយសរសេរក្នុងនាមនាយករដ្ឋមន្ត្រី និងបញ្ជាក់ពីកាលបរិច្ឆេទដែលសេចក្ដីព្រាងអត្ថបទត្រូវបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី រួចផ្ញើលិខិតស្នើសុំហត្ថលេខានាយករដ្ឋមន្ត្រីផ្ញើជូនប្រធានរដ្ឋសភា។

ចំណងជើងនៃសេចក្ដីថ្លែងហេតុត្រូវសរសេរដូចខាងក្រោម៖

**សេចក្ដីថ្លែងហេតុ**

**អំពី**

**សេចក្ដីព្រាងច្បាប់ស្ដីពី...**

### ២.២- កំណត់មូលហេតុសង្ខេប

កំណត់មូលហេតុសង្ខេបជាអត្ថបទដែលត្រូវភ្ជាប់ជាមួយសេចក្ដីព្រាងព្រះរាជក្រឹត្យដែលត្រូវសុំព្រះរាជតម្រិះពីព្រះមហាក្សត្រ និងជាមួយសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលត្រូវសុំការសម្រេចពីនាយករដ្ឋមន្ត្រី។

កំណត់មូលហេតុសង្ខេបត្រូវសរសេរឱ្យមានន័យច្បាស់លាស់ ចំបញ្ហា ខ្លី ហើយងាយយល់ ដោយមានការលើកឡើងអំពី៖

- មូលហេតុដែលនាំឱ្យមានការរៀបចំអត្ថបទនេះឬការកែប្រែបទប្បញ្ញត្តិដែលនៅជាធរមាននិងការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- ខ្លឹមសារសំខាន់ៗនៃអត្ថបទ។

កំណត់មូលហេតុសង្ខេបដែលត្រូវភ្ជាប់ជាមួយសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្តដែលត្រូវបញ្ជូនទៅទីស្ដីការគណៈរដ្ឋមន្ត្រីសម្រាប់ដាក់សុំឆ្លងអង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យចុងក្រោយឬនីតិវិធីផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីឬតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី ត្រូវសរសេរក្នុងនាមរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី(ពុំចាំបាច់ចុះហត្ថលេខាលើកំណត់មូលហេតុសង្ខេប) ដោយមានលិខិតស្នើរបស់រដ្ឋមន្ត្រីឬប្រធានស្ថាប័ននោះផ្ញើជូននាយករដ្ឋមន្ត្រី។ ក្នុងករណីមានការប្រែប្រួលចំណងជើងសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្ត ចំណងជើងជំពូក ចំណងជើងផ្នែក ចំណងជើង... ឬចំនួនជំពូក ចំនួនមាត្រា ក្រោយពីកិច្ចប្រជុំណាមួយ ក្រសួង ស្ថាប័នសាមីត្រូវរៀបចំសេចក្ដីកំណត់មូលហេតុសង្ខេបជាថ្មី។

កំណត់មូលហេតុសង្ខេបដែលត្រូវភ្ជាប់ជាមួយសេចក្ដីព្រាងព្រះរាជក្រឹត្យ ត្រូវចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រីសម្រាប់ថ្វាយព្រះមហាក្សត្រឬជូនប្រមុខរដ្ឋស្ដីទី មានទម្រង់ជាលិខិតស្នើរបស់រាជរដ្ឋាភិបាល ដែលសរសេរជាអក្សរកាត់ថា ល.ស.។

ចំពោះកំណត់មូលហេតុសង្ខេបស្ដីពីការតែងតាំង ត្រូវបញ្ជាក់ពីមូលហេតុខ្លីៗពីកម្មវត្ថុដែលតម្រូវឱ្យមានការតែងតាំង និងមានភ្ជាប់សំណុំឯកសារចាំបាច់មួយចំនួន មានជាអាទិ៍៖

- សំណើរបស់ក្រសួង ស្ថាប័នសាមី ដែលមានការបញ្ជាក់ពីតម្រូវការនៃការតែងតាំង ស្ថានភាពទំនេរនៃមុខតំណែង សមត្ថភាព បទពិសោធ និងគុណសម្បត្តិនៃមន្ត្រីរាជការដែលត្រូវតែងតាំង

- សំណុំលិខិតស្នើតែងតាំងដែលត្រូវមានភ្ជាប់តារាងបញ្ជាក់ពីឈ្មោះ ថ្ងៃខែឆ្នាំកំណើត កម្រិតវប្បធម៌ កម្រិតជំនាញ អត្តលេខ(បើមាន) ឋានន្តរសក្តិ ថ្នាក់ ក្របខ័ណ្ឌ មុខងារបច្ចុប្បន្ន និងមុខងារស្នើតែងតាំង ព្រមទាំងជីវប្រវត្តិរបស់សាមីជននិងសញ្ញាបត្រដែលមាន
- លិខិតបញ្ជាក់ដែលជាទិដ្ឋាការរបស់ក្រសួងមុខងារសាធារណៈ។

ប្រសិនបើការតែងតាំងជាក្រុម ដូចជាអាជ្ញាធរ ក្រុមប្រឹក្សាជាដើម ត្រូវភ្ជាប់បន្ថែមនូវបញ្ជីឈ្មោះរបស់អ្នកដែលត្រូវតែងតាំងនិងអត្ថបទជាមូលដ្ឋានដែលនាំឱ្យមានការតែងតាំងនោះ។

ចំណងជើងនៃកំណត់មូលហេតុសង្ខេបត្រូវសរសេរដូចខាងក្រោម៖

**កំណត់មូលហេតុសង្ខេប**

**អំពី**

**សេចក្តីព្រាងព្រះរាជក្រឹត្យឬអនុក្រឹត្យ... ស្តីពី...**

## ៣- វិធាននៃការតែងសេចក្តីនិងទម្រង់នៃសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត

### ៣.១- វិធាននៃការតែងសេចក្តី

ការតែងសេចក្តីនៃសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតត្រូវអនុវត្តដូចតទៅ៖

#### ៣.១.១- ក្បាលលិខិត

ក្បាលលិខិតត្រូវដាក់ចំណងជើងនៃសេចក្តីព្រាងអត្ថបទឱ្យបានច្បាស់លាស់ ហើយបើជាអត្ថបទដែលត្រូវធ្វើវិសោធនកម្មឬកែសម្រួល ត្រូវបញ្ជាក់នៅក្នុងចំណងជើងស្តីពីវិសោធនកម្មឬការកែសម្រួល។

#### ៣.១.២- មូលបទ

មូលបទត្រូវ៖

- ចែងលេខ ថ្ងៃខែឆ្នាំ និងចំណងជើងនៃលិខិតបទដ្ឋានគតិយុត្តដែលត្រូវយោងឱ្យបានពេញលេញ ហើយមិនត្រូវប្រើសញ្ញាខណ្ឌនៅចុងឃ្លានៃគំនូសចុងក្រោយទេ

ឧទាហរណ៍ : - បានឃើញអនុក្រឹត្យលេខ... ចុះថ្ងៃទី...(លេខ) ខែ...(អក្សរ) ឆ្នាំ...(លេខ) ស្តីពី...(ចំណងជើងនៃអនុក្រឹត្យដែលយោងទាំងស្រុង)

- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ... ចុះថ្ងៃទី...(លេខ) ខែ...(អក្សរ) ឆ្នាំ...(លេខ) ស្តីពី...(ចំណងជើងនៃសេចក្តីសម្រេចដែលយោងទាំងស្រុង)

- យោងតែលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដោយផ្ទាល់ ដែលមានឋានានុក្រមស្មើឬខ្ពស់ជាង។

#### ៣.១.៣- ខ្លឹមសារនៃអត្ថបទ

ខ្លឹមសារនៃអត្ថបទត្រូវ៖

- ចែងខ្លឹមសារឱ្យបានច្បាស់លាស់ ហើយត្រូវខិតខំប្រើពាក្យដែលមាននិយមន័យច្បាប់ចំៗ ច្បាស់លាស់ និងពាក្យដែលមិននាំឱ្យមានការបកស្រាយខុសពីស្មារតីដើមដែលចង់បាន ក្នុងនោះត្រូវ៖
    - ប្រើពាក្យបច្ចេកទេសដែលមាននៅក្នុងច្បាប់និងមានក្នុងសៀវភៅបោះពុម្ពដោយវិស័យអប់រំ ឬពាក្យបច្ចេកទេសដែលគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ឬក្រុមប្រឹក្សាជាតិភាសាខ្មែរបានអនុម័ត និងដែលរាជរដ្ឋាភិបាលបានប្រកាសឱ្យប្រើ ហើយក្នុងការសរសេរត្រូវផ្អែកលើសទ្ទានុក្រមរបស់គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ឬវចនានុក្រមខ្មែរបោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យគ្រាទី៥ និងវចនានុក្រមខ្មែរដែលរៀបចំដោយក្រុមប្រឹក្សាជាតិភាសាខ្មែរនៃរាជបណ្ឌិត្យសភាកម្ពុជា

- គួរចៀសវាងការប្រើពាក្យបាលីសំស្ក្រឹតឬពាក្យបរទេសឱ្យអស់លទ្ធភាព
- គួរចៀសវាងការប្រើពាក្យ **នឹង** នៅមុខកិរិយាសព្ទឱ្យអស់លទ្ធភាព
- មិនអនុញ្ញាតឱ្យដាក់លេខយោងទៅពន្យល់ឬបកស្រាយនៅរឹមខាងក្រោមនៃទំព័រទេ។

- តែងល្បះខ្លីៗតែមានន័យគ្រប់គ្រាន់ ដោយមានការដកឃ្លានិងការដាក់សញ្ញាខណ្ឌឱ្យបានត្រឹមត្រូវ
- ប្រើពាក្យ **មានជាអាទិ៍** ក្នុងការរៀបរាប់មិនអស់ មិនត្រូវប្រើពាក្យ ។ល។ ទេ
- ចៀសវាងការគូសបន្ទាត់នៅក្រោមចំណងជើងនៃគន្ថី មាតិកា ជំពូក ផ្នែក អនុផ្នែកឬកថាភាគ មាត្រា និងប្រការ ក៏ដូចជាក្នុងខ្លឹមសារនៃសេចក្តីព្រាងអត្ថបទទាំងមូល តែប្រើអក្សរមូលដិតខ្មៅចំពោះឈ្មោះឬអក្សរកាត់នៃឈ្មោះគ្រឹះស្ថានសាធារណៈ ឈ្មោះទិវាជាតិនានាជាដើម
- សរសេរចំណងជើងនៃសេចក្តីព្រាងអត្ថបទឱ្យធំជាងចំណងជើងនៃគន្ថី មាតិកា ជំពូក ផ្នែក អនុផ្នែកឬកថាភាគ ចំណែកឯចំណងជើងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស សារាចរ និងគន្ថី មាតិកា ជំពូក ផ្នែក អនុផ្នែកឬកថាភាគ មាត្រា និងប្រការ ត្រូវប្រើពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light
- ប្រើពាក្យ **មាត្រា** សម្រាប់តែក្នុងក្រម ច្បាប់ ព្រះរាជក្រឹត្យ និងអនុក្រឹត្យ ចំណែកពាក្យ **ប្រការ** វិញ ប្រើសម្រាប់តែក្នុងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ប្រកាស និងសេចក្តីសម្រេចរបស់ក្រសួង ស្ថាប័ន
- សរសេរខ្លឹមសារនៃអត្ថបទ ត្រូវប្រើពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Siem Reap ទំហំអក្សរ ១២
- សរសេរជាលេខខ្មែរមុន រួចទើបសរសេរជាអក្សរក្នុងវង់ក្រចកចំពោះចំនួនក្នុងខ្លឹមសារនៃអត្ថបទ
- ចៀសវាងការដាក់ឈ្មោះរបស់សាមីជនក្នុងព្រះរាជក្រឹត្យស្តីពីការបង្កើតឬការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរ ក្រុមប្រឹក្សាជាតិ ឬក្នុងអនុក្រឹត្យស្តីពីការបង្កើតឬការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិនានា តែត្រូវដាក់មុខតំណែងឬមុខងារនិងតួនាទីនៃតំណាងក្រសួង ស្ថាប័នសាមីវិញ។ ជាគោលការណ៍ការតែងតាំងសាមីជនជាក់ស្តែងត្រូវធ្វើដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លើកលែងតែករណីដែលមានការកំណត់ឱ្យតែងតាំងសាមីជនដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ
- បញ្ជាក់ពីឈ្មោះ អត្តលេខ(បើមាន) ឋានន្តរសក្តិ ថ្នាក់ ក្របខ័ណ្ឌ មុខងាររបស់សាមីជន ដោយសរសេរឈ្មោះជាអក្សរខ្មែរឱ្យបានត្រឹមត្រូវ ចំពោះការតែងតាំងមន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ចំណែកឯការតែងតាំងជំនួសមន្ត្រីដែលត្រូវបានបញ្ចប់ភារកិច្ច ត្រូវចែងបន្ថែមថា ជំនួស ឯកឧត្តម...(ឈ្មោះ) ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត) និងត្រូវចែងអំពីការបញ្ចប់មុខតំណែងបច្ចុប្បន្នណាមួយរបស់សាមីជន(ក្នុងករណីមានការបញ្ចប់មុខតំណែង) ដែលទទួលការតែងតាំងឱ្យកាន់តំណែងថ្មីក្នុងព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ឬប្រកាសរបស់ក្រសួងស្តីពីការតែងតាំង ការផ្លាស់ប្តូរ ឬការបញ្ចប់ភារកិច្ច
- ចែងល្បះក្នុងឧបសម្ព័ន្ធថា ឧបសម្ព័ន្ធទី...នៃច្បាប់ស្តីពី... ឬនៃលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី(ចំណងជើង) ក្នុងករណីដែលច្បាប់ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតនោះមានឧបសម្ព័ន្ធភ្ជាប់
- ការយោងមាត្រាឬប្រការ ត្រូវសរសេរថា មាត្រា... នៃក្រមនេះ/ច្បាប់នេះ/ព្រះរាជក្រឹត្យនេះ/អនុក្រឹត្យនេះ ឬប្រការ... នៃប្រកាសនេះ/សេចក្តីសម្រេចនេះ
- ការយោងកថាខណ្ឌ ត្រូវសរសេរថា កថាខណ្ឌទី... នៃមាត្រា... នៃក្រមនេះ/ច្បាប់នេះ/ព្រះរាជក្រឹត្យនេះ/អនុក្រឹត្យនេះ ឬប្រការ... នៃប្រកាសនេះ/សេចក្តីសម្រេចនេះ
- ការយោងកថាខណ្ឌដែលស្ថិតក្នុងមាត្រាតែមួយឬប្រការតែមួយ ត្រូវសរសេរថា កថាខណ្ឌទី... ខាងលើនេះ
- ការយោងវាក្យខណ្ឌដែលស្ថិតក្នុងមាត្រាតែមួយឬប្រការតែមួយ ត្រូវសរសេរថា វាក្យខណ្ឌទី... នៃកថាខណ្ឌទី... ខាងលើនេះ
- ការយោងបទប្បញ្ញត្តិ ត្រូវសរសេរថា បទប្បញ្ញត្តិនៃក្រមនេះ/ច្បាប់នេះ/ព្រះរាជក្រឹត្យនេះ/អនុក្រឹត្យនេះ ឬប្រការ... នៃប្រកាសនេះ/សេចក្តីសម្រេចនេះ។

### ៣.២- ទម្រង់

ទម្រង់នៃសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតត្រូវអនុលោមតាមប្រភេទដូចខាងក្រោម៖

#### ៣.២.១- ទម្រង់នៃសេចក្តីព្រាងច្បាប់

ក- ក្របសន្លឹកទំព័រដំបូង

ក.១- ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ដែលត្រូវដាក់ឆ្លងអង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យចុងក្រោយឬនីតិវិធីផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីឬតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី ក្រសួង ស្ថាប័នសាមីត្រូវប្រើក្រដាសក្បាលលិខិតរបស់ក្រសួង ស្ថាប័ន ហើយនៅចំកណ្តាលសន្លឹកទំព័រនេះ ត្រូវដាក់ពាក្យ **សេចក្តីព្រាង** ក្រោមពាក្យសេចក្តីព្រាង ចំកណ្តាលដាក់ពាក្យ **ច្បាប់** ក្រោមពាក្យច្បាប់ ចំកណ្តាលដាក់ពាក្យ **ស្តីពី** ក្រោមពាក្យស្តីពី ដាក់ចំណងជើងនៃសេចក្តីព្រាងច្បាប់។ នៅប៉ែកខាងក្រោមនៃទំព័រ ត្រូវដាក់កាលបរិច្ឆេទចុងក្រោយបង្អស់ដែលក្រសួង ស្ថាប័ន បានរៀបចំសេចក្តីព្រាងអត្ថបទនោះផ្ញើទៅទីស្តីការគណៈរដ្ឋមន្ត្រី។

**សូមមើលគំរូទី១** : ទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ដែលត្រូវដាក់ឆ្លងអង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យចុងក្រោយឬនីតិវិធីផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីឬតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី នៅទំព័រទី១០។

ក.២- ចំពោះក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ក្រោយពេលឆ្លងអង្គប្រជុំតាមនីតិវិធីរួចហើយ ដើម្បីផ្ញើទៅស្ថាប័ននីតិប្បញ្ញត្តិ ក្រសួង ស្ថាប័នសាមីត្រូវប្រើក្រដាសក្បាលលិខិតរបស់រាជរដ្ឋាភិបាលដែលមិនមានលេខ ហើយនៅចំកណ្តាលសន្លឹកទំព័រនេះ ត្រូវដាក់ពាក្យ **សេចក្តីព្រាង** ក្រោមពាក្យសេចក្តីព្រាង ចំកណ្តាលដាក់ពាក្យ **ច្បាប់** ក្រោមពាក្យច្បាប់ ដាក់ពាក្យ **ស្តីពី** ក្រោមពាក្យស្តីពី ដាក់ចំណងជើងនៃសេចក្តីព្រាងច្បាប់។ នៅប៉ែកខាងក្រោមនៃទំព័រត្រូវដាក់ថា **បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី... ខែ... ឆ្នាំ...**។

**សូមមើលគំរូទី២** : ទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ក្រោយពេលឆ្លងអង្គប្រជុំតាមនីតិវិធីដើម្បីផ្ញើទៅស្ថាប័ននីតិប្បញ្ញត្តិ នៅទំព័រទី១១។

ខ- សន្លឹកទំព័របន្តបន្ទាប់

ជាទូទៅ ក្រសួង ស្ថាប័នសាមីត្រូវតែងសេចក្តីដោយរៀបចំចែកអត្ថបទជាជំពូក ផ្នែក អនុផ្នែកឬកថាភាគ និងសរសេរបទប្បញ្ញត្តិជាមាត្រា។ ក្នុងករណីដែលអត្ថបទនៃសេចក្តីព្រាងច្បាប់នេះវែង ហើយមានបទប្បញ្ញត្តិច្រើនដែលត្រូវចែង អាចចែកជាគន្ថី មាតិកា ជំពូក ផ្នែក អនុផ្នែកឬកថាភាគ និងសរសេរបទប្បញ្ញត្តិជាមាត្រា។ ពាក្យគន្ថី មាតិកា ជំពូក ផ្នែក និងអនុផ្នែកឬកថាភាគ ត្រូវដាក់នៅចំកណ្តាលទំព័រនិងមានដាក់ចំណងជើងនៅចំកណ្តាល ក្រោមពាក្យគន្ថី មាតិកា ជំពូក ផ្នែក និងអនុផ្នែកឬកថាភាគដែរ។ មាត្រានីមួយៗ ជាទូទៅ មិនត្រូវមានចំណងជើងទេ ប៉ុន្តែក្នុងករណីចាំបាច់ អាចអនុញ្ញាតបានដោយត្រូវដាក់ចំណងជើងគ្រប់មាត្រាទាំងអស់។ គន្ថី មាតិកា ជំពូក ផ្នែក និងអនុផ្នែកឬកថាភាគ ត្រូវដាក់លេខរៀងតាមលំដាប់លំដោយ ហើយត្រូវមានដាក់ពាក្យ ទី នៅចន្លោះពាក្យគន្ថី មាតិកា ជំពូក ផ្នែក អនុផ្នែកឬកថាភាគ និងលេខ ជាឧទាហរណ៍ : **គន្ថីទី១ មាតិកាទី១ ជំពូកទី១ ផ្នែកទី១ អនុផ្នែកទី១ឬកថាភាគទី១** ប៉ុន្តែមានសេចក្តីព្រាងច្បាប់ខ្លះខ្លី អាចពុំមានការបែងចែកដូចខាងលើឡើយ ដោយគ្រាន់តែកំណត់ជាមាត្រាប៉ុណ្ណោះ។

ខ.១- ជំពូក

**ជំពូកទី១ បទប្បញ្ញត្តិទូទៅ**

ជំពូកនេះត្រូវចែងអំពីគោលបំណងនិងវិសាលភាពនៃច្បាប់និងបទប្បញ្ញត្តិ ដែលមានអានុភាពប្រើប្រាស់សម្រាប់ច្បាប់ទាំងមូល ហើយអាចមាននិយមន័យផងដែរ។ គោលបំណងនិងវិសាលភាពនៃច្បាប់ ត្រូវចែងជាបន្តបន្ទាប់នៅក្នុងមាត្រា១និងមាត្រា២។ ប្រសិនបើមាននិយមន័យនៃបច្ចេកសព្ទឬវាក្យសព្ទសំខាន់ៗ និយមន័យនោះត្រូវចែងនៅក្នុង

មាត្រា៣ឬនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ ហើយបច្ចេកសព្ទឬវាក្យសព្ទទាំងនោះត្រូវរៀបតាមអក្ខរក្រមនៃភាសាខ្មែរ។

**ជំពូកទី២**(ចំណងជើង)និង**ជំពូក**បន្តបន្ទាប់

ជំពូកទី២និងជំពូកបន្តបន្ទាប់អាចចែកជាផ្នែក ហើយត្រូវចែងអំពីខ្លឹមសារពិស្តារទាំងឡាយដែលមានគោលដៅដាក់ជាបញ្ញត្តិដើម្បីឱ្យអនុវត្ត ហើយត្រូវចែងលម្អិតតាមផ្នែកដោយឡែកៗ ដែលច្បាប់ត្រូវបញ្ញត្ត។

**ជំពូកទី... បទប្បញ្ញត្តិដោយឡែក**(ប្រសិនបើមាន)

ជំពូកនេះត្រូវចែងអំពីបទប្បញ្ញត្តិដែលផ្សេងពីបទប្បញ្ញត្តិដែលគ្របដណ្ដប់លើជំពូកនានានៃសេចក្ដីព្រាងច្បាប់។

**ជំពូកទី... សហាវិធាន**(ប្រសិនបើមាន)

នៅក្នុងជំពូកនេះ ត្រូវចែងអំពីវិធានរួម សម្រាប់យកទៅអនុវត្តលើជំពូកផ្សេងៗនៅក្នុងសេចក្ដីព្រាងច្បាប់។

**ជំពូកទី... ទោសប្បញ្ញត្តិ**

នៅក្នុងជំពូកនេះ ត្រូវចែងអំពីទណ្ឌកម្ម ស្ថានទម្ងន់ទោស ស្ថានសម្រាលទោស(ប្រសិនបើមានភាពចាំបាច់) និងរបបគតិយុត្តនៃប្រភេទទណ្ឌកម្មពិន័យជាប្រាក់ (អាចជា : ការពិន័យជាប្រាក់ ពិន័យអន្តរការណ៍ ការផាកពិន័យ) ចំពោះអំពើប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិដែលបានចែងក្នុងច្បាប់។ ការចែងអំពីទោសប្បញ្ញត្តិដែលពាក់ព័ន្ធនឹងមាត្រាណាមួយត្រូវយោងទៅលេខមាត្រានោះឱ្យច្បាស់ចំៗតែម្ដង។

**ជំពូកទី... អន្តរប្បញ្ញត្តិ** (ប្រសិនបើមាន)

ជំពូកនេះអាចចែងបានតែចំពោះករណីដែលកំណត់រយៈពេលមួយជាកំណត់សម្រាប់ផ្ដល់លទ្ធភាពឱ្យបំពេញបែបបទអន្តរកាល ដើម្បីសម្រួលការអនុវត្តបទប្បញ្ញត្តិនៃច្បាប់ថ្មីដែលចូលជាធរមានជំនួសច្បាប់ឬបទប្បញ្ញត្តិនៃច្បាប់ចាស់ដែលពាក់ព័ន្ធ។ ប្រសិនបើមានបដិប្បញ្ញត្តិ ត្រូវរៀបចំចែងក្នុងជំពូកនេះដែរ។

**ជំពូកទី... អវសានប្បញ្ញត្តិ**

ជំពូកនេះមានតែ១ឬ២មាត្រាយ៉ាងច្រើន ដែលក្នុងនោះ អាចមានមាត្រាមួយដែលចែងថា ច្បាប់ស្ដីពី... ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ... និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ឬបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ និងអាចមានមាត្រាមួយទៀតដែលចែងថា ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ចំពោះតែករណីច្បាប់ណាដែលត្រូវអនុវត្តជាការប្រញាប់តែប៉ុណ្ណោះ។

គ្រង់ប៉ែកខាងស្ដាំ ១ភាគ៣នៃទំព័រចុងក្រោយបង្អស់នៃអត្ថបទ ត្រូវសរសេរដូចខាងក្រោម៖

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី.......... ខែ............ ឆ្នាំ................
នាសម័យប្រជុំរដ្ឋសភាលើកទី... (ឬជាវិសាមញ្ញ) នីតិកាលទី...។
ថ្ងៃ........ ខែ......... ឆ្នាំ......... .....ស័ក ព.ស. .........
រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ.......... ឆ្នាំ............

**ប្រធានរដ្ឋសភា**
**(ត្រាមនិងឈ្មោះ)**

ខ.២- មាត្រា

មាត្រាត្រូវដាក់លេខរៀងតាមលំដាប់លំដោយ ដោយចាប់ផ្តើមពីមាត្រា១នៃសេចក្តីព្រាងច្បាប់នោះ។ ចំពោះមាត្រាត្រូវចាប់ផ្តើមសរសេរឃ្លាតពីរឹមទំព័រខាងឆ្វេង ដោយដាក់លេខនៅក្រោយជាប់នឹងពាក្យ **មាត្រា** ហើយមិនត្រូវប្រើពាក្យ **ទី** នៅចន្លោះមាត្រានិងលេខឡើយ ក្រោយលេខមាត្រាត្រូវដកឃ្លា រួចប្រើសញ្ញា .-។

ឧទាហរណ៍ : **មាត្រា១ .-**

ការតែងសេចក្តីនៅតាមមាត្រានីមួយៗត្រូវផ្តើមល្បះដោយចុះបន្ទាត់មកក្រោមលេខមាត្រា ហើយសរសេរស្មើនឹងដើមលេខនៃមាត្រានោះ។ ពេលសរសេរមិនអស់ ចូលដល់បន្ទាត់ទី២ ត្រូវចាប់ផ្តើមសរសេរល្បះបន្តស្មើនឹងដើមពាក្យមាត្រា។

ឧទាហរណ៍ : ច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ

**មាត្រា១ .-**

ច្បាប់នេះកំណត់អំពីក្របខ័ណ្ឌនិងយន្តការសម្រាប់គ្រប់គ្រង និងធានាសុវត្ថិភាព គុណភាព អនាម័យ និងភាពស្របច្បាប់នៃម្ហូបអាហារ ក្នុងគ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្មម្ហូបអាហារ ដើម្បីផ្តល់ការការពារសុខភាព និងសុវត្ថិភាពម្ហូបអាហារសម្រាប់អ្នកប្រើប្រាស់ និងធានាឱ្យមានការធ្វើពាណិជ្ជកម្មម្ហូបអាហារប្រកបដោយភាពស្មោះត្រង់។

មាត្រានីមួយៗអាចចែកជាកថាខណ្ឌ ហើយកថាខណ្ឌអាចចែកជាវាក្យខណ្ឌ។ ប៉ុន្តែក្នុងមាត្រានីមួយៗ គួរចែងបទប្បញ្ញត្តិតែមួយ ហើយមិនត្រូវផ្តើមមាត្រាដោយដាក់លេខកថាខណ្ឌតែម្តងទេ ត្រូវតែមានល្បះផ្តើមដើម្បីអត្ថាធិប្បាយអំពីកថាខណ្ឌដែលត្រូវដាក់លេខរៀង។ ក្នុងករណីមានខ្លឹមសារដោយឡែកពីគ្នា ត្រូវតែមានសញ្ញាខណ្ឌនៅចុងល្បះគ្រប់លេខរៀងឬលំដាប់អក្សរទាំងអស់ តែក្នុងករណីដែលការរៀបរាប់ទាំងនោះជាកន្សោមនៃលក្ខខណ្ឌដែលច្បាប់នោះបញ្ញត្តឱ្យមានរួមគ្នាទាំងអស់ ត្រូវដាក់គំនូស ហើយមិនដាក់សញ្ញាខណ្ឌនៅចុងវាក្យខណ្ឌនីមួយៗនោះទេ គឺដាក់សញ្ញាខណ្ឌនៅខាងចុងវាក្យខណ្ឌក្រោយបង្អស់តែប៉ុណ្ណោះ។ នៅខាងចុងល្បះផ្តើមរបស់មាត្រានីមួយៗ ត្រូវប្រើសញ្ញាដំពីរ(៖) មិនត្រូវប្រើសញ្ញាចំណុចពីរ( : )ឬសញ្ញាលេខចែក(÷)ឡើយ។

ឧទាហរណ៍ក្នុងករណីដាក់គំនូស : ច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ

**មាត្រា២៣ .-**

ការចិញ្ចឹមសត្វនិងការបង្កាត់ពូជសត្វ ព្រមទាំងការបង្កើតទីកន្លែងផលិតឬសន្និធិផលិតផលសត្វ ជាលក្ខណៈពាណិជ្ជកម្ម ត្រូវគ្រប់គ្រងតាមរយៈ៖

- ការផ្តល់លិខិតអនុញ្ញាត
- ការចុះបញ្ជីពូជសត្វក្នុងស្រុកនិងពូជថ្មីនៃសត្វ
- ការបង្កើតអត្តសញ្ញាណកម្មសត្វនិងប្រព័ន្ធតាមដានប្រភពសត្វ។

ឧទាហរណ៍ក្នុងករណីដាក់លេខរៀង : ច្បាប់ស្តីពីសញ្ជាតិ

**មាត្រា១២ .-**

ជនបរទេសដែលអាចសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍បាន ត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

១- មានគំនិត មារយាទ និងសីលធម៌ល្អ។

២- ពុំដែលមានទោសពីបទឧក្រិដ្ឋឬបទមជ្ឈិមណាមួយ។

៣- មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដាក់ពាក្យសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍។

៤- ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្ត្រខ្មែរខ្លះៗ។

៥- មានបញ្ញានិងកាយសម្បទាដែលមិននាំឱ្យមានគ្រោះថ្នាក់ ឬនាំឱ្យមានបន្ទុកដល់ជាតិ។

ឧទាហរណ៍ក្នុងករណីដាក់ជាលំដាប់អក្សរ : ច្បាប់ស្តីពីសំណង់

**មាត្រា៧១ .-**

រយៈពេលនៃការធានាចំពោះវិការៈនៃការងារដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ គិតចាប់ពីថ្ងៃប្រគល់ទទួលសំណង់ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- ១០(ដប់)ឆ្នាំយ៉ាងតិច ចំពោះគ្រឿងផ្គុំសំណង់ធ្វើពីបេតុងសសៃដែក បេតុងដែក ឬដែក។

ខ- ៥(ប្រាំ)ឆ្នាំយ៉ាងតិច ចំពោះជញ្ជាំងខាងក្រៅ បង្អួច ទ្វារ និងដំបូលអគារ។

គ- ២(ពីរ)ឆ្នាំយ៉ាងតិច ចំពោះការងារផ្នែកអគ្គិសនី ទឹក មេកានិក និងការងារពាក់ព័ន្ធផ្សេងទៀត។

**សូមមើលគំរូទី៣** : ទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្តីព្រាងច្បាប់ នៅទំព័រទី១២។

**សូមមើលគំរូទី៤** : ទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងឬរដ្ឋលេខាធិការដ្ឋាន ក្រោយពេលឆ្លងអង្គប្រជុំតាមនីតិវិធីដើម្បីផ្ញើទៅស្ថាប័ននីតិប្បញ្ញត្តិ នៅទំព័រទី១៣។

**សូមមើលគំរូទី៥** : ទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងឬរដ្ឋលេខាធិការដ្ឋាន នៅទំព័រទី១៤។

**សូមមើលគំរូទី៦** : ទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតស្ថាប័ន ក្រោយពេលឆ្លងអង្គប្រជុំតាមនីតិវិធីដើម្បីផ្ញើទៅស្ថាប័ននីតិប្បញ្ញត្តិ នៅទំព័រទី១៥។

**សូមមើលគំរូទី៧** : ទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតស្ថាប័ន នៅទំព័រទី១៦។

**សូមមើលគំរូទី៨** : ទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ស្ថាប័ន ក្រោយពេលឆ្លងអង្គប្រជុំតាមនីតិវិធីដើម្បីផ្ញើទៅស្ថាប័ននីតិប្បញ្ញត្តិ នៅទំព័រទី១៧។

**សូមមើលគំរូទី៩** : ទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ស្ថាប័ន នៅទំព័រទី១៨។

**សូមមើលគំរូទី១០** : ទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឬលើលិខិតជានាទូទាត់របស់រាជរដ្ឋាភិបាល ឬក៏លើសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ ក្រោយពេលឆ្លងអង្គប្រជុំតាមនីតិវិធីដើម្បីផ្ញើទៅស្ថាប័ននីតិប្បញ្ញត្តិ នៅទំព័រទី១៩។

**សូមមើលគំរូទី១១** : ទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឬលើលិខិតជានាទូទាត់របស់រាជរដ្ឋាភិបាល ឬក៏លើសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ នៅទំព័រទី២០។

**គំរូទី១**

ទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ដែលត្រូវដាក់ឆ្លងអង្គប្រជុំជំនាញបច្ចេកទេស
អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យចុងក្រោយឬនីតិវិធីផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ
គណៈរដ្ឋមន្ត្រី និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីឬតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

(សញ្ញាក្រសួង ស្ថាប័ន)
**ក្រសួង**... (ឈ្មោះក្រសួង ស្ថាប័ន)

**សេចក្តីព្រាង**
**ច្បាប់**
**ស្តីពី**
(ចំណងជើងនៃសេចក្តីព្រាងច្បាប់ជាពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light)

**ថ្ងៃ... ខែ... ឆ្នាំ...**
(កាលបរិច្ឆេទចុងក្រោយបង្អស់នៃអត្ថបទដែលក្រសួង ស្ថាប័នសាមីបានរៀបចំ)

**គំរូទី២**

ទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ក្រោយពេលឆ្លងអង្គប្រជុំតាមនីតិវិធី
ដើម្បីផ្ញើទៅស្ថាប័ននីតិប្បញ្ញត្តិ

(សញ្ញាជាតិដូចមានក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**សេចក្តីព្រាង**

**ច្បាប់**

**ស្តីពី**

(ចំណងជើងនៃសេចក្តីព្រាងច្បាប់ជាពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light)

**បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ**
**នាថ្ងៃទី... ខែ... ឆ្នាំ...**

**គំរូទី៣**

ទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្តីព្រាងច្បាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

.............................................................................................................................................។

## ជំពូកទី២និងជំពូកបន្តបន្ទាប់

(ចំណងជើង)

**មាត្រា... .-**

.............................................................................................................................................។

## ជំពូកទី...

## បទប្បញ្ញត្តិដោយឡែក(ប្រសិនបើមាន)

**មាត្រា... .-**

.............................................................................................................................................។

## ជំពូកទី...

## សហាទិធាន(ប្រសិនបើមាន)

**មាត្រា... .-**

.............................................................................................................................................។

## ជំពូកទី...

## ទោសប្បញ្ញត្តិ

**មាត្រា... .-**

.............................................................................................................................................។

## ជំពូកទី...

## អន្តរប្បញ្ញត្តិ(ប្រសិនបើមាន)

**មាត្រា... .-**

.............................................................................................................................................។

## ជំពូកទី...

## អវសានប្បញ្ញត្តិ

**មាត្រា... .-**

ច្បាប់ស្តីពី... ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ... និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។(ករណីនិរាករណ៍ច្បាប់ចាស់) ឬ

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា... .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។(ក្នុងករណីដែលច្បាប់ត្រូវអនុវត្តជាប្រញាប់)

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី.......... ខែ.............. ឆ្នាំ..................
នាសម័យប្រជុំរដ្ឋសភាលើកទី... (ឬជាវិសាមញ្ញ) នីតិកាលទី...។
ថ្ងៃ........ ខែ......... ឆ្នាំ.......... .....ស័ក ព.ស. ..........
រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ.......... ឆ្នាំ..................

**ប្រធានរដ្ឋសភា**

**(ហត្ថលេខានិងឈ្មោះ)**

**គំរូទី៤**

ទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងឬរដ្ឋលេខាធិការដ្ឋាន
ក្រោយពេលឆ្លងអង្គប្រជុំតាមនីតិវិធីដើម្បីផ្ញើទៅស្ថាប័ននីតិប្បញ្ញត្តិ



(សញ្ញាជាតិដូចមានក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**សេចក្តីព្រាង**

**ច្បាប់**

**ស្តីពី**

**ការបង្កើតក្រសួង...(ឈ្មោះក្រសួង) ឬរដ្ឋលេខាធិការដ្ឋាន...(ឈ្មោះរដ្ឋលេខាធិការដ្ឋាន)**

(ពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light)

**បានឧទ្ទេសការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ**

**នាថ្ងៃទី... ខែ... ឆ្នាំ...**

**គំរូទី៥**

**ទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងឬរដ្ឋលេខាធិការដ្ឋាន**

**មាត្រា១ .-**

ត្រូវបានបង្កើតក្រសួង...(ឈ្មោះក្រសួង) ឬរដ្ឋលេខាធិការដ្ឋាន...(ឈ្មោះរដ្ឋលេខាធិការដ្ឋាន)។

**មាត្រា២ .-**

(ចែងអំពីសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រង...)។

**មាត្រា៣ .-**

(ចែងអំពីសមាសភាពដឹកនាំនិងគ្រប់គ្រង...)។

**មាត្រា៤ .-**

(ចែងអំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង... ឬរដ្ឋលេខាធិការដ្ឋាន... ដែលត្រូវកំណត់ដោយអនុក្រឹត្យ។)។

**មាត្រា...(មាត្រាបន្តបន្ទាប់) .-**

(ចែងអំពីអន្តរប្បញ្ញត្តិ (ប្រសិនបើមាន) អវសានប្បញ្ញត្តិ (បញ្ញត្តិនិរាករណ៍ និង/ឬ ការប្រកាសជាការប្រញាប់))។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី......... ខែ............ ឆ្នាំ................
នាសម័យប្រជុំរដ្ឋសភាលើកទី... (ឬជាវិសាមញ្ញ) នីតិកាលទី...។
ថ្ងៃ........ ខែ......... ឆ្នាំ......... .....ស័ក ព.ស. .........
រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ......... ឆ្នាំ............

**ប្រធានរដ្ឋសភា**

**(គោរមងារនិងឈ្មោះ)**

**គំរូទី៦**

ទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតស្ថាប័ន
ក្រោយពេលឆ្លងអង្គប្រជុំតាមនីតិវិធីដើម្បីផ្ញើទៅស្ថាប័ននីតិប្បញ្ញត្តិ

(សញ្ញាជាតិដូចមានក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**សេចក្តីព្រាង**

**ច្បាប់**

**ស្តីពី**

**ការបង្កើត...(ឈ្មោះស្ថាប័ន)...**(ក្នុងករណីដែលពុំទាន់បានបង្កើតដោយរដ្ឋធម្មនុញ្ញ)

(ពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light)

**បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ**
**នាថ្ងៃទី... ខែ... ឆ្នាំ...**

## គំរូទី៧
## ទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្ដីព្រាងច្បាប់ស្ដីពីការបង្កើតស្ថាប័ន

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើត...(ឈ្មោះស្ថាប័ន).........................................................................................។

## ជំពូកទី២និងជំពូកបន្តបន្ទាប់
(ចំណងជើង)

(អាចមានបេសកកម្ម តួនាទី ភារកិច្ច សមាសភាព ការប្រព្រឹត្តទៅ(...ការប្រើរូបសញ្ញានិងត្រា....)...)

(ចំពោះការបង្កើតអាជ្ញាធរ ក្រុមប្រឹក្សា គណៈកម្មាធិការ...ដែលស្ថិតក្នុងក្របខ័ណ្ឌនៃអង្គការនីតិប្រតិបត្តិ សមាសភាពត្រូវមានការចូលរួមពីតំណាងទីស្ដីការគណៈរដ្ឋមន្ត្រី)

**មាត្រា... .-**

..........................................................................................................................។

(ការរៀបចំនិងការប្រព្រឹត្តទៅអាចកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក)

## ជំពូកទី...
## ប្រភពធនធាន

**មាត្រា... .-**

..........................................................................................................................។

## ជំពូកទី...
## អន្តរប្បញ្ញត្តិ (ប្រសិនបើមាន)

**មាត្រា... .-**

..........................................................................................................................។

## ជំពូកទី...
## អវសានប្បញ្ញត្តិ

**មាត្រា... .-**

ច្បាប់ស្ដីពី... ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ... និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។(ករណីនិរាករណ៍ច្បាប់ចាស់) ឬ

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា... .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។ (ក្នុងករណីដែលច្បាប់ត្រូវអនុវត្តជាប្រញាប់)

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី.......... ខែ.......... ឆ្នាំ..........
នាសម័យប្រជុំរដ្ឋសភាលើកទី... (ឬជាវិសាមញ្ញ) នីតិកាលទី...។
ថ្ងៃ........ ខែ......... ឆ្នាំ......... ......ស័ក ព.ស..........
រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ.......... ឆ្នាំ..........

**ប្រធានរដ្ឋសភា**

(**ត្រា មហត្ថលេខា និងឈ្មោះ**)

**គំរូទី៨**

**ទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ស្ថាប័ន ក្រោយពេលឆ្លងអង្គប្រជុំតាមនីតិវិធីដើម្បីផ្ញើទៅស្ថាប័ននីតិប្បញ្ញត្តិ**



(សញ្ញាជាតិដូចមានក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**សេចក្តីព្រាង**

**ច្បាប់**

**ស្តីពី**

**ការរៀបចំនិងការប្រព្រឹត្តទៅរបស់...(ឈ្មោះស្ថាប័ន)**

(ក្នុងករណីដែលបានបង្កើតដោយរដ្ឋធម្មនុញ្ញរួចហើយ)

(ពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light)

**បានឧទ្ទូលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ**

**នាថ្ងៃទី... ខែ... ឆ្នាំ...**

## គំរូទី៩

### ទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ស្ថាប័ន

(ក្នុងករណីដែលបានបង្កើតដោយរដ្ឋធម្មនុញ្ញរួចហើយ)

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់...(ឈ្មោះស្ថាប័ន)។

**ជំពូកទី២**និង**ជំពូក**បន្តបន្ទាប់

(ចំណងជើង)

(អាចមានបេសកកម្ម តួនាទី ភារកិច្ច សមាសភាព ការប្រព្រឹត្តទៅ(...ការប្រើរូបសញ្ញានិងត្រា....)...)

(ចំពោះស្ថាប័នដែលស្ថិតក្នុងក្របខ័ណ្ឌនៃអង្គការនីតិប្រតិបត្តិ សមាសភាពត្រូវមានការចូលរួមពីតំណាងទីស្តីការគណៈរដ្ឋមន្ត្រី)

**មាត្រា... .-**

.............................................................................................................។

## ជំពូកទី...

## ប្រភពធនធាន

**មាត្រា... .-**

.............................................................................................................។

## ជំពូកទី...

## **អន្តរប្បញ្ញត្តិ**(ប្រសិនបើមាន)

**មាត្រា... .-**

.............................................................................................................។

## ជំពូកទី...

## អវសានប្បញ្ញត្តិ

**មាត្រា... .-**

ច្បាប់ស្តីពី... ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ... និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។(ករណីនិរាករណ៍ច្បាប់ចាស់) ឬ

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា... .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។(ក្នុងករណីដែលច្បាប់ត្រូវអនុវត្តជាប្រញាប់)

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី.......... ខែ.............. ឆ្នាំ..............
នាសម័យប្រជុំរដ្ឋសភាលើកទី... (ឬជាវិសាមញ្ញ) នីតិកាលទី...។
ថ្ងៃ........ ខែ......... ឆ្នាំ.............. ស័ក ព.ស. ..........
រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ.......... ឆ្នាំ..............

**ប្រធានរដ្ឋសភា**

**(ហត្ថលេខានិងឈ្មោះ)**

**គំរូទី១០**

ទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រ
អភិវឌ្ឍន៍ជាតិ ឬលើលិខិតធានាទូទាត់របស់រាជរដ្ឋាភិបាល ឬក៏លើសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ...
ក្រោយពេលឆ្លងអង្គប្រជុំតាមនីតិវិធីដើម្បីផ្ញើទៅស្ថាប័ននីតិប្បញ្ញត្តិ

(សញ្ញាជាតិដូចមានក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**សេចក្ដីព្រាង**

**ច្បាប់**

**ស្ដីពី**

**ការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឬលើលិខិតធានាទូទាត់**
**របស់រាជរដ្ឋាភិបាល ឬក៏លើសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ...**

(ពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light)

**បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ**
**នាថ្ងៃទី... ខែ... ឆ្នាំ...**

## គំរូទី១១

### ទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឬលើលិខិតជានាទូទាត់របស់រាជរដ្ឋាភិបាល ឬក៏លើសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ...

**មាត្រា១ .-**

អនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឬលើលិខិតជានាទូទាត់របស់រាជរដ្ឋាភិបាល ឬក៏លើសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ... (បញ្ជាក់ទីកន្លែងនិងកាលបរិច្ឆេទដែលបានចុះហត្ថលេខា) ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២ .-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឬលើលិខិតជានាទូទាត់របស់រាជរដ្ឋាភិបាល ឬក៏លើសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ...នេះ។

**មាត្រា៣ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់(ប្រសិនបើមាន)។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី......... ខែ............ ឆ្នាំ................
នាសម័យប្រជុំរដ្ឋសភាលើកទី... (ឬជាវិសាមញ្ញ) នីតិកាលទី...។
ថ្ងៃ........ ខែ......... ឆ្នាំ......... .....ស័ក ព.ស. .........
រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ.......... ឆ្នាំ............

**ប្រធានរដ្ឋសភា**
**(ហត្ថលេខានិងឈ្មោះ)**

### ៣.២.២- ទម្រង់នៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់

ក- ក្របសន្លឹកទំព័រដំបូង

ក.១- ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ដែលត្រូវដាក់ឆ្លងអង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យចុងក្រោយឬនីតិវិធីផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីឬតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី ក្រសួង ស្ថាប័នសាមីត្រូវប្រើក្រដាសក្បាលលិខិតរបស់ក្រសួង ស្ថាប័ន ហើយនៅចំកណ្តាលសន្លឹកទំព័រនេះ ត្រូវដាក់ពាក្យ **សេចក្តីព្រាង** ក្រោមពាក្យសេចក្តីព្រាង ចំកណ្តាលដាក់ពាក្យ **ច្បាប់** ក្រោមពាក្យច្បាប់ ដាក់ពាក្យ **ស្តីពី** ក្រោមពាក្យស្តីពី ដាក់ពាក្យ **វិសោធនកម្មច្បាប់ស្តីពី** ក្រោមពាក្យវិសោធនកម្មច្បាប់ស្តីពី ដាក់ចំណងជើងច្បាប់ដំបូងដែលត្រូវធ្វើវិសោធនកម្ម។ ចំពោះចំណងជើងនៃសេចក្តីព្រាងច្បាប់ដែលធ្វើវិសោធនកម្មច្បាប់ដំបូងជាបន្តបន្ទាប់ ត្រូវដាក់ចំណងជើងថា **សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី**...(ចំណងជើងច្បាប់ដំបូង)ដដែល ពីព្រោះទោះបីជាមានវិសោធនកម្មប៉ុន្មានដងក៏ដោយ ក៏ត្រូវបានបកស្រាយថាជាច្បាប់តែមួយ ដូចករណីវិសោធនកម្មរដ្ឋធម្មនុញ្ញច្រើនដងដែរ។ នៅប៉ែកខាងក្រោមនៃទំព័រ ត្រូវដាក់កាលបរិច្ឆេទចុងក្រោយបង្អស់ដែលក្រសួង ស្ថាប័នបានរៀបចំ។

**សូមមើលគំរូទី១២** : ទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ដែលត្រូវដាក់ឆ្លងអង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យចុងក្រោយឬនីតិវិធីផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីឬតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី នៅទំព័រទី២៣។

ក.២- ចំពោះក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ក្រោយពេលឆ្លងអង្គប្រជុំតាមនីតិវិធីរួចហើយដើម្បីផ្ញើទៅស្ថាប័ននីតិប្បញ្ញត្តិ ក្រសួង ស្ថាប័នសាមីត្រូវប្រើក្រដាសក្បាលលិខិតរបស់រាជរដ្ឋាភិបាលដែលមិនមានលេខ។ នៅប៉ែកខាងក្រោមនៃទំព័រ ត្រូវដាក់ថា **បានឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី... ខែ... ឆ្នាំ...។**

**សូមមើលគំរូទី១៣** : ទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ក្រោយពេលឆ្លងអង្គប្រជុំតាមនីតិវិធីដើម្បីផ្ញើទៅស្ថាប័ននីតិប្បញ្ញត្តិ នៅទំព័រទី២៤។

ខ- សន្លឹកទំព័របន្តបន្ទាប់

ខ.១- ជាទូទៅ សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់អាចមានរូបភាព២៖

- ចំពោះវិសោធនកម្មច្បាប់ដែលត្រូវប្រកាសជាការប្រញាប់ ក្រសួង ស្ថាប័នសាមីត្រូវរៀបចំចំណងជើងដោយដាក់ថា **សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី**... (ចំណងជើងច្បាប់ដំបូង) ហើយនៅក្រោមចំណងជើងច្បាប់ រំលង១បន្ទាត់ ត្រូវសរសេរ **មាត្រាមួយ** ក្នុងនោះ ត្រូវចែងមាត្រាថ្មីដែលកែប្រែខ្លឹមសារមាត្រាចាស់និង/ឬមាត្រាស្ទួន ដោយដាក់ស្មើនឹងមាត្រាមួយដែរ។ សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មនេះ ជាទូទៅមាន២មាត្រា។

**សូមមើលគំរូទី១៤** : ទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ដែលត្រូវប្រកាសជាការប្រញាប់ នៅទំព័រទី២៥ដល់ទំព័រទី២៦។

- ចំពោះវិសោធនកម្មច្បាប់ដែលមិនត្រូវប្រកាសជាការប្រញាប់ មានតែមួយមាត្រាដែលដាក់ថា **មាត្រាតែមួយ .-** (ចែងអំពីមាត្រាដែលត្រូវធ្វើវិសោធនកម្ម)។

**សូមមើលគំរូទី១៥** : ទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ដែលមិនត្រូវប្រកាសជាការប្រញាប់ នៅទំព័រទី២៧។

ខ.២- ក្នុងករណីមានការកែប្រែខ្លឹមសារផងនិងមានការប្តូរលេខរៀងរបស់មាត្រាផង ត្រូវរៀបចំ៖

- មាត្រាថ្មីដែលមានការកែប្រែឬការបញ្ចូលបន្ថែមខ្លឹមសារ ត្រូវដាក់ថា **មាត្រា**...(លេខរបស់មាត្រា) **.- ថ្មី**
- មាត្រាថ្មីដែលបានយកមាត្រាចាស់មកប្តូរលេខរៀងនិងមានការកែប្រែឬការបញ្ចូលបន្ថែមខ្លឹមសារ ត្រូវដាក់ថា **មាត្រា**...(លេខរបស់មាត្រាថ្មី) **.- ថ្មី**

- មាត្រាថ្មីដែលគ្រាន់តែយកមាត្រាចាស់មកប្តូរលេខរៀង ត្រូវដាក់ថា **មាត្រា...**(លេខរបស់មាត្រា) **-- ថ្មី** (មាត្រា...(លេខរបស់មាត្រា)ចាស់)

ឧទាហរណ៍ : នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា **មាត្រា១២២ -- ថ្មី (មាត្រា១០៣ ចាស់)**។

- មាត្រាបន្ថែមថ្មីពោលគឺមាត្រាស្ទួន ត្រូវដាក់លេខរៀងស្ទួនដែលមានទម្រង់ : **មាត្រា...**(លេខរបស់មាត្រាដែលត្រូវស្ទួន) **-- ស្ទួន**លេខលំដាប់ស្ទួន។

**សេចក្តីពន្យល់៖**

+ លេខរៀងស្ទួន ត្រូវយកលេខរបស់មាត្រាដែលត្រូវស្ទួនមកប្រើ
+ ពាក្យសម្គាល់លំដាប់ស្ទួន ត្រូវប្រើពាក្យថា «ស្ទួន» សម្រាប់មាត្រាដែលត្រូវស្ទួនដំបូង ហើយត្រូវប្រើទម្រង់ «ស្ទួនលេខលំដាប់ស្ទួនសរសេរជាអក្សរ» សម្រាប់មាត្រាដែលត្រូវស្ទួនបន្តបន្ទាប់ ទោះជាបន្ថែមម្តងមួយក្តី បន្ថែមព្រមគ្នាក្តី។

ឧទាហរណ៍៖

- មាត្រាបន្ថែមថ្មីស្ទួនដំបូង(មាត្រាស្ទួននឹងមាត្រា៤) ត្រូវដាក់ថា «**មាត្រា៤ -- ស្ទួន**»
- បើមាត្រា៤នេះត្រូវស្ទួនជាលើកទី២ លើកទី៣ ... ត្រូវដាក់ថា «**មាត្រា៤ -- ស្ទួនមួយ**» «**មាត្រា៤ -- ស្ទួនពីរ**» ...
- មាត្រាបន្ថែមថ្មីដែលស្ទួនច្រើនដងព្រមគ្នាត្រូវសរសេរថា «**មាត្រា៤ -- ស្ទួន**» «**មាត្រា៤ -- ស្ទួនមួយ**» និង «**មាត្រា៤ -- ស្ទួនពីរ**» ...

ខ.៣- ចំពោះការធ្វើវិសោធនកម្មមាត្រាណាមួយចំនួនពីរលើក ត្រូវដាក់ថា **មាត្រា...**(លេខរបស់មាត្រា) **-- ថ្មី(មួយ)** ហើយបើមានការធ្វើវិសោធនកម្មចំនួនបីលើកឡើងទៅ ត្រូវដាក់ថា **មាត្រា...**(លេខរបស់មាត្រា) **-- ថ្មី(ពីរ) មាត្រា...**(លេខរបស់មាត្រា) **-- ថ្មី(បី) មាត្រា...**(លេខរបស់មាត្រា) **-- ថ្មី(បួន)** ឬ **មាត្រា...**(លេខរបស់មាត្រា) **-- ថ្មី(...)**។

ខ.៤- ចំពោះការធ្វើវិសោធនកម្មមាត្រាស្ទួន : ករណីធ្វើវិសោធនកម្មលើកទី១ ត្រូវដាក់ថា **មាត្រា...ស្ទួន(ថ្មី)** ករណីធ្វើវិសោធនកម្មលើកទី២ ត្រូវដាក់ថា **មាត្រា...ស្ទួន(ថ្មីមួយ)**។

ខ.៥- ចំពោះការធ្វើវិសោធនកម្មលើមាត្រាដែលបានធ្វើវិសោធនកម្មនិងត្រូវបានស្ទួន : ករណីធ្វើវិសោធនកម្មលើកទី១ ត្រូវដាក់ថា **មាត្រា...ថ្មីស្ទួន(ថ្មី)** ករណីធ្វើវិសោធនកម្មលើកទី២ ត្រូវដាក់ថា **មាត្រា...ថ្មីស្ទួន(ថ្មីមួយ)**។

ខ.៦- ចំពោះការធ្វើវិសោធនកម្មច្បាប់ណាមួយក្នុងករណីមាននិរាករណ៍ និង/ឬធ្វើវិសោធនកម្ម និង/ឬបន្ថែមមាត្រាស្ទួនត្រូវអនុវត្តតាម**គំរូទី១៦** នៅទំព័រទី២៨(ដែលត្រូវប្រកាសជាការប្រញាប់) និង**គំរូទី១៧** នៅទំព័រទី២៩(ដែលមិនត្រូវប្រកាសជាការប្រញាប់)។

**គំរូទី១២**

ទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្ដីព្រាងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ដែលត្រូវដាក់ឆ្លង
អង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យចុងក្រោយឬនីតិវិធីផ្សេងទៀតតាមការសម្រេច
របស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីឬតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

(សញ្ញាក្រសួង ស្ថាប័ន)
**ក្រសួង**...(ឈ្មោះក្រសួង ស្ថាប័ន)

**សេចក្ដីព្រាង**
**ច្បាប់**
**ស្ដីពី**
**វិសោធនកម្មច្បាប់ស្ដីពី...**
(ចំណងជើងនៃច្បាប់ដំបូងដែលត្រូវធ្វើវិសោធនកម្ម)
(ពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light)

**ថ្ងៃទី... ខែ... ឆ្នាំ...**
(កាលបរិច្ឆេទចុងក្រោយបង្អស់នៃអត្ថបទដែលក្រសួង ស្ថាប័នសាមីបានរៀបចំ)

**គំរូទី១៣**

ទម្រង់ក្របសន្លឹកទំព័រដំបូងនៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ក្រោយពេលឆ្លង
អង្គប្រជុំតាមនីតិវិធីដើម្បីផ្ញើទៅស្ថាប័ននីតិប្បញ្ញត្តិ

(សញ្ញាជាតិដូចមានក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**សេចក្តីព្រាង**

**ច្បាប់**

**ស្តីពី**

**វិសោធនកម្មច្បាប់ស្តីពី...**

(ចំណងជើងនៃច្បាប់ដំបូងដែលត្រូវធ្វើវិសោធនកម្ម)

(ពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light)

**បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ**
**នាថ្ងៃទី... ខែ... ឆ្នាំ...**

**គំរូទី១៤**

**ទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ដែលត្រូវ**
**ប្រកាសជាការប្រញាប់**

**មាត្រាមួយ ._**

មាត្រា...(លេខមាត្រាដែលត្រូវធ្វើវិសោធនកម្ម)នៃច្បាប់ស្តីពី...(ចំណងជើងនៃច្បាប់ដែលត្រូវធ្វើវិសោធនកម្ម) ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ.../រកម/.../... ចុះថ្ងៃទី... ខែ... ឆ្នាំ... ត្រូវបានធ្វើវិសោធនកម្មដូចតទៅ៖ (ក្នុងករណីសេចក្តីព្រាងច្បាប់សម្រាប់វិសោធនកម្មលើកដំបូង) ឬ

មាត្រា...(លេខមាត្រាដែលត្រូវធ្វើវិសោធនកម្ម : មាត្រាដើម និងមាត្រាដែលបានធ្វើវិសោធនកម្ម ហើយត្រូវយកមកធ្វើវិសោធនកម្មក្នុងច្បាប់នេះ)នៃច្បាប់ស្តីពី...(ចំណងជើងនៃច្បាប់ដំបូងដែលត្រូវធ្វើវិសោធនកម្ម) ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ.../រកម/.../... ចុះថ្ងៃទី... ខែ... ឆ្នាំ... ត្រូវបានធ្វើវិសោធនកម្មដូចតទៅ៖

**មាត្រា**...(លេខមាត្រាដែលត្រូវធ្វើវិសោធនកម្ម) **._ ថ្មី**

..............................................................................................................................។

ឬ

**មាត្រាមួយ ._**

ច្បាប់ស្តីពី...(ចំណងជើងនៃច្បាប់ដែលត្រូវធ្វើវិសោធនកម្ម)ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ... /រកម/.../... ចុះថ្ងៃទី... ខែ... ឆ្នាំ... ត្រូវបានធ្វើវិសោធនកម្មដោយបន្ថែមមាត្រា...(លេខមាត្រា)ស្ទួន ដូចតទៅ៖ (ក្នុងករណីសេចក្តីព្រាងច្បាប់សម្រាប់បន្ថែមមាត្រាស្ទួន)

**មាត្រា**...(លេខមាត្រា) **._ ស្ទួន**

........................................................................................................................។

កំណត់សម្គាល់ : ក្នុងករណីមានការធ្វើវិសោធនកម្មមាត្រាចាស់ផង មានការបន្ថែមមាត្រាស្ទួនផង មាត្រាមួយ ត្រូវសរសេរដូចខាងក្រោម ហើយមាត្រាដែលត្រូវធ្វើវិសោធនកម្មនិងបន្ថែមត្រូវវាយតាមលំដាប់លេខរៀង៖

**មាត្រាមួយ ._**

ច្បាប់ស្តីពី... (ចំណងជើងនៃច្បាប់ដែលត្រូវធ្វើវិសោធនកម្ម)ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ... /រកម/.../... ចុះថ្ងៃទី... ខែ... ឆ្នាំ... ត្រូវបានធ្វើវិសោធនកម្មដោយកែប្រែមាត្រា...(លេខមាត្រាដែលត្រូវកែប្រែ) និងបន្ថែមមាត្រា...(លេខមាត្រា)ស្ទួន ដូចតទៅ៖

**មាត្រា**...(លេខមាត្រាដែលត្រូវធ្វើវិសោធនកម្ម) **._ ថ្មី**

.........................................................................................................................។

**មាត្រា**...(លេខមាត្រា) **._ ស្ទួន**

.........................................................................................................................។

**មាត្រាពីរ ._**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី.......... ខែ............ ឆ្នាំ................
នាសម័យប្រជុំរដ្ឋសភាលើកទី... (ឬជាវិសាមញ្ញ) នីតិកាលទី...។
ថ្ងៃ........ ខែ......... ឆ្នាំ......... .....ស័ក ព.ស. .........
រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ.......... ឆ្នាំ............

**ប្រធានរដ្ឋសភា**
(**ហត្ថលេខានិងឈ្មោះ**)

## គំរូទី១៥

## ទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ដែលមិនត្រូវប្រកាសជាការប្រញាប់

**មាត្រាតែមួយ .-**

មាត្រា...(លេខមាត្រាដែលត្រូវធ្វើវិសោធនកម្ម)នៃច្បាប់ស្តីពី...(ចំណងជើងនៃច្បាប់ដែលត្រូវធ្វើវិសោធនកម្ម) ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ.../រកម/.../... ចុះថ្ងៃទី... ខែ... ឆ្នាំ... ត្រូវបានធ្វើវិសោធនកម្មដូចតទៅ៖ (ក្នុងករណីសេចក្តីព្រាងច្បាប់សម្រាប់វិសោធនកម្មលើកដំបូង) ឬ

មាត្រា...(លេខមាត្រាដែលត្រូវធ្វើវិសោធនកម្ម : មាត្រាដើម និងមាត្រាដែលបានធ្វើវិសោធនកម្ម ហើយត្រូវយកមកធ្វើវិសោធនកម្មក្នុងច្បាប់នេះ)នៃច្បាប់ស្តីពី...(ចំណងជើងនៃច្បាប់ដំបូងដែលត្រូវធ្វើវិសោធនកម្ម) ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ.../រកម/.../... ចុះថ្ងៃទី... ខែ... ឆ្នាំ... ត្រូវបានធ្វើវិសោធនកម្មដូចតទៅ៖

**មាត្រា**...(លេខមាត្រាដែលត្រូវធ្វើវិសោធនកម្ម) **.- ថ្មី**

.......................................................................................................................................។

ឬ

**មាត្រាតែមួយ .-**

ច្បាប់ស្តីពី...(ចំណងជើងនៃច្បាប់ដែលត្រូវធ្វើវិសោធនកម្ម)ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ.../រកម/.../... ចុះថ្ងៃទី... ខែ... ឆ្នាំ... ត្រូវបានធ្វើវិសោធនកម្មដោយបន្ថែមមាត្រា...(លេខមាត្រា)ស្ទួន ដូចតទៅ៖ (ក្នុងករណីសេចក្តីព្រាងច្បាប់សម្រាប់បន្ថែមមាត្រាស្ទួន)

**មាត្រា**...(លេខមាត្រា) **.- ស្ទួន**

..............................................................................................................................។

**កំណត់សម្គាល់** : ក្នុងករណីមានការធ្វើវិសោធនកម្មមាត្រាចាស់ផង មានការបន្ថែមមាត្រាស្ទួនផង មាត្រាមួយ ត្រូវសរសេរដូចខាងក្រោម ហើយមាត្រាដែលត្រូវធ្វើវិសោធនកម្មនិងបន្ថែមត្រូវរាយតាមលំដាប់លេខរៀង៖

**មាត្រាតែមួយ .-**

ច្បាប់ស្តីពី... (ចំណងជើងនៃច្បាប់ដែលត្រូវធ្វើវិសោធនកម្ម)ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ.../រកម/.../... ចុះថ្ងៃទី... ខែ... ឆ្នាំ... ត្រូវបានធ្វើវិសោធនកម្មដោយកែប្រែមាត្រា...(លេខមាត្រាដែលត្រូវកែប្រែ) និងបន្ថែមមាត្រា...(លេខមាត្រា)ស្ទួន ដូចតទៅ៖

**មាត្រា**...(លេខមាត្រាដែលត្រូវធ្វើវិសោធនកម្ម) **.- ថ្មី**

..............................................................................................................................។

**មាត្រា**...(លេខមាត្រា) **.- ស្ទួន**

..............................................................................................................................។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី.......... ខែ.......... ឆ្នាំ..........
នាសម័យប្រជុំរដ្ឋសភាលើកទី... (ឬជាវិសាមញ្ញ) នីតិកាលទី...។
ថ្ងៃ........ ខែ......... ឆ្នាំ.......... ស័ក ព.ស.........
រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ.......... ឆ្នាំ..........

**ប្រធានរដ្ឋសភា**

**(ត្រាមហោរនិងឈ្មោះ)**

**គំរូទី១៦**

**ទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់**
**ក្នុងករណីមាននិរាករណ៍ និង/ឬធ្វើវិសោធនកម្ម និង/ឬបន្ថែមមាត្រាស្ទួន**
**ដែលត្រូវប្រកាសជាការប្រញាប់**

**មាត្រាមួយ .-**

ច្បាប់ស្តីពី...(ចំណងជើងនៃច្បាប់ដែលត្រូវធ្វើវិសោធនកម្ម)ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ.../រកម/.../... ចុះថ្ងៃទី... ខែ... ឆ្នាំ... ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម៖

- ដោយធ្វើនិរាករណ៍ ជំពូក... ផ្នែក... មាត្រា... (លេខជំពូកទី ផ្នែកទី មាត្រា ដែលត្រូវនិរាករណ៍) និង/ឬ
- ដោយកែប្រែ ជំពូក... ផ្នែក... មាត្រា... (លេខជំពូកទី ផ្នែកទី មាត្រា ដែលត្រូវធ្វើវិសោធនកម្ម) និង/ឬ
- ដោយបន្ថែមមាត្រា...(លេខមាត្រា)ស្ទួន ក្នុងជំពូកទី... ដូចតទៅ៖

**ជំពូកទី**...(លេខជំពូកដែលត្រូវធ្វើវិសោធនកម្ម) **ថ្មី**
(ចំណងជើងជំពូកថ្មីដែលត្រូវដាក់បញ្ចូល) និង/ឬ
**ផ្នែកទី**... (លេខផ្នែកដែលត្រូវធ្វើវិសោធនកម្ម) **ថ្មី**
(ចំណងជើងផ្នែកថ្មីដែលត្រូវដាក់បញ្ចូល) និង/ឬ

**មាត្រា**...(លេខមាត្រាដែលត្រូវធ្វើវិសោធនកម្ម) **.- ថ្មី**

........................................................................................................................។

**មាត្រា**...(លេខមាត្រា) **.- ស្ទួន**

........................................................................................................................។

**មាត្រាពីរ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី.......... ខែ............ ឆ្នាំ.................
នាសម័យប្រជុំរដ្ឋសភាលើកទី... (ឬជាវិសាមញ្ញ) នីតិកាលទី...។
ថ្ងៃ........ ខែ......... ឆ្នាំ......... .....ស័ក ព.ស. .........
រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ.......... ឆ្នាំ............

**ប្រធានរដ្ឋសភា**
**(ហត្ថលេខានិងឈ្មោះ)**

**គំរូទី១៧**

**ទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃសេចក្ដីព្រាងច្បាប់ស្ដីពីវិសោធនកម្មច្បាប់**
**ក្នុងករណីមាននិរាករណ៍ និង/ឬធ្វើវិសោធនកម្ម និង/ឬបន្ថែមមាត្រាស្ទួន**
**ដែលមិនត្រូវប្រកាសជាការប្រញាប់**

**មាត្រាតែមួយ .-**

ច្បាប់ស្ដីពី...(ចំណងជើងនៃច្បាប់ដែលត្រូវធ្វើវិសោធនកម្ម)ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ.../រកម/.../... ចុះថ្ងៃទី... ខែ... ឆ្នាំ... ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម៖

- ដោយធ្វើនិរាករណ៍ ជំពូក... ផ្នែក... មាត្រា... (លេខជំពូកទី ផ្នែកទី មាត្រា ដែលត្រូវនិរាករណ៍) **និង/ឬ**
- ដោយកែប្រែ ជំពូក... ផ្នែក... មាត្រា... (លេខជំពូកទី ផ្នែកទី មាត្រា ដែលត្រូវធ្វើវិសោធនកម្ម) **និង/ឬ**
- ដោយបន្ថែមមាត្រា...(លេខមាត្រា)ស្ទួន ក្នុងជំពូកទី... ដូចតទៅ៖

**ជំពូកទី**... (លេខជំពូកដែលត្រូវធ្វើវិសោធនកម្ម) **ថ្មី**
(ចំណងជើងជំពូកថ្មីដែលត្រូវដាក់បញ្ចូល) **និង/ឬ**
**ផ្នែកទី**... (លេខផ្នែកដែលត្រូវធ្វើវិសោធនកម្ម) **ថ្មី**
(ចំណងជើងផ្នែកថ្មីដែលត្រូវដាក់បញ្ចូល) **និង/ឬ**

**មាត្រា**...(លេខមាត្រាដែលត្រូវធ្វើវិសោធនកម្ម) **.- ថ្មី**

.........................................................................................................................................។

**មាត្រា**...(លេខមាត្រា) **.- ស្ទួន**

.........................................................................................................................................។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី.......... ខែ............ ឆ្នាំ................
នាសម័យប្រជុំរដ្ឋសភាលើកទី... (ឬជាវិសាមញ្ញ) នីតិកាលទី...។
ថ្ងៃ........ ខែ......... ឆ្នាំ......... .....ស័ក ព.ស. .........
រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ.......... ឆ្នាំ............

**ប្រធានរដ្ឋសភា**
**(ហត្ថលេខានិងឈ្មោះ)**

### ៣.២.៣- ទម្រង់នៃអនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្តីស្នើច្បាប់

ក្នុងករណីមានសំណើពីរដ្ឋសភាឬព្រឹទ្ធសភាសុំឱ្យរាជរដ្ឋាភិបាលផ្តល់អនុសាសន៍លើសេចក្តីស្នើច្បាប់ ការផ្តល់អនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្តីស្នើច្បាប់ត្រូវធ្វើតាមចំណុចនីមួយៗលើចំណងជើងច្បាប់ ចំណងជើងគន្ថី ចំណងជើងមាតិកា ចំណងជើងជំពូក ចំណងជើងផ្នែក ចំណងជើងអនុផ្នែកឬកថាភាគ និងលើខ្លឹមសារតាមមាត្រា ដោយត្រូវចម្លងខ្លឹមសារដើម ហើយនៅខាងក្រោមដាក់អនុសាសន៍របស់រាជរដ្ឋាភិបាល។

ការផ្តល់អនុសាសន៍ត្រូវអនុវត្តតាមលំដាប់ដូចតទៅៈ

- ការផ្តល់អនុសាសន៍របស់ក្រសួង ស្ថាប័នជំនាញ
- ការពិនិត្យរបស់អង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យចុងក្រោយឬនីតិវិធីផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីឬតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី លើការផ្តល់អនុសាសន៍របស់ក្រសួង ស្ថាប័នជំនាញ
- ការផ្តល់អនុសាសន៍ក្នុងនាមរាជរដ្ឋាភិបាល បន្ទាប់ពីការពិនិត្យរបស់អង្គប្រជុំតាមនីតិវិធី។

**ក- ទម្រង់នៃអនុសាសន៍របស់ក្រសួង ស្ថាប័នជំនាញទទួលបន្ទុកពិនិត្យនិងផ្តល់យោបល់**

ក្រសួង ស្ថាប័នជំនាញទទួលបន្ទុកពិនិត្យនិងផ្តល់យោបល់ ក្រោយពីបានពិនិត្យនិងសិក្សាលើសេចក្តីស្នើច្បាប់រួចហើយ ត្រូវបញ្ជូនមតិយោបល់របស់ខ្លួនជូននាយករដ្ឋមន្ត្រី ដោយត្រូវមានលិខិតបញ្ជូនអត្ថបទនៃការផ្តល់អនុសាសន៍លើសេចក្តីស្នើច្បាប់ ដែលចុះហត្ថលេខាដោយរដ្ឋមន្ត្រីឬប្រធានស្ថាប័នទៅទីស្តីការគណៈរដ្ឋមន្ត្រី។

**សូមមើលគំរូទី១៨** : ទម្រង់ក្របសន្លឹកទំព័រដំបូងនៃអនុសាសន៍របស់ក្រសួង ស្ថាប័នលើសេចក្តីស្នើច្បាប់ នៅទំព័រទី៣១។

**សូមមើលគំរូទី១៩** : ទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃអនុសាសន៍របស់ក្រសួង ស្ថាប័នលើសេចក្តីស្នើច្បាប់ នៅទំព័រទី៣២។

**ខ- ទម្រង់នៃការផ្តល់អនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្តីស្នើច្បាប់ ក្រោយការរួមយោបល់របស់អង្គប្រជុំតាមនីតិវិធីដែលទីស្តីការគណៈរដ្ឋមន្ត្រីត្រូវរៀបចំបញ្ជូនទៅស្ថាប័ននីតិប្បញ្ញត្តិ**

ក្រោយពីបានទទួលសេចក្តីព្រាងអនុសាសន៍របស់ក្រសួង ស្ថាប័នជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រីត្រូវរៀបចំដាក់សេចក្តីព្រាងអនុសាសន៍នេះជូនអង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង និងអង្គប្រជុំត្រួតពិនិត្យចុងក្រោយឬនីតិវិធីផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនិងផ្តល់យោបល់ និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីឬតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី។ ឯទម្រង់នៃសេចក្តីព្រាងអត្ថបទស្តីពីការផ្តល់អនុសាសន៍ដើម្បីដាក់ជូននាយករដ្ឋមន្ត្រីសម្រេចនិងផ្ញើទៅស្ថាប័ននីតិប្បញ្ញត្តិ ក៏ត្រូវបានកែសម្រួលឡើងវិញដែរ។

**សូមមើលគំរូទី២០** : ទម្រង់ក្របសន្លឹកទំព័រដំបូងនៃអនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្តីស្នើច្បាប់ នៅទំព័រទី៣៣។

**សូមមើលគំរូទី២១** : ទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃអនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្តីស្នើច្បាប់ នៅទំព័រទី៣៤។

**គំរូទី១៨**

ទម្រង់ក្របសន្លឹកទំព័រដំបូងនៃអនុសាសន៍របស់ក្រសួង ស្ថាប័នលើសេចក្តីស្នើច្បាប់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

( សញ្ញាក្រសួង ស្ថាប័ន )

**ក្រសួង**... ( ឈ្មោះក្រសួង ស្ថាប័ន )

**អនុសាសន៍លើសេចក្តីស្នើ**

**ច្បាប់**

**ស្តីពី**

( ចំណងជើងនៃសេចក្តីស្នើច្បាប់ជាពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light )

**ដែលរៀបចំដោយគណៈកម្មការទី...នៃរដ្ឋសភាឬព្រឹទ្ធសភា**

**អនុសាសន៍លើចំណងជើងនៃសេចក្តីស្នើច្បាប់**

( ចំណងជើងដែលក្រសួង ស្ថាប័នផ្តល់អនុសាសន៍កែសម្រួល )

## គំរូទី១៩

## ទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃអនុសាសន៍របស់ក្រសួង ស្ថាប័នលើសេចក្ដីស្នើច្បាប់

## **ជំពូកទី១**

## **បទប្បញ្ញត្តិទូទៅ**

**មាត្រា១ .-**

..........................................ខ្លឹមសារដើមរបស់សេចក្ដីស្នើច្បាប់......................................។

**អនុសាសន៍របស់...(ឈ្មោះក្រសួង ស្ថាប័ន)**

ខ្លឹមសារទាំងស្រុងដែលក្រសួង ស្ថាប័នផ្ដល់អនុសាសន៍។

**ជំពូកទី២**និង**ជំពូក**បន្តបន្ទាប់

(ចំណងជើង)

**មាត្រា... .-**

...................................ខ្លឹមសារដើមរបស់សេចក្ដីស្នើច្បាប់.............................................។

**អនុសាសន៍របស់...(ឈ្មោះក្រសួង ស្ថាប័ន)**

ខ្លឹមសារទាំងស្រុងដែលក្រសួង ស្ថាប័នផ្ដល់អនុសាសន៍។

**ជំពូកទី...**

**អន្តរប្បញ្ញត្តិ**(ប្រសិនបើមាន)

**មាត្រា... .-**

...................................ខ្លឹមសារដើមរបស់សេចក្ដីស្នើច្បាប់..............................................។

**អនុសាសន៍របស់...(ឈ្មោះក្រសួង ស្ថាប័ន)**

ខ្លឹមសារទាំងស្រុងដែលក្រសួង ស្ថាប័នផ្ដល់អនុសាសន៍។

**ជំពូកទី...**

**អវសានប្បញ្ញត្តិ**

**មាត្រា... .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា... .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។(ក្នុងករណីដែលច្បាប់ត្រូវអនុវត្តជាប្រញាប់)

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី.......... ខែ............ ឆ្នាំ.................
នាសម័យប្រជុំរដ្ឋសភាលើកទី... (ឬជាវិសាមញ្ញ) នីតិកាលទី...។
ថ្ងៃ........ ខែ......... ឆ្នាំ.............ស័ក ព.ស. ........
រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ.......... ឆ្នាំ...............

**ប្រធានរដ្ឋសភា**

**(ហត្ថលេខានិងឈ្មោះ)**

**គំរូទី២០**

ទម្រង់ក្របសន្លឹកទំព័រដំបូងនៃអនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្ដីស្នើច្បាប់



(សញ្ញាជាតិដូចមានក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**អនុសាសន៍លើសេចក្ដីស្នើ**

**ច្បាប់**

**ស្ដីពី**

(ចំណងជើងនៃសេចក្ដីស្នើច្បាប់ជាពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light)

**ដែលរៀបចំដោយគណៈកម្មការទី...នៃរដ្ឋសភាឬព្រឹទ្ធសភា**

**អនុសាសន៍របស់រាជរដ្ឋាភិបាលលើចំណងជើងនៃសេចក្ដីស្នើច្បាប់**

(ចំណងជើងដែលនាយករដ្ឋមន្ត្រីឯកភាពផ្ដល់អនុសាសន៍កែសម្រួល)

**គំរូទី២១**

ទម្រង់សន្លឹកទំព័របន្តបន្ទាប់នៃអនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្តីស្នើច្បាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

..........................................ខ្លឹមសារដើមរបស់សេចក្តីស្នើច្បាប់......................................។

**អនុសាសន៍របស់រាជរដ្ឋាភិបាល**

ខ្លឹមសារទាំងស្រុងដែលនាយករដ្ឋមន្ត្រីឯកភាព តាមការផ្តល់អនុសាសន៍របស់អង្គប្រជុំតាមនីតិវិធី។

**ជំពូកទី២**និង**ជំពូក**បន្តបន្ទាប់

(ចំណងជើង)

**មាត្រា... .-**

..........................................ខ្លឹមសារដើមរបស់សេចក្តីស្នើច្បាប់......................................។

**អនុសាសន៍របស់រាជរដ្ឋាភិបាល**

ខ្លឹមសារទាំងស្រុងដែលនាយករដ្ឋមន្ត្រីឯកភាព តាមការផ្តល់អនុសាសន៍របស់អង្គប្រជុំតាមនីតិវិធី។

**ជំពូកទី...**

**អន្តរប្បញ្ញត្តិ**(ប្រសិនបើមាន)

**មាត្រា... .-**

..........................................ខ្លឹមសារដើមរបស់សេចក្តីស្នើច្បាប់......................................។

**អនុសាសន៍របស់រាជរដ្ឋាភិបាល**

ខ្លឹមសារទាំងស្រុងដែលនាយករដ្ឋមន្ត្រីឯកភាព តាមការផ្តល់អនុសាសន៍របស់អង្គប្រជុំតាមនីតិវិធី។

**ជំពូកទី...**

**អវសានប្បញ្ញត្តិ**

**មាត្រា... .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា... .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។(ក្នុងករណីដែលច្បាប់ត្រូវអនុវត្តជាប្រញាប់)

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

អនុម័តនៅថ្ងៃទី......... ខែ............ ឆ្នាំ...............

នាសម័យប្រជុំរដ្ឋសភាលើកទី... (ឬជាវិសាមញ្ញ) នីតិកាលទី...។

ថ្ងៃ........ ខែ......... ឆ្នាំ............ ស័ក ព.ស...........

រាជធានីភ្នំពេញ ថ្ងៃទី......... ខែ.............ឆ្នាំ.............

**ប្រធានរដ្ឋសភា**

**(គោរមងារនិងឈ្មោះ)**

### ៣.២.៤- ទម្រង់នៃព្រះរាជក្រម

ព្រះរាជក្រមជាលិខិតបទដ្ឋានគតិយុត្តដែលឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ ដើម្បីប្រកាសឱ្យប្រើច្បាប់។

ច្បាប់ទាំងឡាយដែលត្រូវបានរដ្ឋសភាអនុម័តនិងព្រឹទ្ធសភាពិនិត្យចប់សព្វគ្រប់រួចហើយ ត្រូវបានរដ្ឋសភាបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីវិញ ដើម្បីចាត់ចែងរៀបចំបែបបទទូលថ្វាយព្រះមហាក្សត្រស្នើសុំឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ស្របតាមរដ្ឋធម្មនុញ្ញ។

ទម្រង់នៃព្រះរាជក្រមចែកចេញជា៤ផ្នែក មានក្បាលលិខិត មូលបទ ខ្លឹមសារនៃអត្ថបទ និងរូបមន្តបញ្ចប់។

ក- **ក្បាលលិខិត** នៅផ្នែកនេះ ត្រូវទុកកន្លែងសម្រាប់បញ្ចូលព្រះរាជសង្ហាររបស់ព្រះមហាក្សត្រ ដែលមិនដូចសញ្ញាជាតិក្នុងរដ្ឋធម្មនុញ្ញទេ។ នៅចំកណ្តាលទំព័រក្រោមព្រះរាជសង្ហារ រំលង១បន្ទាត់ ត្រូវដាក់ពាក្យ **ព្រះរាជក្រម** ក្រោមពាក្យព្រះរាជក្រម ចំកណ្តាលដាក់ពាក្យ **យើង** ក្រោមពាក្យយើង សរសេរព្រះបរមនាមរបស់ព្រះមហាក្សត្រ។

ខ- **មូលបទ** ត្រូវយោងជាចាំបាច់នូវរដ្ឋធម្មនុញ្ញ ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី និងព្រះរាជក្រមទាំងឡាយដែលពាក់ព័ន្ធដោយដាក់លេខនិងដាក់សញ្ញាគំនូសទ្រេត(/)ឱ្យបានត្រឹមត្រូវ និងចុងក្រោយនៃមូលបទមានដាក់សេចក្តីថា៖

- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារនិងឈ្មោះ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

បន្ទាប់ពីនេះ នៅខាងក្រោម ចំកណ្តាលទំព័រ ត្រូវប្រើពាក្យនិងឃ្លារូបមន្តផ្តើមដូចខាងក្រោម៖

**ប្រកាសឱ្យប្រើ**

ច្បាប់ស្តីពី...(ចំណងជើងនៃច្បាប់)ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី... ខែ... ឆ្នាំ... នាសម័យប្រជុំរដ្ឋសភាលើកទី...(ឬជាវិសាមញ្ញ) នីតិកាលទី... ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី... ខែ... ឆ្នាំ... នាសម័យប្រជុំព្រឹទ្ធសភាលើកទី...(ឬជាវិសាមញ្ញ) នីតិកាលទី... ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ក្នុងករណីដែលច្បាប់ណាត្រូវបានឆ្លងការពិនិត្យរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសរសេរថា៖

ច្បាប់ស្តីពី...(ចំណងជើងនៃច្បាប់)ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី... ខែ... ឆ្នាំ... នាសម័យប្រជុំរដ្ឋសភាលើកទី...(ឬជាវិសាមញ្ញ) នីតិកាលទី... ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី... ខែ... ឆ្នាំ... នាសម័យប្រជុំព្រឹទ្ធសភាលើកទី...(ឬជាវិសាមញ្ញ) នីតិកាលទី... ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ(លើកលែងតែ... ឬចំណុច... ឬក៏មាត្រា...នៃ...(ប្រសិនបើមាន)) ក្នុងសេចក្តីសម្រេចលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

គ- **ខ្លឹមសារនៃអត្ថបទ** ត្រូវបញ្ចូលអត្ថបទច្បាប់ទាំងស្រុងដែលរដ្ឋសភាបានអនុម័តនិងព្រឹទ្ធសភាបានពិនិត្យ។

ឃ- **រូបមន្តបញ្ចប់** ព្រះរាជក្រមត្រូវបានឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រឬចុះហត្ថលេខាដោយប្រមុខរដ្ឋស្តីទី នៅពេលដែលព្រះមហាក្សត្រទ្រង់អវត្តមាន។ នាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីឬប្រធានស្ថាប័ន(ជាសមាជិករាជរដ្ឋាភិបាល)សាមីដែលជាអ្នកទទួលបន្ទុករៀបចំសេចក្តីព្រាងច្បាប់ ត្រូវចុះហត្ថលេខាអមផងដែរ។

ការដាក់ថ្វាយព្រះមហាក្សត្រឡាយព្រះហស្តលេខានិងការដាក់ជូននាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីឬប្រធានស្ថាប័ន(ជាសមាជិករាជរដ្ឋាភិបាល)សាមីចុះហត្ថលេខា ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម៖

- នៅមួយភាគបីខាងស្តាំនៃទំព័រចុងក្រោយរបស់ច្បាប់ ត្រូវដាក់កាលបរិច្ឆេទ៖
  - កាលបរិច្ឆេទចន្ទគតិ ថ្ងៃ... ខែ... ឆ្នាំ... ព.ស. ...
  - ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី... ខែ... ឆ្នាំ...(ក្នុងករណីដែលព្រះមហាក្សត្រគង់នៅព្រះបរមរាជវាំង) ឬ
  - ធ្វើនៅថ្ងៃទី... ខែ... ឆ្នាំ...(ក្នុងករណីដែលព្រះមហាក្សត្រមិនគង់នៅព្រះបរមរាជវាំង)។

- នៅក្រោមកាលបរិច្ឆេទ ត្រូវទុកចន្លោះប្រមាណ៤បន្ទាត់ សម្រាប់ព្រះហស្តលេខារបស់ព្រះមហាក្សត្រនៅខាងស្តាំ និងសម្រាប់ប្រថាប់ព្រះរាជលញ្ឆករបស់ព្រះមហាក្សត្រនៅខាងឆ្វេង។

ក្នុងករណីដែលត្រូវជូនប្រមុខរដ្ឋស្តីទី ត្រូវបន្ថែមកន្សោមពាក្យ **ឆ្លងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់** នៅលើពាក្យ **ប្រមុខរដ្ឋស្តីទី** ហើយទុកចន្លោះសម្រាប់ជូនប្រមុខរដ្ឋស្តីទីចុះហត្ថលេខា។

- នៅក្រោមព្រះហស្តលេខារបស់ព្រះមហាក្សត្រឬហត្ថលេខារបស់ប្រមុខរដ្ឋស្តីទី ត្រូវដាក់ព្រះបរមនាមឬគោរមងារ និង/ឬឈ្មោះរបស់ប្រមុខរដ្ឋស្តីទី។

- នៅប៉ែកខាងឆ្វេងនៃទំព័រ ក្រោមព្រះបរមនាមរបស់ព្រះមហាក្សត្រឬគោរមងារនិង/ឬឈ្មោះរបស់ប្រមុខរដ្ឋស្តីទី ត្រូវមានហត្ថលេខាអមរបស់នាយករដ្ឋមន្ត្រី ដោយដាក់ថា «បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា»។

- ក្រោមហត្ថលេខា គោរមងារ និងឈ្មោះរបស់នាយករដ្ឋមន្ត្រី ខាងស្តាំទំព័រត្រូវមានហត្ថលេខាអមរបស់រដ្ឋមន្ត្រីឬប្រធានស្ថាប័ន(ជាសមាជិករាជរដ្ឋាភិបាល)សាមី ដោយដាក់ថា «បានយកសេចក្តីគោរពជម្រាបជូន(គោរមងារ)នាយករដ្ឋមន្ត្រី»។

ក្រសួងព្រះបរមរាជវាំងចុះលេខព្រះរាជក្រម ដោយដាក់សញ្ញាសម្គាល់អក្សរកាត់តាមរូបមន្ត **នស/រកម**/...**(លេខខែឆ្នាំ)**/...**(លេខព្រះរាជក្រម)** ចុះកាលបរិច្ឆេទ ប្រថាប់ព្រះរាជលញ្ឆករ និងចុះលេខព្រះរាជលញ្ឆករ ព្រមទាំងបោះត្រារបស់ក្រសួងព្រះបរមរាជវាំងលើគ្រប់សន្លឹកទំព័រនៃព្រះរាជក្រម លើកលែងតែទំព័រចុងក្រោយដែលមានព្រះរាជលញ្ឆករួចហើយ។

**សូមមើលគំរូទី២២** : ទម្រង់នៃព្រះរាជក្រម នៅទំព័រទី៣៨ដល់ទំព័រទី៤១។

ង- ព្រះរាជក្រមបានចម្លងត្រឹមត្រូវតាមច្បាប់ដើមនិងច្បាប់ចម្លងចែក

ចំពោះព្រះរាជក្រមដែលព្រះមហាក្សត្របានឡាយព្រះហស្តលេខាឬប្រមុខរដ្ឋស្តីទីបានចុះហត្ថលេខារួច ទីស្តីការគណៈរដ្ឋមន្ត្រីមានភារកិច្ចរៀបចំ ចម្លងត្រឹមត្រូវតាមច្បាប់ដើម សម្រាប់ចែកជូនក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ដើម្បីចាត់ចែងអនុវត្ត។ ក្នុងករណីនេះ ត្រូវដាក់នៅប៉ែកខាងស្តាំនៃទំព័រ ក្រោមព្រះបរមនាមរបស់ព្រះមហាក្សត្រឬគោរមងារនិង/ឬឈ្មោះរបស់ប្រមុខរដ្ឋស្តីទី ដោយរក្សាទុកព្រះហស្តលេខារបស់ព្រះមហាក្សត្រឬហត្ថលេខារបស់ប្រមុខរដ្ឋស្តីទី ហត្ថលេខាអមរបស់នាយករដ្ឋមន្ត្រី និងហត្ថលេខាអមរបស់រដ្ឋមន្ត្រីឬប្រធានស្ថាប័ន(ជាសមាជិករាជរដ្ឋាភិបាល)សាមីនូវរូបមន្តខាងក្រោមនេះ៖

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
(ហត្ថលេខានិងត្រា)
**(គោរមងារនិង/ឬឈ្មោះ)**

ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្តមានភារកិច្ចបន្តចម្លងព្រះរាជក្រមបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ជូនអង្គភាពក្រោមឱវាទដើម្បីចាត់ចែងអនុវត្ត។ ក្នុងករណីនេះ ត្រូវអនុវត្តដូចតទៅ៖

- នៅប៉ែកខាងស្តាំនៃទំព័រ ក្រោមរូបមន្តបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ត្រូវដាក់រូបមន្តខាងក្រោមនេះ៖

លេខ : ..........................................................
**បានចម្លងត្រឹមត្រូវតាមច្បាប់ចម្លងចែក**
ថ្ងៃ............... ខែ........ ឆ្នាំ........ ស័ក ព.ស.......
រាជធានីភ្នំពេញ ថ្ងៃទី........ ខែ........ ឆ្នាំ..........
**ត.ប. រដ្ឋមន្ត្រី**
**អគ្គលេខាធិការឬអគ្គនាយក**..............................
(ហត្ថលេខានិងត្រា)
(ឈ្មោះ)

- នៅប៉ែកខាងឆ្វេងនៃទំព័រ ក្រោមរូបមន្តបានចម្លងត្រឹមត្រូវតាមច្បាប់ចម្លងចែក ត្រូវដាក់ **កន្លែងទទួល** ដែលរួមមាន អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន នាយកដ្ឋាន មន្ទីរជំនាញរាជធានី ខេត្ត និងឯកសារ កាលប្បវត្តិ។

**សូមមើលគំរូទី២៣** : ទម្រង់នៃព្រះរាជក្រមបានចម្លងត្រឹមត្រូវតាមច្បាប់ដើមនិងច្បាប់ចម្លងចែក នៅទំព័រទី៤២ ដល់ទំព័រទី៤៥។

**គំរូទី២២**

ទម្រង់នៃព្រះរាជក្រម

(រូបសញ្ញាព្រះរាជសង្ហាររបស់ព្រះមហាក្សត្រ)

# ព្រះរាជក្រម

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី...ខែ...ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី...ខែ...ឆ្នាំ... ស្តីពីការកែសម្រួល និង/ឬបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬការតែងតាំងសមាជិករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា(ដែលទាក់ទងនឹងរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីដែលរៀបចំសេចក្តីព្រាង)
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី...ខែ...ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី...ខែ...ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត... (ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារនិងឈ្មោះ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី...(ចំណងជើងនៃច្បាប់)ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី... ខែ... ឆ្នាំ... នាសម័យប្រជុំរដ្ឋសភាលើកទី...(ឬជាវិសាមញ្ញ) នីតិកាលទី... ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី... ខែ... ឆ្នាំ... នាសម័យប្រជុំព្រឹទ្ធសភាលើកទី...(ឬជាវិសាមញ្ញ) នីតិកាលទី... (ក្នុងករណីដែលច្បាប់ណាត្រូវបានឆ្លងការពិនិត្យរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវថែងបន្ថែមថា ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ(លើកលែងតែ... ឬចំណុច... ឬក៏មាត្រា...នៃ...(ប្រសិនបើមាន)) ក្នុងសេចក្តីសម្រេចលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ...) ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

(ត្រូវបញ្ចូលអត្ថបទច្បាប់ទាំងស្រុងដែលរដ្ឋសភាបានអនុម័តនិងព្រឹទ្ធសភាបានពិនិត្យហើយឱ្យឃើញ)

# ច្បាប់
# ស្តីពី

...

(ចំណងជើងជាពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light)

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

.................................................................................................................................។

## ជំពូកទី២និងជំពូកបន្តបន្ទាប់
(ចំណងជើង)

**មាត្រា... .-**

.................................................................................................................................។

## ជំពូកទី...
## ទោសប្បញ្ញត្តិ

**មាត្រា... .-**

.................................................................................................................................។

## ជំពូកទី...
## អន្តរប្បញ្ញត្តិ (ប្រសិនបើមាន)

**មាត្រា... .-**

.................................................................................................................................។

## ជំពូកទី...
## អវសានប្បញ្ញត្តិ

**មាត្រា... .-**

.................................................................................................................................។

ថ្ងៃ.................. ខែ............ ឆ្នាំ......... ......ស័ក ព.ស. .......
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី........... ខែ............ ឆ្នាំ.......... ឬ
ថ្ងៃ.................. ខែ............ ឆ្នាំ......... ......ស័ក ព.ស. .......
ធ្វើនៅថ្ងៃទី............. ខែ................. ឆ្នាំ.........................

(ក្នុងករណីដែលព្រះមហាក្សត្រមិនគង់នៅព្រះបរមរាជវាំង)

(ព្រះហស្តលេខានិងព្រះរាជលញ្ចករ)

(**ព្រះនាម**) ឬ

ថ្ងៃ.................. ខែ............ ឆ្នាំ......... ......ស័ក ព.ស. .......
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី........... ខែ......... ឆ្នាំ...............

**ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

(ហត្ថលេខានិងព្រះរាជលញ្ចករ)

(**គោរមងារនិង/ឬឈ្មោះ**)

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

(ហត្ថលេខា)

(**គោរមងារនិងឈ្មោះ**)

បានយកសេចក្ដីគោរពជម្រាបជូន(គោរមងារ)នាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**...ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**...ឬ

**រដ្ឋមន្ត្រីក្រសួង**...(ឬប្រធានស្ថាប័ន(ជាសមាជិករាជរដ្ឋាភិបាល)សាមី)

(ហត្ថលេខា)

(**គោរមងារនិង/ឬឈ្មោះ**)

**គំរូទី២៣**

ទម្រង់នៃព្រះរាជក្រមបានចម្លងត្រឹមត្រូវតាមច្បាប់ដើមនិងច្បាប់ចម្លងចែក

(រូបសញ្ញាព្រះរាជសង្ហាររបស់ព្រះមហាក្សត្រ)

# ព្រះរាជក្រម

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី...ខែ...ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី...ខែ...ឆ្នាំ... ស្តីពីការកែសម្រួលនិង/ឬបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬការតែងតាំងសមាជិករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា(ដែលទាក់ទងនឹងរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីដែលរៀបចំសេចក្តីព្រាង)
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី...ខែ...ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី...ខែ...ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត...(ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារនិងឈ្មោះ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី(ចំណងជើងនៃច្បាប់) ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី... ខែ... ឆ្នាំ... នាសម័យប្រជុំរដ្ឋសភាលើកទី...(ឬជាវិសាមញ្ញ) នីតិកាលទី... ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី... ខែ... ឆ្នាំ... នាសម័យប្រជុំព្រឹទ្ធសភាលើកទី...(ឬជាវិសាមញ្ញ) នីតិកាលទី... (ក្នុងករណីដែលច្បាប់ណាត្រូវបានឆ្លងការពិនិត្យរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវថែងបន្ថែមថា ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ(លើកលែងតែ... ឬចំណុច... ឬក៏មាត្រា...នៃ...(ប្រសិនបើមាន)) ក្នុងសេចក្តីសម្រេចលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ...) ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

(ត្រូវបញ្ចូលអត្ថបទច្បាប់ទាំងស្រុងដែលរដ្ឋសភាបានអនុម័តនិងព្រឹទ្ធសភាបានពិនិត្យហើយឱ្យយោបល់)

# ច្បាប់
# ស្តីពី

...

(ចំណងជើងជាពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light)

**ជំពូកទី១**
**បទប្បញ្ញត្តិទូទៅ**

**មាត្រា១ .-**

.............................................................................................................................។

**ជំពូកទី២**និង**ជំពូក**បន្តបន្ទាប់
(ចំណងជើង)

**មាត្រា... .-**

.............................................................................................................................។

**ជំពូកទី...**
**ទោសប្បញ្ញត្តិ**

**មាត្រា... .-**

.............................................................................................................................។

**ជំពូកទី...**
**អន្តរប្បញ្ញត្តិ** (ប្រសិនបើមាន)

**មាត្រា... .-**

.............................................................................................................................។

**ជំពូកទី...**
**អវសានប្បញ្ញត្តិ**

**មាត្រា... .-**

.............................................................................................................................។

ថ្ងៃ................. ខែ........... ឆ្នាំ......... ......ស័ក ព.ស. .......
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី........... ខែ............ ឆ្នាំ.......... ឬ
ថ្ងៃ................. ខែ........... ឆ្នាំ......... ......ស័ក ព.ស. .......
ធ្វើនៅថ្ងៃទី............. ខែ................. ឆ្នាំ........................
(ក្នុងករណីដែលព្រះមហាក្សត្រមិនគង់នៅព្រះបរមរាជវាំង)
(ព្រះហស្តលេខានិងព្រះរាជលញ្ឆករ)
(**ព្រះនាម**) ឬ
ថ្ងៃ................. ខែ........... ឆ្នាំ......... ......ស័ក ព.ស. .......
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី............ ខែ.......... ឆ្នាំ...............
**ក្នុងព្រះបរមនាមនិងតាមព្រះរាជបន្ទូលបង្គាប់**
**ប្រមុខរដ្ឋស្តីទី**
(ហត្ថលេខានិងព្រះរាជលញ្ឆករ)
(**គោរមងារនិង/ឬឈ្មោះ**)

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
(ហត្ថលេខា)
(**គោរមងារនិងឈ្មោះ**)

បានយកសេចក្តីគោរពជម្រាបជូន(គោរមងារ)នាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**...ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**...ឬ
**រដ្ឋមន្ត្រីក្រសួង**...(ឬប្រធានស្ថាប័ន(ជាសមាជិករាជរដ្ឋាភិបាល)សាមី)
(ហត្ថលេខា)
(**គោរមងារនិង/ឬឈ្មោះ**)

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
(ហត្ថលេខានិងត្រា)
(**គោរមងារនិង/ឬឈ្មោះ**)

លេខ : .........................................................
**បានចម្លងត្រឹមត្រូវតាមច្បាប់ចម្លងចែក**
ថ្ងៃ.............. ខែ........ ឆ្នាំ...... ....ស័ក ព.ស. ...
រាជធានីភ្នំពេញ ថ្ងៃទី........ ខែ......... ឆ្នាំ...........
**ត.ប. រដ្ឋមន្ត្រី**
**អគ្គលេខាធិការឬអគ្គនាយក**...................
(ហត្ថលេខានិងត្រា)
(**ឈ្មោះ**)

**កន្លែងទទួល៖**
- អគ្គលេខាធិការដ្ឋាន
- អគ្គនាយកដ្ឋាន
- អគ្គាធិការដ្ឋាន
- នាយកដ្ឋាន
- មន្ទីរជំនាញរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

### ៣.២.៥- ទម្រង់នៃព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យជាសេចក្តីត្រាស់បង្គាប់ចេញដោយព្រះមហាក្សត្រ។ ព្រះរាជក្រឹត្យមានពីរប្រភេទគឺព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅនិងព្រះរាជក្រឹត្យមានលក្ខណៈជាឯកត្តកូត។

ព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ ជាសេចក្តីត្រាស់បង្គាប់ណែនាំការអនុវត្តច្បាប់ឬជាសេចក្តីត្រាស់បង្គាប់ស្តីពីខ្លឹមសារពាក់ព័ន្ធនឹងបញ្ហាទាំងឡាយដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល មានលក្ខណៈជាបទបញ្ញា មានអានុភាពទូទៅ និងមិនសំដៅចំឈ្មោះបុគ្គលណាម្នាក់ឡើយ។ ព្រះរាជក្រឹត្យប្រភេទនេះមានដូចជា ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាដើម។

ព្រះរាជក្រឹត្យមានលក្ខណៈជាឯកត្តកូត ជាសេចក្តីត្រាស់បង្គាប់ដែលសំដៅចំឈ្មោះបុគ្គលតែម្តង។ អនុលោមតាមរដ្ឋធម្មនុញ្ញនិងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ព្រះរាជក្រឹត្យមានលក្ខណៈជាឯកត្តកូតមានដូចជាព្រះរាជក្រឹត្យស្តីពីការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ការតែងតាំង ការប្រគល់ភារកិច្ច ការផ្ទេរភារកិច្ច ការដំឡើងឋានន្តរសក្តិ ការបន្ថយឋានន្តរសក្តិ ការដំឡើងថ្នាក់ ការបន្ថយថ្នាក់ ការដកពីមុខតំណែង ការអនុញ្ញាតឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ការអនុញ្ញាតឬការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ការអនុញ្ញាតឱ្យចូលបម្រើការងារឡើងវិញ ការបញ្ចប់ភារកិច្ច ការលុបឈ្មោះឬការបញ្ឈប់ពីការងារ ការដាក់ឱ្យចូលនិវត្តន៍ ការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌប្រភេទ ក ការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ការបន្ធូរបន្ថយនិងការលើកលែងទោស ការតែងតាំង/ផ្លាស់ប្តូរ/...ថៅក្រមនិងព្រះរាជអាជ្ញា ការតែងតាំងព្រះគោរមងារឬព្រះឋានានុក្រមមន្ត្រីសង្ឃ ការប្រទានគ្រឿងឥស្សរិយយសចំពោះបុគ្គលឬជាក្រុម ការតែងតាំងឬប្រទានគោរមងារ លោកអ្នកឧកញ៉ា ឬអ្នកឧកញ៉ា ឬក៏ឧកញ៉ា ជាដើម។

ទម្រង់នៃព្រះរាជក្រឹត្យចែកចេញជា៤ផ្នែក មានក្បាលលិខិត មូលបទ ខ្លឹមសារនៃអត្ថបទ និងរូបមន្តបញ្ចប់។

**ក- ក្បាលលិខិត** នៅផ្នែកនេះមានព្រះរាជសង្ហាររបស់ព្រះមហាក្សត្រ នៅចំកណ្តាលទំព័រក្រោមព្រះរាជសង្ហាររបស់ព្រះមហាក្សត្រ រំលង១បន្ទាត់ ត្រូវដាក់ពាក្យ **ព្រះរាជក្រឹត្យ** ក្រោមពាក្យព្រះរាជក្រឹត្យ ដាក់ពាក្យ **ស្តីពី** ក្រោមពាក្យស្តីពី នៅក្រោមចំកណ្តាល ដាក់ចំណងជើងនៃព្រះរាជក្រឹត្យ នៅក្រោមចំណងជើងនៃព្រះរាជក្រឹត្យ ចំកណ្តាលដាក់ពាក្យ **យើង** ហើយនៅពីក្រោមនេះ ចំកណ្តាល សរសេរព្រះបរមនាមរបស់ព្រះមហាក្សត្រ។

**ខ- មូលបទ** ត្រូវយោងជាចាំបាច់នូវរដ្ឋធម្មនុញ្ញ ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ព្រះរាជក្រម និងព្រះរាជក្រឹត្យទាំងឡាយដែលពាក់ព័ន្ធ មានជាអាទិ៍ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង ស្ថាប័ន ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការនៃក្រសួង ស្ថាប័នសាមី(បើជាព្រះរាជក្រឹត្យតែងតាំង) និងចុងក្រោយនៃមូលបទមានដាក់សេចក្តីដូចខាងក្រោម៖

- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារនិងឈ្មោះ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី... ខែ... ឆ្នាំ... (ចំពោះព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ ដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី) ឬ

- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារនិងឈ្មោះ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា (ចំពោះព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ ដែលមិនបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងព្រះរាជក្រឹត្យមានលក្ខណៈជាឯកត្តកូត ដែលស្នើឡើងដោយរាជរដ្ឋាភិបាល)។

ដោយឡែកចំពោះការតែងតាំងរាជរដ្ឋាភិបាលថ្មី ត្រូវថែងបន្ថែមក្នុងមូលបទដូចខាងក្រោម៖

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នាថ្ងៃទី... ខែ... ឆ្នាំ...

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្ដីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី... នីតិកាលទី... នៃរដ្ឋសភា នាថ្ងៃទី... ខែ... ឆ្នាំ... ស្ដីពីការជ្រើសតាំងរចនាសម្ព័ន្ធនិងថ្នាក់ដឹកនាំនៃរដ្ឋសភា និងការសំដែងការទុកចិត្តទៅលើសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

បន្ទាប់ពីនេះ នៅខាងក្រោមចំកណ្ដាលទំព័រ ត្រូវសរសេរពាក្យ **ត្រាស់បង្គាប់**

**គ- ខ្លឹមសារនៃអត្ថបទ**

គ.១- ព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ជាទូទៅ ត្រូវចែកជាជំពូក ដែលមានបទប្បញ្ញត្តិទូទៅ បទប្បញ្ញត្តិផ្សេងៗ និងអវសានប្បញ្ញត្តិ ហើយបទប្បញ្ញត្តិនៃជំពូកនីមួយៗ មានចែកជាផ្នែក អនុផ្នែក មាត្រា កថាខណ្ឌ វាក្យខណ្ឌ អាស្រ័យទៅតាមខ្លឹមសារនៃបទប្បញ្ញត្តិវែងឬខ្លី។ ប៉ុន្តែមានសេចក្ដីព្រាងព្រះរាជក្រឹត្យខ្លះខ្លី អាចពុំមានការបែងចែកដូចខាងលើឡើយ ដោយគ្រាន់តែកំណត់ជាមាត្រាប៉ុណ្ណោះ។

ចំពោះការតាក់តែងសេចក្ដីព្រាងព្រះរាជក្រឹត្យ ត្រូវអនុវត្តដូចក្នុងចំណុច ខ នៃ៣.២.១(ទម្រង់នៃសេចក្ដីព្រាងច្បាប់)។

**សូមមើលគំរូទី២៤** : ទម្រង់នៃព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ជាទូទៅ ដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទំព័រទី៥០ដល់ទំព័រទី៥២។

**សូមមើលគំរូទី២៥** : ទម្រង់នៃព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ជាទូទៅ ដែលមិនបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី តែមានសំណើពីក្រសួង ស្ថាប័នសាមី នៅទំព័រទី៥៣ដល់ទំព័រទី៥៥។

គ.២- ចំពោះព្រះរាជក្រឹត្យមានលក្ខណៈជាឯកត្តភូត មិនត្រូវចែកជាជំពូកទេ គឺចែកត្រឹមតែជាមាត្រា។

ជាទូទៅ ព្រះរាជក្រឹត្យមានលក្ខណៈជាឯកត្តភូតមានតែ២ទៅ៤មាត្រាប៉ុណ្ណោះ។

ដោយឡែក ព្រះរាជក្រឹត្យស្ដីពីការប្រទានគ្រឿងឥស្សរិយយសចំពោះបុគ្គលឬជាក្រុម និងព្រះរាជក្រឹត្យស្ដីពីការប្រទានគោរមងារ លោកអ្នកឧកញ៉ា ឬអ្នកឧកញ៉ា ឬក៏ឧកញ៉ា ពុំមានចែងពីមូលបទនិងមាត្រាដូចព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ជាទូទៅនិងព្រះរាជក្រឹត្យមានលក្ខណៈជាឯកត្តភូតឯទៀតទេ។

គ.២.១- **ខ្លឹមសារដែលត្រូវចែងក្នុងមាត្រា១** ត្រូវចែងដោយប្រែប្រួលទៅតាមកម្មវត្ថុនិងគោលបំណងជាក់ស្ដែងនីមួយៗ។

**សូមមើលគំរូទី២៦** : ទម្រង់នៃព្រះរាជក្រឹត្យស្ដីពីការតែងតាំងរាជរដ្ឋាភិបាលថ្មី នៅទំព័រទី៥៦ដល់ទំព័រទី៥៧។

**សូមមើលគំរូទី២៧** : ទម្រង់នៃព្រះរាជក្រឹត្យស្ដីពីការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ការតែងតាំង ការដំឡើងឋានន្តរសក្ដិ ឬថ្នាក់ ការដាក់ឱ្យចូលនិវត្តន៍មន្ត្រីរាជការ នៅទំព័រទី៥៨ដល់ទំព័រទី៦៤។

**សូមមើលគំរូទី២៨** : ទម្រង់នៃព្រះរាជក្រឹត្យស្ដីពីការផ្ដល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម នៅទំព័រទី៦៥ដល់ទំព័រទី៦៦។

**សូមមើលគំរូទី២៩** : ទម្រង់នៃព្រះរាជក្រឹត្យស្ដីពីការបន្ធូរបន្ថយទោសនិង/ឬការលើកលែងទោស នៅទំព័រទី៦៧ដល់ទំព័រទី៦៨។

**សូមមើលគំរូទី៣០** : ទម្រង់នៃព្រះរាជក្រឹត្យស្ដីពីការតែងតាំង/ផ្លាស់ប្ដូរ/... ចៅក្រមនិងព្រះរាជអាជ្ញា នៅទំព័រទី៦៩ដល់ទំព័រទី៧០។

**សូមមើលគំរូទី៣១** : ទម្រង់នៃព្រះរាជក្រឹត្យស្ដីពីការតែងតាំងព្រះគោរមងារឬព្រះឋានានុក្រមមន្ត្រីសង្ឃ នៅទំព័រទី៧១ដល់ទំព័រទី៧២។

**សូមមើលគំរូទី៣២** : ទម្រង់នៃព្រះរាជក្រឹត្យស្ដីពីការប្រទានគ្រឿងឥស្សរិយយសចំពោះបុគ្គល នៅទំព័រទី៧៣។

**សូមមើលគំរូទី៣៣** : ទម្រង់នៃព្រះរាជក្រឹត្យស្ដីពីការប្រទានគ្រឿងឥស្សរិយយសជាក្រុម នៅទំព័រទី៧៤។

**សូមមើលគំរូទី៣៤** : ទម្រង់នៃព្រះរាជក្រឹត្យស្ដីពីការប្រទានគោរមងារ ជាលោកអ្នកឧកញ៉ា ឬអ្នកឧកញ៉ា ឬឧកញ៉ា នៅទំព័រទី៧៥។

**សូមមើលគំរូទី៣៥** : ទម្រង់នៃព្រះរាជក្រឹត្យស្ដីពីការបញ្ចប់គោរមងារ ជាលោកអ្នកឧកញ៉ា ឬអ្នកឧកញ៉ា ឬឧកញ៉ា នៅទំព័រទី៧៦។

**សូមមើលគំរូទី៣៦** : ទម្រង់នៃព្រះរាជក្រឹត្យស្ដីពីការផ្ទេរស្ថាប័នឬអង្គភាព នៅទំព័រទី៧៧ដល់ទំព័រទី៧៨ (បញ្ជាក់ : ជាគោលការណ៍ បើស្ថាប័នឬអង្គភាពដែលត្រូវផ្ទេរនោះ បង្កើតឡើងដោយលិខិតបទដ្ឋានគតិយុត្តកម្រិតណា ការផ្ទេរនេះក៏ត្រូវប្រើលិខិតបទដ្ឋានគតិយុត្តកម្រិតនោះដែរ)។

**សូមមើលគំរូទី៣៧** : ទម្រង់នៃព្រះរាជក្រឹត្យស្ដីពីការបង្កើតស្ថាប័ន ដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទំព័រទី៧៩ដល់ទំព័រទី៨១។

**សូមមើលគំរូទី៣៨** : ទម្រង់នៃព្រះរាជក្រឹត្យស្ដីពីការបង្កើតស្ថាប័ន ដែលមិនឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី តែមានសំណើពីក្រសួង ស្ថាប័ន នៅទំព័រទី៨២ដល់ទំព័រទី៨៤។

**សូមមើលគំរូទី៣៩** : ទម្រង់នៃព្រះរាជក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ស្ថាប័ន ដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទំព័រទី៨៥ដល់ទំព័រទី៨៧។

**សូមមើលគំរូទី៤០** : ទម្រង់នៃព្រះរាជក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ស្ថាប័ន ដែលមិនឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី តែមានសំណើពីក្រសួង ស្ថាប័ន នៅទំព័រទី៨៨ដល់ទំព័រទី៩០។

**គ.២.២- ខ្លឹមសារដែលត្រូវចែងក្នុងមាត្រាបន្ទាប់និងមាត្រាបញ្ចប់**

មាត្រាដែលត្រូវចែងពីនិរាករណ៍ត្រូវចែងតែចំពោះករណីចាំបាច់ដែលត្រូវនិរាករណ៍ជាស្ថាពរនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលផ្ទុយនឹងព្រះរាជក្រឹត្យតែប៉ុណ្ណោះ។ ចំពោះមាត្រាបញ្ចប់ ត្រូវចែងពីបទប្បញ្ញត្តិស្ដីពីការត្រាស់បង្គាប់ឱ្យនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អនុវត្តព្រះរាជក្រឹត្យចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ហើយមិនត្រូវចែងបន្ថែមមាត្រាមួយទៀតថា «ព្រះរាជក្រឹត្យនេះត្រូវចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ» ឡើយ។

មាត្រាដែលត្រូវចែងពីនិរាករណ៍និងមាត្រាបញ្ចប់ត្រូវចែងដូចមានខ្លឹមសារក្នុងគំរូទម្រង់នៃព្រះរាជក្រឹត្យ។

**ឃ- រូបមន្តបញ្ចប់** ព្រះរាជក្រឹត្យត្រូវបានឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រឬចុះហត្ថលេខាដោយប្រមុខរដ្ឋស្ដីទី។ ចំពោះព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ជាទូទៅ ដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី មានតែហត្ថលេខាអមរបស់នាយករដ្ឋមន្ត្រីប៉ុណ្ណោះ។ ចំពោះព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ជាទូទៅ ដែលមិនបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី តែមានសំណើពីក្រសួង ស្ថាប័នសាមី ត្រូវមានហត្ថលេខាអមរបស់រដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័ន (ជាសមាជិករាជរដ្ឋាភិបាល)សាមីដែលជាអ្នកស្នើឡើងថែមទៀត។ ប្រសិនបើជាព្រះរាជក្រឹត្យមានលក្ខណៈជាឯកត្តភូត មិនមានហត្ថលេខាអមរបស់នាយករដ្ឋមន្ត្រីទេ។

ទីស្ដីការគណៈរដ្ឋមន្ត្រី ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ត្រូវពិនិត្យមើលរាល់សេចក្ដីព្រាងព្រះរាជក្រឹត្យឱ្យបានត្រឹមត្រូវតាមទម្រង់ខាងលើ មុននឹងដាក់ជូននាយករដ្ឋមន្ត្រីចុះហត្ថលេខាលើលិខិតថ្វាយព្រះមហាក្សត្រដើម្បីសូមឡាយព្រះហស្តលេខា។

ក្រសួងព្រះបរមរាជវាំងចុះលេខព្រះរាជក្រឹត្យ ដោយដាក់សញ្ញាសម្គាល់អក្សរកាត់តាមរូបមន្ត **នស/រកត**/...(លេខខែឆ្នាំ)/...(លេខព្រះរាជក្រឹត្យ) ចុះកាលបរិច្ឆេទ ប្រថាប់ព្រះរាជលញ្ចករ និងចុះលេខព្រះរាជលញ្ចករ ព្រមទាំងបោះត្រារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំងលើគ្រប់សន្លឹកទំព័រនៃព្រះរាជក្រឹត្យ លើកលែងតែទំព័រចុងក្រោយដែលមានព្រះរាជលញ្ចករួចហើយ។

**ង- ព្រះរាជក្រឹត្យបានចម្លងត្រឹមត្រូវតាមច្បាប់ដើមនិងច្បាប់ចម្លងចែក**

ចំពោះព្រះរាជក្រឹត្យដែលព្រះមហាក្សត្រឡាយព្រះហស្តលេខារួច ទីស្ដីការគណៈរដ្ឋមន្ត្រីមានភារកិច្ចរៀបចំចម្លងត្រឹមត្រូវតាមច្បាប់ដើម សម្រាប់ចែកជូនក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ដើម្បីចាត់ចែងអនុវត្ត។ ក្នុងករណីនេះ

ត្រូវដាក់នៅប៉ែកខាងស្ដាំនៃទំព័រ ក្រោមព្រះនាមរបស់ព្រះមហាក្សត្រឬគោរមងារនិង/ឬឈ្មោះរបស់ប្រមុខរដ្ឋស្ដីទី ដោយរក្សាទុកព្រះហស្ថលេខារបស់ព្រះមហាក្សត្រឬហត្ថលេខារបស់ប្រមុខរដ្ឋស្ដីទី ហត្ថលេខាអមរបស់នាយករដ្ឋមន្ត្រី និងហត្ថលេខាអមរបស់រដ្ឋមន្ត្រីឬប្រធានស្ថាប័ន(ជាសមាជិករាជរដ្ឋាភិបាល)សាមី នូវរូបមន្តខាងក្រោមនេះ៖

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

(ហត្ថលេខានិងត្រា)

(**គោរមងារនិង/ឬឈ្មោះ**)

ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត មានភារកិច្ចបន្តចម្លងព្រះរាជក្រឹត្យបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ជូនអង្គភាពក្រោមឱវាទដើម្បីចាត់ចែងអនុវត្ត។ ក្នុងករណីនេះ ត្រូវអនុវត្តដូចតទៅ៖

- នៅប៉ែកខាងស្ដាំនៃទំព័រ ក្រោមរូបមន្តបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ត្រូវដាក់រូបមន្តខាងក្រោមនេះ៖

លេខ : ........................................................

**បានចម្លងត្រឹមត្រូវតាមច្បាប់ចម្លងចែក**

ថ្ងៃ................ ខែ........ ឆ្នាំ...... ....ស័ក ព.ស. ...

រាជធានីភ្នំពេញ ថ្ងៃទី........ ខែ......... ឆ្នាំ...........

**ត.ប. រដ្ឋមន្ត្រី**

**អគ្គលេខាធិការឬអគ្គនាយក**...................

(ហត្ថលេខានិងត្រា)

(**ឈ្មោះ**)

- នៅប៉ែកខាងឆ្វេងនៃទំព័រ ក្រោមរូបមន្តបានចម្លងត្រឹមត្រូវតាមច្បាប់ចម្លងចែក ត្រូវដាក់ **កន្លែងទទួល** ដែលរួមមាន អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន នាយកដ្ឋាន មន្ទីរជំនាញរាជធានី ខេត្ត និងឯកសារ កាលប្បវត្តិ។

**សូមមើលគំរូទី៤១** : ទម្រង់នៃព្រះរាជក្រឹត្យបានចម្លងត្រឹមត្រូវតាមច្បាប់ដើមនិងច្បាប់ចម្លងចែកនៅទំព័រទី៩១ដល់ទំព័រទី៩៣។

**ច- ព្រះរាជក្រឹត្យដែលស្នើឡើងដោយស្ថាប័នផ្សេងទៀត**

ព្រះរាជក្រឹត្យដែលព្រះមហាក្សត្រសព្វព្រះរាជហឫទ័យប្រទានតាមព្រះរាជតម្រិះ ក្រសួងព្រះបរមរាជវាំងបញ្ជូនច្បាប់ចម្លងនៃព្រះរាជក្រឹត្យទាំងនោះ ដោយមានការបញ្ជាក់ថា «បានចម្លងត្រឹមត្រូវតាមច្បាប់ដើម» ពីរដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ទៅទីស្ដីការគណៈរដ្ឋមន្ត្រី ដើម្បីផ្សព្វផ្សាយក្នុងរាជកិច្ច។ ក្រសួងព្រះបរមរាជវាំងមានចេញច្បាប់ «បានចម្លងត្រឹមត្រូវតាមច្បាប់តម្កល់» ជូនក្រសួង ស្ថាប័ន ឬសាមីជនដែលត្រូវការ។

**ក- ក្បាលលិខិត** ត្រូវប្រើក្រដាសក្បាលលិខិតរបស់រាជរដ្ឋាភិបាល ដែលមានសញ្ញាជាតិ(ដូចក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា) នៅខាងលើចំកណ្តាលទំព័រ ក្រោមសញ្ញាជាតិ ដាក់ **ព្រះរាជាណាចក្រកម្ពុជា** ក្រោមព្រះរាជាណាចក្រកម្ពុជា ដាក់បាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ** ប៉ែកខាងឆ្វេងក្រោមបន្ទាត់បាវចនា ត្រូវដាក់ **រាជរដ្ឋាភិបាលកម្ពុជា** ក្រោមរាជរដ្ឋាភិបាលកម្ពុជា ដាក់ពាក្យ **លេខ** : ... សម្រាប់ទុកចុះលេខរបស់សេចក្តីសម្រេចដែលមានរូបមន្តអក្សរកាត់ **លេខ** : ... សសរ។

នៅក្រោមបាវចនា រំលង១បន្ទាត់ ចំកណ្តាលទំព័រ ត្រូវដាក់ពាក្យ **សេចក្តីសម្រេច** ក្រោមពាក្យសេចក្តីសម្រេចដាក់ពាក្យ **ស្តីពី** ក្រោមពាក្យស្តីពី ដាក់ **ការកែសម្រួលសេចក្តីសម្រេចស្តីពី...** ចំពោះចំណងជើងនៃសេចក្តីសម្រេចដែលធ្វើការកែសម្រួលសេចក្តីសម្រេចដំបូងជាបន្តបន្ទាប់ ត្រូវដាក់ចំណងជើងថា **សេចក្តីសម្រេចស្តីពីការកែសម្រួលសេចក្តីសម្រេចស្តីពី...**(ចំណងជើងសេចក្តីសម្រេចដំបូង)ដដែល ពីព្រោះទោះបីជាមានការកែសម្រួលប៉ុន្មានដងក៏ដោយ ក៏ត្រូវបានបកស្រាយថាជាសេចក្តីសម្រេចតែមួយ ដូចករណីវិសោធនកម្មរដ្ឋធម្មនុញ្ញច្រើនដងដែរ និងជាបន្តមកទៀត ដាក់ចំណងជើងដំបូងនៃសេចក្តីសម្រេចដែលត្រូវធ្វើការកែសម្រួល។

នៅក្រោមចំណងជើង ចំកណ្តាល រំលង១បន្ទាត់ ត្រូវដាក់ **រាជរដ្ឋាភិបាល**

ខ- មូលបទ ត្រូវជ្រើសរើសយោងតែលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងខ្លឹមសារនៃសេចក្តីសម្រេចស្តីពីការកែសម្រួលសេចក្តីសម្រេច ហើយសរសេរដោយប្រើពាក្យ «បានឃើញ»។ លិខិតបទដ្ឋានគតិយុត្តដែលត្រូវយោងក្នុងសេចក្តីសម្រេចស្តីពីការកែសម្រួលសេចក្តីសម្រេច មានជាអាទិ៍ រដ្ឋធម្មនុញ្ញ ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី អនុក្រឹត្យពាក់ព័ន្ធ សេចក្តីសម្រេចដើម។

នៅចុងក្រោយបង្អស់នៃមូលបទ ត្រូវយោងតាមករណីនីមួយៗនៃសេចក្តី ដោយចែងដូចខាងក្រោម៖

- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល(ក្នុងករណីសម្រេចតាមឆន្ទានុសិទ្ធិរបស់នាយករដ្ឋមន្ត្រី) ឬ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួង ... (ឬប្រធានស្ថាប័នសាមី)។

នៅខាងក្រោមចំកណ្តាលទំព័រ ត្រូវសរសេរពាក្យ **សម្រេច**

**គ- ខ្លឹមសារនៃអត្ថបទ**

សេចក្តីសម្រេចស្តីពីការកែសម្រួលសេចក្តីសម្រេច ជាទូទៅមាន២ប្រការ។

**ប្រការមួយ** ត្រូវចែងពីប្រការទាំងឡាយដែលត្រូវធ្វើការកែសម្រួល ក្នុងនោះត្រូវចែងប្រការថ្មីដែលកែប្រែខ្លឹមសារប្រការចាស់និង/ឬប្រការស្ទួន ដោយដាក់ស្មើនឹងប្រការមួយដែរ។

**កំណត់សម្គាល់** : ចំពោះការកែសម្រួលប្រការណាមួយចំនួនពីរលើក ត្រូវដាក់ថា **ប្រការ**...(លេខរបស់ប្រការ) **_ ថ្មី(មួយ)** ហើយបើមានការកែសម្រួលចំនួនបីលើកឡើងទៅ ត្រូវដាក់ថា **ប្រការ**...(លេខរបស់ប្រការ) **_ ថ្មី(ពីរ) ប្រការ**...(លេខរបស់ប្រការ) **_ ថ្មី(បី) ប្រការ**...(លេខរបស់ប្រការ) **_ ថ្មី(បួន)** ឬ**ប្រការ**...(លេខរបស់ប្រការ) **_ ថ្មី**(...)។

ចំពោះការកែសម្រួលសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលដោយបន្ថែមប្រការស្ទួនឬការកែសម្រួលប្រការស្ទួនត្រូវអនុវត្តដូចចំណុច ខ.២ ខ.៤ និង ខ.៥ នៃចំណុច ខ នៃ៣.២.២(ទម្រង់សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់)។

**ប្រការពីរ** ត្រូវចែងពីការប្រគល់ភារកិច្ចជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីឬប្រធានស្ថាប័នដែលទទួលបន្ទុករៀបចំឬស្នើ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដែលត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**សូមមើលគំរូទី៦៤**៖ ទម្រង់នៃសេចក្តីសម្រេចស្តីពីការកែសម្រួលសេចក្តីសម្រេច តាមឆន្ទានុសិទ្ធិរបស់នាយករដ្ឋមន្រ្តី ឬមានសំណើពីក្រសួង ស្ថាប័នសាមី នៅទំព័រទី១៥៥ដល់ទំព័រទី១៥៦។

**ឃ- រូបមន្តបញ្ចប់** នៅខាងក្រោមប៉ែកខាងស្តាំ ត្រូវចុះទីកន្លែង កាលបរិច្ឆេទ ហត្ថលេខា គោរមងារ និង ឈ្មោះរបស់នាយករដ្ឋមន្រ្តី និងបោះត្រារបស់រាជរដ្ឋាភិបាល។ ចំពោះសេចក្តីសម្រេចស្តីពីការកែសម្រួលសេចក្តីសម្រេច តាមឆន្ទានុសិទ្ធិរបស់នាយករដ្ឋមន្រ្តីឬសំណើពីក្រសួង ស្ថាប័នសាមី មានតែហត្ថលេខារបស់នាយករដ្ឋមន្រ្តីប៉ុណ្ណោះ។

នៅប៉ែកខាងឆ្វេងទំព័រ ត្រូវដាក់ **កន្លែងទទួល** ដែលរួមមានក្រសួងព្រះបរមរាជវាំង អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានរដ្ឋសភា ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្រ្តី ខុទ្ទកាល័យ (គោរមងារ)ឧបនាយករដ្ឋមន្រ្តី ដូចប្រការ...(ពាក់ព័ន្ធនឹងក្រសួង ស្ថាប័ន និងសាមីជន ដែលត្រូវអនុវត្ត) រាជកិច្ច និងឯកសារ កាលប្បវត្តិ។

**គំរូទី៦៤**

**ទម្រង់នៃសេចក្តីសម្រេចស្តីពីការកែសម្រួលសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល**
**តាមឆន្ទានុសិទ្ធិរបស់នាយករដ្ឋមន្ត្រី ឬមានសំណើពីក្រសួង ស្ថាប័នសាមី**

(សញ្ញាជាតិដូចមានក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ...

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសេចក្តីសម្រេចស្តីពី...

(ចំណងជើងនៃសេចក្តីសម្រេចដំបូងដែលត្រូវធ្វើការកែសម្រួល)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី...ខែ...ឆ្នាំ... ស្តីពីការកែសម្រួល និង/ឬបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬការតែងតាំងសមាជិករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា(ដែលទាក់ទងនឹងរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីដែលរៀបចំសេចក្តីព្រាង)
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត...(ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់...(ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី... (ដែលពាក់ព័ន្ធ)
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ... សសរ ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល(ក្នុងករណីតាមឆន្ទានុសិទ្ធិរបស់នាយករដ្ឋមន្ត្រី) ឬ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័នសាមី)

## សម្រេច

**ប្រការមួយ .–**

ប្រការ...(លេខប្រការដែលត្រូវធ្វើការកែសម្រួល) នៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ចំណងជើងនៃសេចក្តីសម្រេចដែលត្រូវធ្វើការកែសម្រួល) ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖ (ក្នុងករណីការកែសម្រួលលើកដំបូង) ឬ

ប្រការ...(លេខប្រការដែលត្រូវធ្វើការកែសម្រួល : ប្រការដើម និងប្រការដែលបានកែសម្រួល ហើយត្រូវយកមកកែសម្រួលក្នុងសេចក្តីសម្រេចនេះ) នៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ចំណងជើងនៃសេចក្តីសម្រេចដំបូងដែលត្រូវធ្វើការកែសម្រួល) ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**ប្រការ**...(លេខប្រការដែលត្រូវធ្វើការកែសម្រួល) **.- ថ្មី**

..................................................................................................................................។

ឬ

**ប្រការមួយ .-**

សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ចំណងជើងនៃសេចក្តីសម្រេចដំបូងដែលត្រូវធ្វើការកែសម្រួល) ត្រូវបានធ្វើការកែសម្រួលដោយបន្ថែមប្រការ...(លេខប្រការ)ស្ទួន ដូចតទៅ៖ (ក្នុងករណីបន្ថែមប្រការស្ទួន)

**ប្រការ**...(លេខប្រការ) **.- ស្ទួន**

..................................................................................................................................។

កំណត់សម្គាល់ : ក្នុងករណីមានការកែសម្រួលប្រការចាស់ផង មានការបន្ថែមប្រការស្ទួនផង ប្រការមួយ ត្រូវសរសេរដូចខាងក្រោម ហើយប្រការដែលត្រូវធ្វើការកែសម្រួលនិងបន្ថែម ត្រូវរាយតាមលំដាប់លេខរៀង៖

**ប្រការមួយ .-**

សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ចំណងជើងនៃសេចក្តីសម្រេចដំបូងដែលត្រូវធ្វើការកែសម្រួល) ត្រូវបានធ្វើការកែសម្រួលដោយកែប្រែប្រការ...(លេខប្រការដែលត្រូវធ្វើការកែប្រែ) និងបន្ថែមប្រការ...(លេខប្រការ)ស្ទួន ដូចតទៅ៖

**ប្រការ**...(លេខប្រការដែលត្រូវធ្វើការកែសម្រួល) **.- ថ្មី**

..................................................................................................................................។

**ប្រការ**...(លេខប្រការ) **.- ស្ទួន**

..................................................................................................................................។

**ប្រការពីរ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័នដែលទទួលបន្ទុករៀបចំឬស្នើ) រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.................. ខែ............ ឆ្នាំ......... ......ស័ក ព.ស. .......
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី............ ខែ.......... ឆ្នាំ...............

**នាយករដ្ឋមន្ត្រី**

(ហត្ថលេខានិងត្រា)

**(គោរមងារនិងឈ្មោះ)**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ...(ពាក់ព័ន្ធនឹងក្រសួង ស្ថាប័ន ដែលត្រូវអនុវត្ត)
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

### ៣.២.៧.៥- ទម្រង់នៃបទបញ្ជារបស់រាជរដ្ឋាភិបាល

បទបញ្ជាជាវិធានការចាំបាច់និងចំពោះមុខរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្ត បង្ការ ទប់ស្កាត់ និងបង្ក្រាបដើម្បីដោះស្រាយបានទាន់ពេលនូវរាល់បញ្ហាដែលរាជរដ្ឋាភិបាលបានជួបប្រទះ ហើយតម្រូវឱ្យមានការអនុវត្តយ៉ាងម៉ឺងម៉ាត់ សំដៅធានាសន្តិសុខ សណ្ដាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ។ បទបញ្ជារបស់រាជរដ្ឋាភិបាលជាលិខិតបទដ្ឋានគតិយុត្ត ចេញដោយនាយករដ្ឋមន្ត្រី សម្រាប់ដាក់ឱ្យក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តអនុវត្ត។

បទបញ្ជារបស់រាជរដ្ឋាភិបាលមិនប្រើមូលបទនិងមាត្រាឬប្រការទេ ហើយមានទម្រង់ចែកចេញជា៣ផ្នែក មាន ក្បាលលិខិត ខ្លឹមសារនៃអត្ថបទ និងរូបមន្តបញ្ចប់។

ក- ក្បាលលិខិត ត្រូវប្រើក្រដាសក្បាលលិខិតរបស់រាជរដ្ឋាភិបាល ដែលមានសញ្ញាជាតិ(ដូចក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា)នៅខាងលើចំកណ្ដាលទំព័រ ក្រោមសញ្ញាជាតិ ដាក់ **ព្រះរាជាណាចក្រកម្ពុជា** ក្រោមព្រះរាជាណាចក្រកម្ពុជា ដាក់បាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ** ប៉ែកខាងឆ្វេងក្រោមបន្ទាត់បាវចនា ត្រូវដាក់ **រាជរដ្ឋាភិបាលកម្ពុជា** ក្រោមរាជរដ្ឋាភិបាលកម្ពុជា ដាក់ពាក្យ **លេខ** : ... សម្រាប់ទុកចុះលេខរបស់បទបញ្ជា ដែលមានរូបមន្តអក្សរកាត់ **លេខ** : ... បប។

នៅក្រោមបាវចនា រំលង១បន្ទាត់ ចំកណ្ដាលទំព័រ ត្រូវដាក់ពាក្យ **បទបញ្ជា** ក្រោមពាក្យបទបញ្ជា ដាក់ពាក្យ **ស្ដីពី** ក្រោមពាក្យស្ដីពី ដាក់ចំណងជើងនៃបទបញ្ជា។

ខ- ខ្លឹមសារនៃអត្ថបទ

ខ.១- **សេចក្ដីផ្ដើម** ត្រូវពិពណ៌នាអំពីបញ្ហាឬស្ថានការណ៍ចាំបាច់ចំពោះមុខដែលរាជរដ្ឋាភិបាលបានជួបប្រទះ ហើយតម្រូវឱ្យមានវិធានអនុវត្តយ៉ាងម៉ឺងម៉ាត់ ដើម្បីដោះស្រាយ។

ខ.២- **តួសេចក្ដី** ត្រូវចែងអំពីការបង្ការបញ្ហានិងវិធានការដែលត្រូវអនុវត្តឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ ដែលមានថិរវេលាកំណត់ជាក់លាក់ ឬមួយកំឡុងពេលសម្រាប់អនុវត្ត។

ខ.៣- **អវសានបទ** ត្រូវចែងថា គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តបទបញ្ជានេះឱ្យបានម៉ឺងម៉ាត់បំផុត និងមានប្រសិទ្ធភាពខ្ពស់ ។

គ- **រូបមន្តបញ្ចប់** នៅខាងក្រោមប៉ែកខាងស្ដាំ ត្រូវចុះទីកន្លែង កាលបរិច្ឆេទ ហត្ថលេខា គោរមងារ និងឈ្មោះរបស់នាយករដ្ឋមន្ត្រីឬរបស់នាយករដ្ឋមន្ត្រីស្ដីទី និងបោះត្រារបស់រាជរដ្ឋាភិបាល។

នៅប៉ែកខាងឆ្វេងទំព័រ ត្រូវដាក់ **កន្លែងទទួល** នៅក្រោមកន្លែងទទួល ត្រូវដាក់ឈ្មោះស្ថាប័នសំខាន់ៗដែលត្រូវជូនជ្រាបឬអនុវត្ត ដែលរួមមាន ក្រសួងព្រះបរមរាជវាំង ទីស្ដីការគណៈរដ្ឋមន្ត្រី អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានរដ្ឋសភា គ្រប់ក្រសួង ស្ថាប័ន ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី រដ្ឋបាលរាជធានី ខេត្ត រាជកិច្ច និងឯកសារ កាលប្បវត្តិ។

**សូមមើលគំរូទី៦៥** : ទម្រង់នៃបទបញ្ជារបស់រាជរដ្ឋាភិបាល នៅទំព័រទី១៥៨។

**គំរូទី៦៥**

ទម្រង់នៃបទបញ្ជារបស់រាជរដ្ឋាភិបាល



(សញ្ញាជាតិដូចមានក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ...

**បទបញ្ជា**

**ស្តីពី**

(ចំណងជើងជាពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light)

(សេចក្តីផ្តើម)

រាជរដ្ឋាភិបាលបានសង្កេតឃើញថា... កំពុងជួបនូវបញ្ហា... ដែលទាមទារឱ្យមានដំណោះស្រាយដែលមានប្រសិទ្ធភាព និងត្រូវមានវិធានការ...

(តួសេចក្តី)

(គោលបំណង)ក្នុងគោលបំណងទប់ស្កាត់ បង្ការ និងដោះស្រាយឱ្យបានទាន់ពេលវេលាចំពោះបញ្ហា... រាជរដ្ឋាភិបាលដាក់ចេញបទបញ្ជាដូចខាងក្រោម៖

(ខ្លឹមសារបង្គាប់បញ្ជានិងវិធានការ) ១ - ...។

២ - ...។

(អវសានបទ)

គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ឬអាជ្ញាធរដែលមានសមត្ថកិច្ចពាក់ព័ន្ធ.... ត្រូវអនុវត្តបទបញ្ជានេះឱ្យបានម៉ឺងម៉ាត់បំផុតនិងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ.................. ខែ............ ឆ្នាំ......... ......ស័ក ព.ស. .......

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី............ ខែ.......... ឆ្នាំ...............

**នាយករដ្ឋមន្ត្រី**

(ហត្ថលេខានិងត្រា)

**(គោរមងារនិងឈ្មោះ)**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**៣.២.៧.៦- ទម្រង់នៃសារាចររបស់រាជរដ្ឋាភិបាល**

ជាទូទៅ សារាចរជាលិខិតបទដ្ឋានគតិយុត្តដែលបញ្ជាក់បំភ្លឺចំណុចខ្លឹមសារជាលក្ខណៈច្បាប់ ពន្យល់បកស្រាយលិខិតបទដ្ឋានគតិយុត្តដែលមានលំដាប់ថ្នាក់ខ្ពស់ជាងឬលើកឡើងនូវវិធានការណែនាំសកម្មភាពការងារ ដើម្បីឱ្យអង្គភាពឬមន្ត្រីរាជការថ្នាក់ក្រោមអនុវត្ត។ សារាចររបស់រាជរដ្ឋាភិបាលជាលិខិតបទដ្ឋានគតិយុត្តចេញដោយនាយករដ្ឋមន្ត្រី សម្រាប់ណែនាំឱ្យក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តអនុវត្ត។

សារាចររបស់រាជរដ្ឋាភិបាលមិនប្រើមូលបទនិងមាត្រាឬប្រការទេ ហើយមានទម្រង់ចែកចេញជា៣ផ្នែក មានក្បាលលិខិត ខ្លឹមសារនៃអត្ថបទ និងរូបមន្តបញ្ចប់។

ក- **ក្បាលលិខិត** ត្រូវប្រើក្រដាសក្បាលលិខិតរបស់រាជរដ្ឋាភិបាល ដែលមានសញ្ញាជាតិ(ដូចក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានបោះពុម្ពលើកទី១)នៅខាងលើចំកណ្តាលទំព័រ ក្រោមសញ្ញាជាតិ ដាក់ **ព្រះរាជាណាចក្រកម្ពុជា** ក្រោមព្រះរាជាណាចក្រកម្ពុជា ដាក់បាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ** ប៉ែកខាងឆ្វេងក្រោមបន្ទាត់បាវចនាត្រូវដាក់ **រាជរដ្ឋាភិបាលកម្ពុជា** ក្រោមរាជរដ្ឋាភិបាលកម្ពុជា ដាក់ពាក្យ **លេខ** : ... សម្រាប់ទុកចុះលេខរបស់សារាចរដែលមានរូបមន្តអក្សរកាត់ **លេខ** : ... សរ។

នៅក្រោមបាវចនា រំលង១បន្ទាត់ ចំកណ្តាលទំព័រ ត្រូវដាក់ពាក្យ **សារាចរ** ក្រោមពាក្យសារាចរ ដាក់ពាក្យ **ស្តីពី** ក្រោមពាក្យស្តីពី ដាក់ចំណងជើងនៃសារាចរ។

ខ- **ខ្លឹមសារនៃអត្ថបទ**

ខ.១- **សេចក្តីផ្តើម** ត្រូវយោងទៅរកលិខិតបទដ្ឋានគតិយុត្តដែលត្រូវវិភាគនិងពន្យល់បកស្រាយបញ្ជាក់ខ្លឹមសារឱ្យបានច្បាស់ឬត្រូវបង្ហាញអំពីបញ្ហាដែលបានជួបប្រទះក្នុងការអនុវត្ត ដើម្បីឱ្យការអនុវត្តទទួលបានលទ្ធផលល្អ។

ខ.២- **តួសេចក្តី** ត្រូវចែងអំពីខ្លឹមសារដែលត្រូវបំភ្លឺនិងបកស្រាយឬវិធានការណែនាំដែលត្រូវអនុវត្តឱ្យបានច្បាស់លាស់តាមផ្លូវច្បាប់។

ខ.៣- **អវសានបទ** ត្រូវចែងថា ទទួលបានសារាចរនេះ ទីស្តីការគណៈរដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត(តាមករណីពាក់ព័ន្ធ) ត្រូវ(ផ្សព្វផ្សាយ)អនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់(ហើយរាយការណ៍ពីលទ្ធផលនៃការអនុវត្តមករាជរដ្ឋាភិបាលវិញ)។

គ- **រូបមន្តបញ្ចប់** នៅខាងក្រោមប៉ែកខាងស្តាំ ត្រូវចុះទីកន្លែង កាលបរិច្ឆេទ ហត្ថលេខា គោរមងារ និងឈ្មោះរបស់នាយករដ្ឋមន្ត្រីឬរបស់នាយករដ្ឋមន្ត្រីស្តីទី និងបោះត្រារបស់រាជរដ្ឋាភិបាល។

នៅប៉ែកខាងឆ្វេងទំព័រ ត្រូវដាក់ **កន្លែងទទួល** នៅក្រោមកន្លែងទទួល ត្រូវដាក់ឈ្មោះស្ថាប័នសំខាន់ៗដែលត្រូវជូនជ្រាបឬអនុវត្ត ដែលរួមមាន ក្រសួងព្រះបរមរាជវាំង ទីស្តីការគណៈរដ្ឋមន្ត្រី អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានរដ្ឋសភា គ្រប់ក្រសួង ស្ថាប័ន ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី រដ្ឋបាលរាជធានី ខេត្ត រាជកិច្ច និងឯកសារ កាលប្បវត្តិ។

**សូមមើលគំរូទី៦៦** : ទម្រង់នៃសារាចររបស់រាជរដ្ឋាភិបាល នៅទំព័រទី១៦០។

**គំរូទី៦៦**

ទម្រង់នៃសារាចររបស់រាជរដ្ឋាភិបាល



(សញ្ញាជាតិដូចមានក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ...

**សារាចរ**

**ស្តីពី**

(ចំណងជើងជាពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light)

(សេចក្តីផ្តើម)

កន្លងមក ទោះមានច្បាប់(ឬលិខិតបទដ្ឋានគតិយុត្ត) ស្តីពី... ក៏ដោយ ក៏រាជរដ្ឋាភិបាលសង្កេតឃើញថា...។

(តួសេចក្តី)

(គោលបំណង)ក្នុងករណីនេះ រាជរដ្ឋាភិបាលសូមដាក់ចេញនូវវិធានការណែនាំដូចខាងក្រោម៖

(ខ្លឹមសារណែនាំ) ១ - ...។

២ - ...។

(អវសានបទ)

ទទួលបានសារាចរនេះ ទីស្តីការគណៈរដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត(តាមករណីពាក់ព័ន្ធ) ត្រូវ(ផ្សព្វផ្សាយ)អនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់(ហើយរាយការណ៍ពីលទ្ធផលនៃការអនុវត្តមករាជរដ្ឋាភិបាលវិញ)។

ថ្ងៃ.................. ខែ............ ឆ្នាំ......... ......ស័ក ព.ស. .......

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី............ ខែ.......... ឆ្នាំ...............

**នាយករដ្ឋមន្ត្រី**

(ហត្ថលេខានិងត្រា)

**(គោរមងារនិងឈ្មោះ)**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ៣.២.៨- ទម្រង់នៃប្រកាស ប្រកាសអន្តរក្រសួង ប្រកាសរួម សេចក្តីសម្រេច សារាចរ និងសារាចរអន្តរក្រសួងរបស់ក្រសួង ស្ថាប័ន

### ៣.២.៨.១- ទម្រង់នៃប្រកាស

ប្រកាស ជាលិខិតបទដ្ឋានគតិយុត្តចេញដោយរដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័ន មានវិសាលភាពគ្របដណ្តប់លើវិស័យដែលក្រសួង ស្ថាប័ននោះទទួលបន្ទុក។ ប្រកាសមានពីរប្រភេទគឺ ប្រកាសមានលក្ខណៈជាបទបញ្ញាទូទៅនិងប្រកាសមានលក្ខណៈជាឯកត្តកូត។

ប្រកាសមានលក្ខណៈជាបទបញ្ញាទូទៅ ជាការណែនាំការអនុវត្តឬបញ្ជាក់បន្ថែមខ្លឹមសាររបស់ច្បាប់ ព្រះរាជក្រឹត្យ និងអនុក្រឹត្យ ជាការណែនាំការអនុវត្តកិច្ចការដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន ដូចជាប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះក្រសួង ស្ថាប័ន ប្រកាសស្តីពីវិធានការចាំបាច់មួយចំនួនសម្រាប់គ្រប់គ្រងការនាំចេញ ក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ជាដើម។

ប្រកាសមានលក្ខណៈជាឯកត្តកូត ជាប្រកាសដែលទាក់ទងឬសំដៅចំឈ្មោះបុគ្គល។ ប្រកាសប្រភេទនេះ មានដូចជាប្រកាសស្តីពីការជ្រើសរើសមន្ត្រីឱ្យចូលក្របខ័ណ្ឌនិងធ្វើកម្មសិក្សា ការចាត់ឱ្យមន្ត្រីធ្វើកម្មសិក្សាបន្ថែម ការលុបឈ្មោះមន្ត្រីកម្មសិក្សា ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ការតែងតាំង ការប្រគល់ភារកិច្ច ការផ្ទេរភារកិច្ច ការផ្លាស់មន្ត្រីរាជការ ការដំឡើងឋានន្តរសក្តិ ការបន្ថយឋានន្តរសក្តិ ការដំឡើងថ្នាក់ ការបន្ថយថ្នាក់ ការដកពីមុខតំណែង ការអនុញ្ញាតឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ការអនុញ្ញាតឬការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ការអនុញ្ញាតឱ្យចូលបម្រើការងារឡើងវិញ ការបញ្ចប់ភារកិច្ច ការលុបឈ្មោះឬការបញ្ឈប់ពីការងារ ការដាក់ឱ្យចូលនិវត្តន៍ ការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌប្រភេទ គ ការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា ជាដើម។

ទម្រង់នៃប្រកាសចែកចេញជា៤ផ្នែក មានក្បាលលិខិត មូលបទ ខ្លឹមសារនៃអត្ថបទ និងរូបមន្តបញ្ចប់។

ក- ក្បាលលិខិត ត្រូវប្រើក្រដាសក្បាលលិខិតរបស់ក្រសួង ស្ថាប័នដែលរៀបចំ ដោយនៅផ្នែកខាងលើចំកណ្តាលទំព័រ ដាក់ **ព្រះរាជាណាចក្រកម្ពុជា** ក្រោមព្រះរាជាណាចក្រកម្ពុជា ដាក់បាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ**។ ប៉ែកខាងឆ្វេងក្រោមបាវចនា ដាក់សញ្ញាក្រសួង ស្ថាប័ន ក្រោមសញ្ញា ដាក់ឈ្មោះក្រសួង ស្ថាប័ន ក្រោមឈ្មោះ ដាក់ពាក្យ **លេខ** : ... សម្រាប់ទុកចុះលេខរបស់ប្រកាសដែលមាន រូបមន្តអក្សរកាត់ **លេខ** : ... ប្រក. ... (អក្សរកាត់របស់ក្រសួង ស្ថាប័ន)។

នៅក្រោមបាវចនា រំលង៣បន្ទាត់ ចំកណ្តាលទំព័រ ត្រូវដាក់ពាក្យ **ប្រកាស** ក្រោមពាក្យប្រកាស ដាក់ពាក្យ **ស្តីពី** ក្រោមពាក្យស្តីពី ដាក់ចំណងជើងនៃប្រកាស។

នៅក្រោមចំណងជើង ចំកណ្តាល រំលង១បន្ទាត់ ត្រូវដាក់ **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**... ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**... ឬ**រដ្ឋមន្ត្រីក្រសួង**...(ឬ **ប្រធានស្ថាប័ន**)។

ខ- មូលបទ ត្រូវជ្រើសរើសយោងតែលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងខ្លឹមសារនៃប្រកាស ហើយសរសេរដោយប្រើពាក្យ «បានឃើញ»។ លិខិតបទដ្ឋានគតិយុត្តដែលត្រូវយោងក្នុងប្រកាស មានជាអាទិ៍ រដ្ឋធម្មនុញ្ញ ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង ស្ថាប័នដែលរៀបចំប្រកាស អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័នដែលរៀបចំប្រកាស ហើយនៅចុងក្រោយបង្អស់នៃមូលបទ ត្រូវយោងតាមករណីនីមួយៗនៃសេចក្តី ដោយចែងដូចខាងក្រោម៖

- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់ក្រសួង ស្ថាប័ន ឬ
- យោងតាមសំណើរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានឬប្រធាននាយកដ្ឋាន...(ឈ្មោះអគ្គនាយកដ្ឋាន នាយកដ្ឋានសាមី)។

ជាគោលការណ៍ ប្រកាសមិនត្រូវយោងលិខិតបទដ្ឋានគតិយុត្តដែលមានឋានានុក្រមទាបជាងឡើយ។

នៅខាងក្រោមចំកណ្តាលទំព័រ ត្រូវសរសេរពាក្យ **សម្រេច**

គ- **ខ្លឹមសារនៃអត្ថបទ** អាចចែកជាជំពូកនិងត្រូវប្រើពាក្យ **ប្រការ** ដោយមិនត្រូវប្រើពាក្យ **មាត្រា** ឡើយ។ ជំពូកស្តីពីអវសានប្បញ្ញត្តិចែងពីនិរាករណ៍លិខិតបទដ្ឋានគតិយុត្តនិងបទប្បញ្ញត្តិណាដែលផ្ទុយនឹងប្រកាសនេះ។ ចំពោះប្រការបញ្ចប់ ត្រូវចែងពីការប្រគល់ភារកិច្ចជូនថ្នាក់ដឹកនាំនៃអង្គភាពពាក់ព័ន្ធរបស់ក្រសួង ស្ថាប័ន និងសាមីខ្លួន ដែលត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឃ- **រូបមន្តបញ្ចប់** នៅខាងក្រោមប៉ែកខាងស្តាំ ត្រូវចុះទីកន្លែងនិងកាលបរិច្ឆេទនៃប្រកាស។ នៅក្រោមទីកន្លែងនិងកាលបរិច្ឆេទ ត្រូវដាក់ **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**...ឬ**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**... ឬ **រដ្ឋមន្ត្រីក្រសួង**...(ឬ**ប្រធានស្ថាប័ន**) ហើយនៅខាងក្រោម ត្រូវទុកចន្លោះសម្រាប់ហត្ថលេខានិងឈ្មោះរបស់រដ្ឋមន្ត្រីឬប្រធានស្ថាប័ន។

នៅប៉ែកខាងឆ្វេងទំព័រ ត្រូវដាក់ **កន្លែងទទួល** ដែលរួមមានទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី រដ្ឋបាលរាជធានីខេត្ត(បើចាំបាច់) ដូចប្រការ...(មន្ត្រីនៃអង្គភាពពាក់ព័ន្ធនឹងក្រសួង ស្ថាប័ន ដែលត្រូវអនុវត្ត) រាជកិច្ច និងឯកសារ កាលប្បវត្តិ។

**សូមមើលគំរូទី៦៧** : ទម្រង់នៃប្រកាសមានលក្ខណៈជាបទបញ្ជាទូទៅ នៅទំព័រទី១៦៣ដល់ទំព័រទី១៦៤។

**សូមមើលគំរូទី៦៨** : ទម្រង់នៃប្រកាសមានលក្ខណៈជាឯកត្តភូត នៅទំព័រទី១៦៥ដល់ទំព័រទី១៧២។

**គំរូទី៦៧**

ទម្រង់នៃប្រកាសមានលក្ខណៈជាបទបញ្ញាទូទៅ

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

(សញ្ញាក្រសួង ស្ថាប័ន)

**ក្រសួង** : ... (ឈ្មោះក្រសួង ស្ថាប័ន)

**លេខ** : ...

## ប្រកាស
## ស្ដីពី

(ចំណងជើងជាពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light)

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...ឬទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...**
**ឬរដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័ន)**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី...ខែ...ឆ្នាំ... ស្ដីពីការកែសម្រួល និង/ឬបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬការតែងតាំងសមាជិករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា(ដែលទាក់ទងនឹងរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីដែលរៀបចំសេចក្ដីព្រាង)
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើត...(ឈ្មោះស្ថាប័នសាមី)
- បានឃើញព្រះរាជក្រមលេខ នស/រកម/... (លេខខែឆ្នាំ)/... (លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី...(ដែលពាក់ព័ន្ធ)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្ដីពី...(ដែលពាក់ព័ន្ធ)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់...(ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្ដីពី...(ដែលពាក់ព័ន្ធ)
- បានឃើញសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្ដីពី...(ដែលពាក់ព័ន្ធ)
- បានឃើញសារាចររបស់រាជរដ្ឋាភិបាលលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ... ស្ដីពី...(ដែលពាក់ព័ន្ធ)
- បានឃើញប្រកាសលេខ... ប្រក. ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្ដីពី...(ដែលពាក់ព័ន្ធ)
- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់ក្រសួង ស្ថាប័ន ឬ
- យោងតាមសំណើរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានឬប្រធាននាយកដ្ឋាន...(ឈ្មោះអគ្គនាយកដ្ឋាន នាយកដ្ឋានសាមី)

# សម្រេច

**ប្រការ១ .-**

..........................................................................................................................................................................។

**ប្រការ២ .-**

..........................................................................................................................................................................។

**ប្រការ... .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។
(ប្រការនេះមិនត្រូវចែងទេ ក្នុងករណីជាក់ស្តែងដែលមិនតម្រូវឱ្យនិរាករណ៍លិខិតបទដ្ឋានគតិយុត្តមុនៗដែលពាក់ព័ន្ធ)

**ប្រការ... .-**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋាន...(ដែលទទួលបន្ទុកការងាររដ្ឋបាលនិង/ឬហិរញ្ញវត្ថុនិង/ឬបុគ្គលិក) អគ្គនាយកនៃអគ្គនាយកដ្ឋាន...(ឈ្មោះអគ្គនាយកដ្ឋានជំនាញពាក់ព័ន្ធ) អគ្គាធិការ(ឬប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ អធិការ...) ប្រធានមន្ទីរ... រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ................. ខែ............ ឆ្នាំ......... ......ស័ក ព.ស. .......

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី........... ខែ.......... ឆ្នាំ...............

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ

**រដ្ឋមន្ត្រីក្រសួង...**(**ឬប្រធានស្ថាប័ន**)

(ហត្ថលេខានិងត្រា)

(**គោរមងារនិង/ឬឈ្មោះ**)

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ...
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**គំរូទី៦៨**

ទម្រង់នៃប្រកាសមានលក្ខណៈជាឯកត្តកូត

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

(សញ្ញាក្រសួង ស្ថាប័ន)

**ក្រសួង** : ... (ឈ្មោះក្រសួង ស្ថាប័ន)

**លេខ** : ...

**ប្រកាស**

**ស្តីពី**

(ចំណងជើងជាពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light)

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...**

ឬ**រដ្ឋមន្ត្រីក្រសួង...**(ឬ **ប្រធានស្ថាប័ន**)

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី...ខែ...ឆ្នាំ... ស្តីពីការកែសម្រួល និង/ឬបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬការតែងតាំងសមាជិករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា(ដែលទាក់ទងនឹងរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីដែលរៀបចំសេចក្តីព្រាង)
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត...(ឈ្មោះស្ថាប័នសាមី)
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីលក្ខន្តិកៈដោយឡែកនៃ...(ឈ្មោះក្របខ័ណ្ឌរបស់មន្ត្រីសាមី)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់...(ឈ្មោះស្ថាប័នសាមី)
- បានឃើញអនុក្រឹត្យលេខ... អនក្រ. ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញប្រកាសលេខ... ប្រក. ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី ...(ដែលពាក់ព័ន្ធ)
- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់ក្រសួង ស្ថាប័ន ឬ
- យោងតាមសំណើរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានឬប្រធាននាយកដ្ឋាន...(ឈ្មោះអគ្គនាយកដ្ឋាន នាយកដ្ឋានសាមី)

# សម្រេច

**ប្រការ១ .-**

**ចំពោះប្រកាសស្តីពីការជ្រើសរើសមន្ត្រីឱ្យចូលក្របខ័ណ្ឌនិងធ្វើកម្មសិក្សា ត្រូវចែងដូចតទៅ៖**

ត្រូវបានជ្រើសរើសលោក ... ឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដោយត្រូវធ្វើកម្មសិក្សារយៈពេល...ខែ ឬ

ត្រូវបានជ្រើសរើសមន្ត្រីឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌ... នៅ... ដោយត្រូវធ្វើកម្មសិក្សារយៈពេល...ខែ ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ...។

២- លោក/លោកស្រី ...។

**ចំពោះប្រកាសស្តីពីការចាត់ឱ្យមន្ត្រីធ្វើកម្មសិក្សាបន្ថែម ត្រូវចែងដូចតទៅ៖**

ត្រូវបានចាត់ឱ្យលោក/លោកស្រី ... មន្ត្រីកម្មសិក្សាក្នុងក្របខ័ណ្ឌ... នៅ... ធ្វើកម្មសិក្សាបន្ថែមរយៈពេល...ខែ ដោយមូលហេតុ... ឬ

ត្រូវបានចាត់ឱ្យធ្វើកម្មសិក្សាបន្ថែមរយៈពេល...ខែ មន្ត្រីកម្មសិក្សាក្នុងក្របខ័ណ្ឌ... នៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... ដោយមូលហេតុ...។

២- លោក/លោកស្រី ... ដោយមូលហេតុ...។

**ចំពោះប្រកាសស្តីពីការលុបឈ្មោះមន្ត្រីកម្មសិក្សា ត្រូវចែងដូចតទៅ៖**

ត្រូវបានលុបឈ្មោះលោក/លោកស្រី ... មន្ត្រីកម្មសិក្សាចេញពីក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដោយមូលហេតុ... ឬ

ត្រូវបានលុបឈ្មោះចេញពីក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... មន្ត្រីកម្មសិក្សា ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... ដោយមូលហេតុ...។

២- លោក/លោកស្រី ... ដោយមូលហេតុ...។

**ចំពោះប្រកាសស្តីពីការតាំងស៊ប់មន្ត្រីរាជការក្នុងក្របខ័ណ្ឌ ត្រូវចែងដូចតទៅ៖**

ត្រូវបានតាំងស៊ប់លោក/លោកស្រី ... អត្តលេខ...(បើមាន) ក្នុងក្របខ័ណ្ឌ... ឋានន្តរសក្តិ... ថ្នាក់លេខ... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ឬ

ត្រូវបានតាំងស៊ប់មន្ត្រីរាជការក្នុងក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... អត្តលេខ... (បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... ។

២- លោក/លោកស្រី ... អត្តលេខ... (បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... ។

**ចំពោះប្រកាសស្តីពីការតែងតាំងមន្ត្រីរាជការដើម្បីបំពេញមុខតំណែងសមស្របតាមឧបនិស្ស័យជំនួសមន្ត្រីរាជការណាម្នាក់ ត្រូវចែងដូចតទៅ៖**

ត្រូវបានតែងតាំងលោក/លោកស្រី... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... ជា... នៅ... ជំនួសលោក/លោកស្រី ... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត) ឬ

ត្រូវបានតែងតាំងមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... ជា... ជំនួសលោក/លោកស្រី ... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។

២- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... ជា... ជំនួសលោក/លោកស្រី... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។

**ចំពោះប្រកាសស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការឱ្យបំពេញមុខងារក្នុងមុខតំណែងខ្ពស់ជាងឧបនិស្ស័យជំនួសមន្ត្រីរាជការណាម្នាក់ ត្រូវចែងដូចតទៅ៖**

ត្រូវបានប្រគល់ភារកិច្ចជូនលោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា... នៅ... ជំនួសលោក/លោកស្រី ... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។ ឬ

ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា ... ជំនួសលោក/លោកស្រី ... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។

២- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា ... ជំនួសលោក/លោកស្រី ... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។

**ចំពោះប្រកាសស្តីពីការតែងតាំងមន្ត្រីរាជការ ដើម្បីបំពេញមុខតំណែងសមស្របតាមឧបនិស្ស័យសម្រាប់អង្គភាពបង្កើតថ្មី ត្រូវចែងដូចតទៅ៖**

ត្រូវបានតែងតាំងលោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... ជា... នៅ... ឬ

ត្រូវបានតែងតាំងមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... ជា...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... ជា...។

**ចំពោះប្រកាសស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការឱ្យបំពេញមុខងារក្នុងមុខតំណែងខ្ពស់ជាងឧបនិស្ស័យសម្រាប់អង្គភាពបង្កើតថ្មី ត្រូវចែងដូចតទៅ៖**

ត្រូវបានប្រគល់ភារកិច្ចជូនលោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា... នៅ... ឬ

ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា...។

២- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា...។

**ចំពោះប្រកាសស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ(ផ្ទៃក្នុង) ត្រូវចែងដូចតទៅ៖**

ត្រូវបានផ្ទេរភារកិច្ចលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... ពី... (មុខតំណែង) ទៅជា...(មុខតំណែង) នៅ... ឬ

ត្រូវបានផ្ទេរភារកិច្ចមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... ពី...(មុខតំណែង) ទៅជា...(មុខតំណែង)។

២- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... ពី...(មុខតំណែង) ទៅជា...(មុខតំណែង)។

**ចំពោះប្រកាសស្តីពីការផ្លាស់មន្ត្រីរាជការ ត្រូវចែងដូចតទៅ៖**

ត្រូវបានផ្លាស់លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... បច្ចុប្បន្ននៅ... ឱ្យទៅបម្រើការងារនៅ... ឬ

ត្រូវបានផ្លាស់មន្ត្រីរាជការ ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... បច្ចុប្បន្ននៅ... ឱ្យទៅបម្រើការងារនៅ...។

២- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... បច្ចុប្បន្ននៅ... ឱ្យទៅបម្រើការងារនៅ...។

**ចំពោះប្រកាសស្តីពីការដំឡើងឋានន្តរសក្តិមន្ត្រីរាជការ ត្រូវចែងដូចតទៅៈ**

ត្រូវបានដំឡើងឋានន្តរសក្តិលោក/លោកស្រី ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... ទៅឋានន្តរសក្តិ ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ... ឬ

ត្រូវបានដំឡើងឋានន្តរសក្តិមន្ត្រីរាជការនៃក្របខ័ណ្ឌ... ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ... ដូចមានរាយនាមខាងក្រោមៈ

១- លោក/លោកស្រី ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... ទៅឋានន្តរសក្តិ... ថ្នាក់លេខ... នៅ ...។

២- លោក/លោកស្រី ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... ទៅឋានន្តរសក្តិ... ថ្នាក់លេខ... នៅ ...។

**ចំពោះប្រកាសស្តីពីការដំឡើងឋានន្តរសក្តិកិត្តិយសជូនមន្ត្រីរាជការ ត្រូវចែងដូចតទៅៈ**

ត្រូវបានដំឡើងឋានន្តរសក្តិកិត្តិយសជូនលោក/លោកស្រី ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... ទៅឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... នៅ... ដែលបាន... (ចូលនិវត្តន៍ ឬលាលែង ឬដាក់ឱ្យឈប់ពីការងារដោយបាត់បង់សមត្ថភាពការងារ ឬទទួលមរណភាព ជាកិច្ចបប្ចាមរណៈ) ឬ

ត្រូវបានដំឡើងឋានន្តរសក្តិកិត្តិយសជូនមន្ត្រីរាជការនៃក្របខ័ណ្ឌ... ដូចមានរាយនាមខាងក្រោមៈ

១- លោក/លោកស្រី ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... ទៅឋានន្តរសក្តិ... ថ្នាក់លេខ... នៅ ... ដែលបាន...(ចូលនិវត្តន៍ ឬលាលែង ឬដាក់ឱ្យឈប់ពីការងារដោយបាត់បង់សមត្ថភាពការងារ ឬទទួលមរណភាព ជាកិច្ចបប្ចាមរណៈ)។

២- លោក/លោកស្រី ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... ទៅឋានន្តរសក្តិ... ថ្នាក់លេខ... នៅ ... ដែលបាន...(ចូលនិវត្តន៍ ឬលាលែង ឬដាក់ឱ្យឈប់ពីការងារដោយបាត់បង់សមត្ថភាពការងារ ឬទទួលមរណភាព ជាកិច្ចបប្ចាមរណៈ)។

**ចំពោះប្រកាសស្តីពីការបន្ថយឋានន្តរសក្តិមន្ត្រីរាជការ ត្រូវចែងដូចតទៅៈ**

ត្រូវបានបន្ថយឋានន្តរសក្តិលោក/លោកស្រី ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... មកឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... នៅ... ដោយមូលហេតុ... ឬ

ត្រូវបានបន្ថយឋានន្តរសក្តិមន្ត្រីរាជការនៃក្របខ័ណ្ឌ... ដូចមានរាយនាមខាងក្រោមៈ

១- លោក/លោកស្រី ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... មកឋានន្តរសក្តិ... ថ្នាក់លេខ... នៅ... ដោយមូលហេតុ...។

២- លោក/លោកស្រី ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... មកឋានន្តរសក្តិ... ថ្នាក់លេខ... នៅ... ដោយមូលហេតុ...។

**ចំពោះប្រកាសស្តីពីការដំឡើងថ្នាក់មន្ត្រីរាជការតាមវេនជ្រើសរើសនិងវេនអតីតភាព ត្រូវចែងដូចតទៅៈ**

ត្រូវបានដំឡើងថ្នាក់លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ...នៃក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ... ឬ

ត្រូវបានដំឡើងថ្នាក់មន្ត្រីរាជការនៃក្របខ័ណ្ឌ... ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ... ដូចមានរាយនាមខាងក្រោមៈ

១- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៅ...។

២- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៅ...។

**ចំពោះប្រកាសស្តីពីការដំឡើងថ្នាក់មន្ត្រីរាជការ ដែលទទួលបានសញ្ញាបត្រខ្ពស់ជាងការកំណត់ក្នុងក្របខ័ណ្ឌ ត្រូវចែងដូចតទៅៈ**

ត្រូវបានដំឡើងថ្នាក់លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ...នៃក្របខ័ណ្ឌ... នៅ... ដោយរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើសនិងវេនអតីតភាព ឬ

ត្រូវបានដំឡើងថ្នាក់មន្ត្រីរាជការនៃក្របខ័ណ្ឌ...ដោយរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើស និងវេនអតីតភាព ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៅ...។

២- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៅ...។

**ចំពោះប្រកាសស្តីពីការបន្ថយថ្នាក់មន្ត្រីរាជការ ត្រូវចែងដូចតទៅ៖**

ត្រូវបានបន្ថយថ្នាក់លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... មកថ្នាក់លេខ...នៃក្របខ័ណ្ឌ... នៅ... ដោយមូលហេតុ... ឬ

ត្រូវបានបន្ថយថ្នាក់មន្ត្រីរាជការនៃក្របខ័ណ្ឌ... ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... មកថ្នាក់លេខ... នៅ... ដោយមូលហេតុ...។

២- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... មកថ្នាក់លេខ... នៅ... ដោយមូលហេតុ...។

**ចំពោះប្រកាសស្តីពីការដកមន្ត្រីរាជការពីមុខតំណែង ត្រូវចែងដូចតទៅ៖**

ត្រូវបានដកលោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... នៅ... ចេញពីមុខតំណែង... ដោយមូលហេតុ... ឬ

ត្រូវបានដកមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... ចេញពីមុខតំណែង... ដោយមូលហេតុ...។

២- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... ចេញពីមុខតំណែង... ដោយមូលហេតុ...។

**ចំពោះប្រកាសស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការស្ថិតនៅក្រៅក្របខ័ណ្ឌដើម ត្រូវចែងដូចតទៅ៖**

ត្រូវបានអនុញ្ញាតឱ្យលោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដើម្បី... ឬ

ត្រូវបានអនុញ្ញាតឱ្យមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... មុខតំណែង... ស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដើម្បី...។

២- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... មុខតំណែង... ស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដើម្បី...។

**ចំពោះប្រកាសស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការចូលបម្រើការងារឡើងវិញ ក្រោយពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម ត្រូវចែងដូចតទៅ៖**

ត្រូវបានអនុញ្ញាតឱ្យលោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... នៅ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬ

ត្រូវបានអនុញ្ញាតឱ្យមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម។

២- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម។

**ចំពោះប្រកាសស្តីពីការអនុញ្ញាតឬការដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សត្រូវចែងដូចតទៅ៖**

ត្រូវបានអនុញ្ញាតឬត្រូវបានដាក់លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... (តាមសំណើឬដោយមូលហេតុ...) ឬ

ត្រូវបានអនុញ្ញាតឬត្រូវបានដាក់មន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... មុខតំណែង... ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស រយៈពេល... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... (តាមសំណើឬដោយមូលហេតុ...)។

២- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... មុខតំណែង... ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស រយៈពេល... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... (តាមសំណើឬដោយមូលហេតុ...)។

**ចំពោះប្រកាសស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការចូលបម្រើការងារឡើងវិញ ក្រោយពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ត្រូវចែងដូចតទៅ៖**

ត្រូវបានអនុញ្ញាតឱ្យលោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... នៅ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស រយៈពេល... ឬ

ត្រូវបានអនុញ្ញាតឱ្យមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស រយៈពេល...។

២- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស រយៈពេល...។

**ចំពោះប្រកាសស្តីពីការបញ្ចប់ភារកិច្ចមន្ត្រីរាជការ ត្រូវចែងដូចតទៅ៖**

ត្រូវបានបញ្ចប់ភារកិច្ចលោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ឱ្យទៅបម្រើការងារនៅស្ថាប័នដើមវិញ(បើជាមន្ត្រីមានក្របខ័ណ្ឌ) ឬ

ត្រូវបានបញ្ចប់ភារកិច្ចមន្ត្រីរាជការឱ្យទៅបម្រើការងារនៅស្ថាប័នដើមវិញ ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... (បើជាមន្ត្រី មានក្របខ័ណ្ឌ)។

២- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... (បើជាមន្ត្រី មានក្របខ័ណ្ឌ)។

**ចំពោះប្រកាសស្តីពីការលុបឈ្មោះឬបញ្ឈប់មន្ត្រីរាជការពីការងារ ត្រូវចែងដូចតទៅ៖**

ត្រូវបានលុបឈ្មោះឬត្រូវបានបញ្ឈប់លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ដោយមូលហេតុ... ឬ

ត្រូវបានលុបឈ្មោះឬត្រូវបានបញ្ឈប់មន្ត្រីរាជការ ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ដោយមូលហេតុ...។

២- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ដោយមូលហេតុ...។

**ចំពោះប្រកាសស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ត្រូវចែងដូចតទៅ៖**

ត្រូវបានដាក់លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ឱ្យចូលនិវត្តន៍ ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ឬ

ត្រូវបានដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។

២- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។

**ចំពោះប្រកាសស្តីពីការអនុញ្ញាតឬការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍មុនកំណត់ ត្រូវចែងដូចតទៅ៖**

ត្រូវបានអនុញ្ញាតឬត្រូវបានដាក់លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ឱ្យចូលនិវត្តន៍មុនកំណត់(តាមសំណើរបស់សាមីខ្លួនឬដោយមូលហេតុ...) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។ ឬ

ត្រូវបានអនុញ្ញាតឬត្រូវបានដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍មុនកំណត់ ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... (តាមសំណើរបស់សាមីខ្លួនឬដោយមូលហេតុ...) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។

២- លោក/លោកស្រី ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... (តាមសំណើរបស់សាមីខ្លួនឬដោយមូលហេតុ...) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។

**ចំពោះប្រកាសស្តីពីសមាហរណកម្មមន្ត្រីរាជការក្នុងក្របខ័ណ្ឌប្រភេទ គ ត្រូវចែងដូចតទៅ៖**

ត្រូវបានធ្វើសមាហរណកម្មលោក/លោកស្រី ... ទៅក្នុងក្របខ័ណ្ឌ... ឋានន្តរសក្តិ... ថ្នាក់លេខ... អត្តលេខ... (បើមាន) នៅ... ឬ

ត្រូវបានធ្វើសមាហរណកម្មមន្ត្រីរាជការទៅក្នុងក្របខ័ណ្ឌ... នៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... ឋានន្តរសក្តិ... ថ្នាក់លេខ... អត្តលេខ...(បើមាន)។

២- លោក/លោកស្រី ... ឋានន្តរសក្តិ... ថ្នាក់លេខ... អត្តលេខ...(បើមាន)។

**ចំពោះប្រកាសស្តីពីការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា ត្រូវចែងដូចតទៅ៖**

ត្រូវបានជ្រើសរើសលោក/លោកស្រី ... ឱ្យចូលបម្រើការងារជាមន្ត្រីជាប់កិច្ចសន្យានៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដោយទទួលប្រាក់កម្រៃចំនួន...រៀលក្នុងមួយខែ ឬ

ត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារជាមន្ត្រីជាប់កិច្ចសន្យាចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដោយទទួលប្រាក់កម្រៃចំនួន...រៀលក្នុងមួយខែ ដូចមានរាយនាមខាងក្រោម៖

១- លោក/លោកស្រី ... នៅ...។

២- លោក/លោកស្រី ... នៅ...។

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

(ប្រការនេះមិនត្រូវចែងទេ ក្នុងករណីជាក់ស្តែងដែលមិនតម្រូវឱ្យនិរាករណ៍លិខិតបទដ្ឋានគតិយុត្តមុនៗដែលពាក់ព័ន្ធ)

**ប្រការ៣ ._**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋាន...(ដែលទទួលបន្ទុកការងាររដ្ឋបាលនិង/ឬហិរញ្ញវត្ថុនិង/ឬបុគ្គលិក) អគ្គនាយកនៃអគ្គនាយកដ្ឋាន...(ឈ្មោះអគ្គនាយកដ្ឋានជំនាញពាក់ព័ន្ធ) អគ្គាធិការ(ឬប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ អធិការ...) ប្រធានមន្ទីរ...រាជធានី ខេត្ត និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.................. ខែ............ ឆ្នាំ......... ......ស័ក ព.ស. .......
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី............ ខែ.......... ឆ្នាំ...............

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ
**រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័ន)**
(ហត្ថលេខានិងត្រា)
(**គោរមងារនិង/ឬឈ្មោះ**)

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ...
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**៣.២.៨.២- ទម្រង់នៃប្រកាសអន្តរក្រសួង**

ប្រកាសអន្តរក្រសួង ជាប្រកាសដែលធ្វើឡើងរវាងក្រសួងនិងក្រសួង ដោយចែងពីការចាត់វិធានការដោះស្រាយបញ្ហារួម តម្រូវឱ្យមានការសហការដោះស្រាយឬចាត់វិធានការដោយក្រសួងនិងក្រសួង២ឬ៣ ដើម្បីអនុវត្តបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងហត្ថលេខី។ ក្នុងករណីមានការពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងលើសពី៣ ត្រូវរៀបចំជាអនុក្រឹត្យ។

ដូចប្រកាសដែរ ប្រកាសអន្តរក្រសួងមានលក្ខណៈជាបទបញ្ជាទូទៅនិងជាឯកត្តកូត។

ទម្រង់នៃប្រកាសអន្តរក្រសួងចែកចេញជា៤ផ្នែក មានក្បាលលិខិត មូលបទ ខ្លឹមសារនៃអត្ថបទ និងរូបមន្តបញ្ចប់។

ក- **ក្បាលលិខិត** ត្រូវប្រើក្រដាសក្បាលលិខិតរបស់ក្រសួងដើម ដោយនៅផ្នែកខាងលើចំកណ្តាលទំព័រដាក់ **ព្រះរាជាណាចក្រកម្ពុជា** ក្រោមព្រះរាជាណាចក្រកម្ពុជា ដាក់បាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ**។ ប៉ែកខាងឆ្វេងក្រោមបាវចនា ដាក់សញ្ញាក្រសួងដើម ក្រោមសញ្ញា ដាក់ឈ្មោះក្រសួងដើមនៅប៉ែកខាងឆ្វេង និងដាក់ឈ្មោះក្រសួងដែលចូលរួមនៅប៉ែកខាងស្តាំ(ក្នុងករណីមាន២ក្រសួង) ឬនៅចំកណ្តាលនិងនៅប៉ែកខាងស្តាំ ដោយផ្អែកទៅតាមទំហំសមត្ថកិច្ចពាក់ព័ន្ធ(ក្នុងករណីមាន៣ក្រសួង)។ នៅក្រោមឈ្មោះក្រសួងដើម ដាក់ពាក្យ **លេខ** : ... សម្រាប់ទុកចុះលេខរបស់ប្រកាសអន្តរក្រសួងដែលមានរូបមន្តអក្សរកាត់ **លេខ** : ... ប្រក. ... (អក្សរកាត់របស់ក្រសួងដើម)។ លេខប្រកាសអន្តរក្រសួងត្រូវយកលេខរបស់ក្រសួងដើម។ ក្រសួងដែលមានសមត្ថកិច្ចពាក់ព័ន្ធច្រើនជាងគេ ជាក្រសួងដើមដែលត្រូវទទួលបន្ទុករៀបចំប្រកាសអន្តរក្រសួងនេះ។

នៅក្រោមបាវចនា រំលង៣បន្ទាត់ ចំកណ្តាលទំព័រ ត្រូវដាក់ពាក្យ **ប្រកាសអន្តរក្រសួង** ក្រោមពាក្យប្រកាសអន្តរក្រសួង ដាក់ពាក្យ **ស្តីពី** ក្រោមពាក្យស្តីពី ដាក់ចំណងជើងនៃប្រកាសអន្តរក្រសួង។

នៅក្រោមចំណងជើង ចំកណ្តាល រំលង១បន្ទាត់ ត្រូវដាក់ **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ**រដ្ឋមន្ត្រីក្រសួង...** (រដ្ឋមន្ត្រីទាំងអស់ដែលចេញប្រកាសអន្តរក្រសួងនេះ ដោយត្រូវដាក់ពីឆ្វេងទៅស្តាំតាមទំហំសមត្ថកិច្ចពាក់ព័ន្ធ)។

ខ- **មូលបទ** ត្រូវជ្រើសរើសយោងតែលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងខ្លឹមសារនៃប្រកាសអន្តរក្រសួង ហើយសរសេរដោយប្រើពាក្យ «បានឃើញ»។ លិខិតបទដ្ឋានគតិយុត្តដែលត្រូវយោងក្នុងប្រកាសអន្តរក្រសួង មានជាអាទិ៍ រដ្ឋធម្មនុញ្ញ ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងដែលទទួលបន្ទុករៀបចំ និងចូលរួមរៀបចំប្រកាសអន្តរក្រសួង អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងដែលទទួលបន្ទុករៀបចំនិងចូលរួមរៀបចំប្រកាសអន្តរក្រសួង ហើយនៅចុងក្រោយបង្អស់នៃមូលបទ ត្រូវយោងតាមករណីនីមួយៗនៃសេចក្តី ដោយចែងដូចខាងក្រោម៖

- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់ក្រសួង...(ឈ្មោះក្រសួងរៀបចំប្រកាសអន្តរក្រសួងនេះ) ឬ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួង... (ឈ្មោះក្រសួងសាមី)។

ជាគោលការណ៍ ប្រកាសអន្តរក្រសួងមិនត្រូវយោងលិខិតបទដ្ឋានគតិយុត្តដែលមានឋានានុក្រមទាបជាងឡើយ។

នៅខាងក្រោម ចំកណ្តាលទំព័រ ត្រូវសរសេរពាក្យ **សម្រេច**

គ- **ខ្លឹមសារនៃអត្ថបទ** អាចចែកជាជំពូកនិងត្រូវប្រើពាក្យ **ប្រការ** ដោយមិនត្រូវប្រើពាក្យ **មាត្រា** ឡើយ។ ជំពូកស្តីពីអវសានប្បញ្ញត្តិ ចែងពីនិរាករណ៍លិខិតបទដ្ឋានគតិយុត្តនិងបទប្បញ្ញត្តិណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ។ ចំពោះប្រការបញ្ចប់ ត្រូវចែងពីការប្រគល់ភារកិច្ចជូនថ្នាក់ដឹកនាំនៃអង្គភាពពាក់ព័ន្ធនឹងក្រសួងទាំងនេះ ដែលត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួង ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

យ- **រូបមន្តបញ្ចប់** នៅខាងក្រោមប៉ែកខាងស្តាំ ត្រូវចុះទីកន្លែងនិងកាលបរិច្ឆេទនៃប្រកាសអន្តរក្រសួង។ នៅក្រោមទីកន្លែងនិងកាលបរិច្ឆេទ ស្របតាមទីតាំងនៅក្បាលលិខិត ត្រូវដាក់ **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ**រដ្ឋមន្ត្រីក្រសួង...** ហើយនៅខាងក្រោម ត្រូវទុកចន្លោះ សម្រាប់ហត្ថលេខានិងឈ្មោះរបស់រដ្ឋមន្ត្រីទាំងនោះ។

នៅប៉ែកខាងឆ្វេងទំព័រ ត្រូវដាក់ **កន្លែងទទួល** ដែលរួមមាន ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី រដ្ឋបាលរាជធានី ខេត្ត(បើចាំបាច់) ដូចប្រការ...(មន្ត្រីនៃអង្គភាពពាក់ព័ន្ធនឹងក្រសួងដែលត្រូវអនុវត្ត) រាជកិច្ច និងឯកសារ កាលប្បវត្តិ។

នាយកដ្ឋានរដ្ឋបាលនៃក្រសួងដើម មានភារកិច្ចចុះលេខនិងកាលបរិច្ឆេទលើប្រកាសអន្តរក្រសួង ហើយបោះត្រារបស់ក្រសួងទាំងអស់ដែលរៀបចំប្រកាសអន្តរក្រសួង នៅតាមជ្រុងរឹមខាងក្រោមលើគ្រប់សន្លឹកស្របតាមកន្លែងចុះហត្ថលេខារបស់រដ្ឋមន្ត្រីនីមួយៗនៃប្រកាសអន្តរក្រសួង លើកលែងតែសន្លឹកទំព័រដែលមានហត្ថលេខារបស់រដ្ឋមន្ត្រីសាមីនៃប្រកាសអន្តរក្រសួងនេះ។

**សូមមើលគំរូទី៦៩** : ទម្រង់នៃប្រកាសអន្តរក្រសួង នៅទំព័រទី១៧៥ដល់ទំព័រទី១៧៦។

### ៣.២.៨.៣- ទម្រង់នៃប្រកាសរួម

ប្រកាសរួម ជាប្រកាសដែលធ្វើឡើងរវាងក្រសួងជាមួយនឹងស្ថាប័ន(ស្ថាប័នដែលបង្កើតដោយច្បាប់និងមានសិទ្ធិចេញប្រកាស) ឬរវាងស្ថាប័នជាមួយនឹងស្ថាប័ន ដែលចែងពីការចាត់វិធានការដោះស្រាយបញ្ហារួម តម្រូវឱ្យមានការសហការដោះស្រាយឬចាត់វិធានការដោយក្រសួង ស្ថាប័ន២ឬ៣ ដើម្បីអនុវត្តបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នហត្ថលេខី។ ក្នុងករណីមានការពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នលើសពី៣ ត្រូវរៀបចំជាអនុក្រឹត្យ។

ដូចប្រកាសដែរ ប្រកាសរួមមានលក្ខណៈជាបទបញ្ជាទូទៅនិងជាឯកត្តភូត។

ទម្រង់នៃប្រកាសរួមត្រូវអនុវត្តដូចប្រកាសអន្តរក្រសួងដែរ។

**សូមមើលគំរូទី៧០** : ទម្រង់នៃប្រកាសរួម នៅទំព័រទី១៧៧ដល់ទំព័រទី១៧៨។

**គំរូទី៦៩**

ទម្រង់នៃប្រកាសអន្តរក្រសួង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

(សញ្ញាក្រសួងដើម)

**ក្រសួង** : ... (ឈ្មោះក្រសួង) **ក្រសួង**... **ក្រសួង**...

**លេខ** : ... (អក្សរកាត់របស់ក្រសួងដើម)

**ប្រកាសអន្តរក្រសួង**

**ស្តីពី**

(ចំណងជើងជាពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light)

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬ រដ្ឋមន្ត្រីក្រសួង...**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬ រដ្ឋមន្ត្រីក្រសួង...**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬ រដ្ឋមន្ត្រីក្រសួង...**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី...ខែ...ឆ្នាំ... ស្តីពីការកែសម្រួល និង/ឬបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬការតែងតាំងសមាជិករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា(ដែលទាក់ទងនឹងរដ្ឋមន្ត្រីសាមីដែលរៀបចំសេចក្តីព្រាង)
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង...(ឈ្មោះក្រសួងដើមដែលរៀបចំ និងព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផ្សេងទៀតដែលចូលរួមរៀបចំប្រកាសអន្តរក្រសួង)
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង... (ឈ្មោះក្រសួងដើមដែលរៀបចំ និងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផ្សេងទៀត ដែលចូលរួមរៀបចំប្រកាសអន្តរក្រសួង)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញសារាចររបស់រាជរដ្ឋាភិបាលលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់ក្រសួង...(ឈ្មោះក្រសួងរៀបចំប្រកាសអន្តរក្រសួងនេះ) ឬ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួង...(ឈ្មោះក្រសួងសាមី)

# សម្រេច

**ប្រការ១ .-**

.............................................................................................................................។

**ប្រការ២ .-**

.............................................................................................................................។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។ (ប្រការនេះមិនត្រូវចែងទេ ក្នុងករណីជាក់ស្តែងដែលមិនតម្រូវឱ្យនិរាករណ៍លិខិតបទដ្ឋានគតិយុត្តមុនៗដែលពាក់ព័ន្ធ)

**ប្រការ៤ .-**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋាន...(ដែលទទួលបន្ទុកការងាររដ្ឋបាលនិង/ឬហិរញ្ញវត្ថុនិង/ឬបុគ្គលិក) អគ្គនាយកនៃអគ្គនាយកដ្ឋាន...(ឈ្មោះអគ្គនាយកដ្ឋានជំនាញ) អគ្គាធិការ(ឬប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ អធិការ...)នៃក្រសួង...និងក្រសួង... ប្រធានមន្ទីរ... រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.................. ខែ........ ឆ្នាំ....... .....ស័ក ព.ស. .....
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី......... ខែ......... ឆ្នាំ............

| | | |
|---|---|---|
| **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **រដ្ឋមន្ត្រីក្រសួង...** | **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...**ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...**ឬ **រដ្ឋមន្ត្រីក្រសួង...** | **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...**ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **រដ្ឋមន្ត្រីក្រសួង...** |
| (ហត្ថលេខានិងត្រា) | (ហត្ថលេខានិងត្រា) | (ហត្ថលេខានិងត្រា) |
| (**គោរមងារនិង/ឬឈ្មោះ**) | (**គោរមងារនិង/ឬឈ្មោះ**) | (**គោរមងារនិង/ឬឈ្មោះ**) |

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ...
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**គំរូទី៧០**

ទម្រង់នៃប្រកាសរួម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

(សញ្ញាក្រសួង/ស្ថាប័នដើម)

**ក្រសួង/ស្ថាប័ន** : ... (ឈ្មោះក្រសួង/ស្ថាប័ន) **ក្រសួង/ស្ថាប័ន...** **ក្រសួង/ស្ថាប័ន...**

**លេខ** : ... (អក្សរកាត់របស់ក្រសួង/ស្ថាប័នដើម)

**ប្រកាសរួម**

**ស្ដីពី**

(ចំណងជើងជាពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light)

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **រដ្ឋមន្ត្រីក្រសួង...**(ឬ**ប្រធានស្ថាប័ន**)

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **រដ្ឋមន្ត្រីក្រសួង...**(ឬ**ប្រធានស្ថាប័ន**)

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **រដ្ឋមន្ត្រីក្រសួង...**(ឬ**ប្រធានស្ថាប័ន**)

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី...ខែ...ឆ្នាំ... ស្ដីពីការកែសម្រួល និង/ឬបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬការតែងតាំងសមាជិករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា(ដែលទាក់ទងនឹងរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីដែលរៀបចំសេចក្ដីព្រាង)
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួង/ស្ថាប័ន...(ឈ្មោះក្រសួង/ស្ថាប័នដើមដែលរៀបចំ និងព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួង/ស្ថាប័នផ្សេងទៀតដែលចូលរួមរៀបចំប្រកាសរួម)
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី...(ដែលពាក់ព័ន្ធ)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្ដីពី...(ដែលពាក់ព័ន្ធ)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង/ស្ថាប័ន...(ឈ្មោះក្រសួង/ស្ថាប័នដើមដែលរៀបចំ និងអនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង/ស្ថាប័នផ្សេងទៀត ដែលចូលរួមរៀបចំប្រកាសរួម)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្ដីពី...(ដែលពាក់ព័ន្ធ)
- បានឃើញសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្ដីពី...(ដែលពាក់ព័ន្ធ)
- បានឃើញសារាចររបស់រាជរដ្ឋាភិបាលលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្ដីពី...(ដែលពាក់ព័ន្ធ)
- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់ក្រសួង/ស្ថាប័ន...(ឈ្មោះក្រសួង/ស្ថាប័នរៀបចំប្រកាសរួមនេះ) ឬ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួង/ស្ថាប័ន...(ឈ្មោះក្រសួង/ស្ថាប័នសាមី)

# **សម្រេច**

**ប្រការ១ .–**

..................................................................................................................................។

**ប្រការ២ .–**

..................................................................................................................................។

**ប្រការ៣ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

(ប្រការនេះមិនត្រូវចែងទេ ក្នុងករណីជាក់ស្តែងដែលមិនតម្រូវឱ្យនិរាករណ៍លិខិតបទដ្ឋានគតិយុត្តមុនៗដែលពាក់ព័ន្ធ)

**ប្រការ៤ .–**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋាន...(ដែលទទួលបន្ទុកការងាររដ្ឋបាលនិង/ឬហិរញ្ញវត្ថុនិង/ឬបុគ្គលិក) អគ្គនាយកនៃអគ្គនាយកដ្ឋាន...(ឈ្មោះអគ្គនាយកដ្ឋានជំនាញ) អគ្គាធិការ(ឬប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ អធិការ...)នៃក្រសួង...និងក្រសួង... ប្រធានមន្ទីរ... រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.................. ខែ........ ឆ្នាំ....... .....ស័ក ព.ស. .....

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី......... ខែ......... ឆ្នាំ...........

| | | |
|---|---|---|
| **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬ រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័ន)** | **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...ឬ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...ឬ រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័ន)** | **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...ឬ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬ រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័ន)** |
| (ហត្ថលេខានិងត្រា) | (ហត្ថលេខានិងត្រា ) | (ហត្ថលេខានិងត្រា ) |
| **(គោរមងារនិង/ឬឈ្មោះ)** | **(គោរមងារនិង/ឬឈ្មោះ)** | **(គោរមងារនិង/ឬឈ្មោះ)** |

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ...
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

### ៣.២.៨.៤- ទម្រង់នៃសេចក្តីសម្រេចរបស់ក្រសួង ស្ថាប័ន

សេចក្តីសម្រេចរបស់ក្រសួង ស្ថាប័ន ជាលិខិតបទដ្ឋានគតិយុត្តមានទម្រង់និងខ្លឹមសារជាចំណាត់ការរបស់ក្រសួង ស្ថាប័ន ដែលប្រើចំពោះការងារមានវិសាលភាពនិងលក្ខណៈមិនស្ថិតស្ថេរយូរអង្វែង។

ទម្រង់នៃសេចក្តីសម្រេចរបស់ក្រសួង ស្ថាប័នចែកចេញជា៤ផ្នែក មានក្បាលលិខិត មូលបទ ខ្លឹមសារនៃអត្ថបទ និងរូបមន្តបញ្ចប់។

ក- ក្បាលលិខិត ត្រូវប្រើក្រដាសក្បាលលិខិតរបស់ក្រសួង ស្ថាប័នដែលរៀបចំ ដោយនៅផ្នែកខាងលើចំកណ្តាលទំព័រ ដាក់ **ព្រះរាជាណាចក្រកម្ពុជា** ក្រោមព្រះរាជាណាចក្រកម្ពុជា ដាក់បាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ**។ ប៉ែកខាងឆ្វេងក្រោមបាវចនា ដាក់សញ្ញាក្រសួង ស្ថាប័ន ក្រោមសញ្ញា ដាក់ឈ្មោះក្រសួង ស្ថាប័ន ក្រោមឈ្មោះដាក់ពាក្យ **លេខ** : ... សម្រាប់ទុកចុះលេខរបស់សេចក្តីសម្រេចដែលមានរូបមន្តអក្សរកាត់ **លេខ** : ... សសរ ...(អក្សរកាត់របស់ក្រសួង ស្ថាប័ន)។

នៅក្រោមបាវចនា រំលង៣បន្ទាត់ ចំកណ្តាលទំព័រ ត្រូវដាក់ពាក្យ **សេចក្តីសម្រេច** ក្រោមពាក្យសេចក្តីសម្រេច ដាក់ពាក្យ **ស្តីពី** ក្រោមពាក្យស្តីពី ដាក់ចំណងជើងនៃសេចក្តីសម្រេច។

នៅក្រោមចំណងជើង ចំកណ្តាល រំលង១បន្ទាត់ ត្រូវដាក់ **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**... ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**... ឬ**រដ្ឋមន្ត្រីក្រសួង**...(ឬ**ប្រធានស្ថាប័ន**)។

ខ- មូលបទ ត្រូវជ្រើសរើសយោងតែលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងខ្លឹមសារនៃសេចក្តីសម្រេច ហើយសរសេរដោយប្រើពាក្យ «បានឃើញ»។ លិខិតបទដ្ឋានគតិយុត្តដែលត្រូវយោងក្នុងសេចក្តីសម្រេច មានជាអាទិ៍ រដ្ឋធម្មនុញ្ញ ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង ស្ថាប័ន អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន ហើយនៅចុងក្រោយបង្អស់នៃមូលបទ ត្រូវយោងតាមករណីនីមួយៗនៃសេចក្តីដោយចែងដូចខាងក្រោម៖

- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់ក្រសួង ស្ថាប័ន ឬ
- យោងតាមសំណើរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានឬប្រធាននាយកដ្ឋាន...(ឈ្មោះអគ្គនាយកដ្ឋាន នាយកដ្ឋានសាមី)។

ជាគោលការណ៍ សេចក្តីសម្រេចមិនត្រូវយោងលិខិតបទដ្ឋានគតិយុត្តដែលមានឋានានុក្រមទាបជាងឡើយ។

នៅខាងក្រោម ចំកណ្តាលទំព័រ ត្រូវសរសេរពាក្យ **សម្រេច**

គ- ខ្លឹមសារនៃអត្ថបទ ត្រូវប្រើពាក្យ **ប្រការ** ដោយមិនត្រូវប្រើពាក្យ **មាត្រា** ឡើយ។ ចំពោះប្រការបញ្ចប់ត្រូវចែងពីការប្រគល់ភារកិច្ចជូនថ្នាក់ដឹកនាំនៃអង្គភាពពាក់ព័ន្ធនឹងក្រសួង ស្ថាប័ននិងសាមីខ្លួន ដែលត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឃ- រូបមន្តបញ្ចប់ នៅខាងក្រោមប៉ែកខាងស្តាំ ត្រូវចុះទីកន្លែងនិងកាលបរិច្ឆេទនៃសេចក្តីសម្រេច។ នៅក្រោមទីកន្លែងនិងកាលបរិច្ឆេទ ត្រូវដាក់ **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**...ឬ**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**... ឬ**រដ្ឋមន្ត្រីក្រសួង**...(ឬ**ប្រធានស្ថាប័ន**) ហើយនៅខាងក្រោម ត្រូវទុកចន្លោះសម្រាប់ហត្ថលេខា និងឈ្មោះរបស់រដ្ឋមន្ត្រីឬប្រធានស្ថាប័ន ឬប្រធានស្ថាប័នស្តីទី។

នៅប៉ែកខាងឆ្វេងទំព័រ ត្រូវដាក់ **កន្លែងទទួល** ដែលរួមមាន ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ដូចប្រការ...(មន្ត្រីនៃអង្គភាពពាក់ព័ន្ធនឹងក្រសួង ស្ថាប័នដែលត្រូវអនុវត្ត) រាជកិច្ច និងឯកសារ កាលប្បវត្តិ។

**សូមមើលគំរូទី៧១** : ទម្រង់នៃសេចក្តីសម្រេចរបស់ក្រសួង ស្ថាប័ន នៅទំព័រទី១៨០ដល់ទំព័រទី១៨១។

**គំរូទី៧១**

ទម្រង់នៃសេចក្តីសម្រេចរបស់ក្រសួង ស្ថាប័ន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

(សញ្ញាក្រសួង ស្ថាប័ន)

**ក្រសួង ស្ថាប័ន** : ... (ឈ្មោះក្រសួង ស្ថាប័ន)

**លេខ** : ...

**សេចក្តីសម្រេច**

**ស្តីពី**

(ចំណងជើងជាពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light)

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...**
**ឬ រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័ន)**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី...ខែ...ឆ្នាំ... ស្តីពីការកែសម្រួល និង/ឬបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬការតែងតាំងសមាជិករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា(ដែលទាក់ទងនឹងរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីដែលរៀបចំសេចក្តីព្រាង)
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត...(ឈ្មោះស្ថាប័នសាមី)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់...(ឈ្មោះស្ថាប័នសាមី)
- បានឃើញសារាចររបស់រាជរដ្ឋាភិបាលលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញប្រកាសលេខ... ប្រក. ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់ក្រសួង ស្ថាប័ន ឬ
- យោងតាមសំណើរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានឬប្រធាននាយកដ្ឋាន...(ឈ្មោះអគ្គនាយកដ្ឋាន នាយកដ្ឋានសាមី)

**សម្រេច**

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការ... ដែលមានសមាសភាពដូចខាងក្រោម៖

១- លោក/លោកស្រី ...(ឈ្មោះ) ...(មុខតំណែង) ប្រធាន
២- លោក/លោកស្រី ...(ឈ្មោះ) ...(មុខតំណែង) អនុប្រធាន
៣- ...។

**ប្រការ២ .-**

គណៈកម្មការនេះមានភារកិច្ចដូចតទៅ៖

- ...
- ...។

**ប្រការ៣ .-**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋាន...(ដែលទទួលបន្ទុកការងាររដ្ឋបាលនិង/ឬហិរញ្ញវត្ថុនិង/ឬបុគ្គលិក) អគ្គនាយកនៃអគ្គនាយកដ្ឋាន...(ឈ្មោះអគ្គនាយកដ្ឋានជំនាញពាក់ព័ន្ធ) អគ្គាធិការ(ឬប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ អធិការ...)... និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.................. ខែ............ ឆ្នាំ......... ......ស័ក ព.ស. .......
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី............ ខែ.......... ឆ្នាំ..............

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ
**រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័ន)**
(ហត្ថលេខានិងត្រា)
(**គោរមងារនិង/ឬឈ្មោះ**)

**កន្លែងទទួល៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ...
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

### ៣.២.៨.៥- ទម្រង់នៃសារាចររបស់ក្រសួង ស្ថាប័ន

សារាចររបស់ក្រសួង ស្ថាប័ន ជាលិខិតបទដ្ឋានគតិយុត្តចេញដោយរដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័ន សម្រាប់ណែនាំឱ្យថ្នាក់ក្រោមអនុវត្ត។ ទម្រង់នៃសារាចររបស់ក្រសួង ស្ថាប័នចែកចេញជា៣ផ្នែក មានក្បាលលិខិត ខ្លឹមសារនៃអត្ថបទ និងរូបមន្តបញ្ចប់។

ក- ក្បាលលិខិត ត្រូវប្រើក្រដាសក្បាលលិខិតរបស់ក្រសួង ស្ថាប័នដែលរៀបចំ ដោយនៅផ្នែកខាងលើចំកណ្តាលទំព័រ ដាក់ **ព្រះរាជាណាចក្រកម្ពុជា** ក្រោមព្រះរាជាណាចក្រកម្ពុជា ដាក់បាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ**។ ប៉ែកខាងឆ្វេងក្រោមបាវចនា ដាក់សញ្ញាក្រសួង ស្ថាប័ន ក្រោមសញ្ញា ដាក់ឈ្មោះក្រសួង ស្ថាប័នក្រោមឈ្មោះដាក់ពាក្យ **លេខ** : ... សម្រាប់ទុកចុះលេខរបស់សារាចរដែលមានរូបមន្តអក្សរកាត់ **លេខ** : ... សរ។ នៅក្រោមបាវចនា រំលង៣បន្ទាត់ ចំកណ្តាលទំព័រ ត្រូវដាក់ពាក្យ **សារាចរ** ក្រោមពាក្យសារាចរ ដាក់ពាក្យ **ស្តីពី** ក្រោមពាក្យស្តីពីដាក់ចំណងជើងនៃសារាចរ។

ខ- ខ្លឹមសារនៃអត្ថបទ

ខ.១- **សេចក្តីផ្តើម** ត្រូវយោងទៅរកលិខិតបទដ្ឋានគតិយុត្តដែលត្រូវវិភាគនិងពន្យល់ ដើម្បីបកស្រាយបញ្ជាក់ខ្លឹមសារឱ្យបានច្បាស់ឬត្រូវបង្ហាញអំពីបញ្ហាដែលបានជួបប្រទះក្នុងការអនុវត្ត ដើម្បីឱ្យការអនុវត្តបន្តទទួលបានលទ្ធផលជាវិជ្ជមាន។

ខ.២- **តួសេចក្តី** ត្រូវចែងអំពីការកំណត់ខ្លឹមសារឬការបកស្រាយបញ្ហា ព្រមទាំងបណ្តាវិធានការណែនាំដែលត្រូវអនុវត្តឱ្យបានច្បាស់លាស់តាមផ្លូវច្បាប់។

ខ.៣- **អវសានបទ** ត្រូវចែងថាទទួលបានសារាចរនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង(ឬស្ថាប័ន) ត្រូវ(ផ្សព្វផ្សាយ)អនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តមកក្រសួង(ឬស្ថាប័ន)វិញ។

គ- **រូបមន្តបញ្ចប់** នៅខាងក្រោមប៉ែកខាងស្តាំ ត្រូវចុះទីកន្លែងនិងកាលបរិច្ឆេទនៃសារាចរ។ នៅក្រោមទីកន្លែងនិងកាលបរិច្ឆេទ ត្រូវដាក់ **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬរដ្ឋមន្ត្រីក្រសួង...**(ឬ**ប្រធានស្ថាប័ន**) ហើយនៅខាងក្រោម ត្រូវទុកចន្លោះសម្រាប់ហត្ថលេខានិងឈ្មោះរបស់រដ្ឋមន្ត្រីឬប្រធានស្ថាប័ន ឬប្រធានស្ថាប័នស្តីទី។

នៅប៉ែកខាងឆ្វេងទំព័រ ត្រូវដាក់ **កន្លែងទទួល** នៅក្រោមកន្លែងទទួល ត្រូវដាក់ឈ្មោះស្ថាប័ន អង្គភាពសំខាន់ៗដែលត្រូវជូនជ្រាបឬអនុវត្ត មានជាអាទិ៍ ទីស្តីការគណៈរដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ខុទ្ទកាល័យ(គោរមងារ) នាយករដ្ឋមន្ត្រី ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី អគ្គនាយកដ្ឋាន នាយកដ្ឋាន រដ្ឋបាលរាជធានី ខេត្ត មន្ទីរជំនាញរាជធានី ខេត្ត រាជកិច្ច និងឯកសារ កាលប្បវត្តិ។

**សូមមើលគំរូទី៧២** : ទម្រង់នៃសារាចររបស់ក្រសួង ស្ថាប័ន នៅទំព័រទី១៨៣។

**គំរូទី៧២**

ទម្រង់នៃសារាចររបស់ក្រសួង ស្ថាប័ន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

(សញ្ញាក្រសួង ស្ថាប័ន)

**ក្រសួង ស្ថាប័ន** : ... (ឈ្មោះក្រសួង ស្ថាប័ន)

**លេខ** : ...

**សារាចរ**

**ស្តីពី**

(ចំណងជើងជាពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light)

(សេចក្តីផ្តើម)

កន្លងមក ក្រសួង(ឬស្ថាប័ន)បានសង្កេតឃើញថា ក្នុងការអនុវត្តអនុក្រឹត្យលេខ... ចុះថ្ងៃទី... ខែ ... ឆ្នាំ... ស្តីពី...ឬ សារាចររបស់រាជរដ្ឋាភិបាលលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...ឬប្រកាសលេខ...ចុះថ្ងៃទី ... ខែ... ឆ្នាំ... ស្តីពី... បានប្រទះការលំបាកជាច្រើន ...។

(តួសេចក្តី)

(គោលបំណង)ដើម្បីចៀសវាងការលំបាកទាំងនេះ ក្រសួង(ឬស្ថាប័ន) សូមដាក់ចេញនូវវិធានការណែនាំ ដូចខាងក្រោម៖

(ខ្លឹមសារណែនាំ) ១. - ... (រៀបរាប់ចំណុចដែលត្រូវណែនាំ)។

២. - ...។

(អវសានបទ)

ទទួលបានសារាចរនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង(ឬស្ថាប័ន) ត្រូវ(ផ្សព្វផ្សាយ)អនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តមកក្រសួង(ឬស្ថាប័ន)វិញ។

ថ្ងៃ................. ខែ............ ឆ្នាំ......... ......ស័ក ព.ស. .......

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី............ ខែ.......... ឆ្នាំ...............

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ

**រដ្ឋមន្ត្រីក្រសួង...**(ឬ**ប្រធានស្ថាប័ន**)

(ហត្ថលេខានិងត្រា)

(**គោរមងារនិង/ឬឈ្មោះ**)

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋាន/នាយកដ្ឋាន
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរជំនាញរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**៣.២.៨.៦- ទម្រង់នៃសារាចរអន្តរក្រសួង**

សារាចរអន្តរក្រសួង ជាលិខិតបទដ្ឋានគតិយុត្តចេញដោយក្រសួង ស្ថាប័ន២ឬ៣ ដើម្បីណែនាំឱ្យថ្នាក់ក្រោមសហការអនុវត្ត។ ក្នុងករណីមានការពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នលើសពី៣ ត្រូវរៀបចំជាសារាចររបស់រាជរដ្ឋាភិបាល។

ទម្រង់នៃសារាចរអន្តរក្រសួងចែកចេញជា៣ផ្នែក មានក្បាលលិខិត ខ្លឹមសារនៃអត្ថបទ និងរូបមន្តបញ្ចប់។

ក- **ក្បាលលិខិត** ត្រូវប្រើក្រដាសក្បាលលិខិតរបស់ក្រសួង ស្ថាប័នដើម ដោយនៅផ្នែកខាងលើចំកណ្តាលទំព័រ ដាក់ **ព្រះរាជាណាចក្រកម្ពុជា** ក្រោមព្រះរាជាណាចក្រកម្ពុជា ដាក់បាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ**។ ប៉ែកខាងឆ្វេងក្រោមបាវចនា ដាក់សញ្ញាក្រសួង ស្ថាប័នដើម ក្រោមសញ្ញា ដាក់ឈ្មោះក្រសួង ស្ថាប័នដើមនៅប៉ែកខាងឆ្វេង និងដាក់ឈ្មោះក្រសួង ស្ថាប័នដែលចូលរួមនៅប៉ែកខាងស្តាំ(ក្នុងករណីមាន២ក្រសួង/ស្ថាប័ន) ឬនៅចំកណ្តាលនិងនៅប៉ែកខាងស្តាំ ដោយផ្អែកទៅតាមទំហំសមត្ថកិច្ចពាក់ព័ន្ធ(ក្នុងករណីមាន៣ក្រសួង/ស្ថាប័ន)។ នៅក្រោមឈ្មោះក្រសួង/ស្ថាប័នដើម ដាក់ពាក្យ **លេខ** :... សម្រាប់ទុកចុះលេខរបស់សារាចរអន្តរក្រសួង ដែលមានរូបមន្តអក្សរកាត់ **លេខ** :... សរ (អក្សរកាត់របស់ក្រសួង ស្ថាប័នដើម)។ លេខសារាចរអន្តរក្រសួង ត្រូវយកលេខរបស់ក្រសួង/ស្ថាប័នដើម។ ក្រសួង/ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធច្រើនជាងគេ ជាក្រសួង/ស្ថាប័នដើម ដែលត្រូវទទួលបន្ទុករៀបចំសារាចរអន្តរក្រសួងនេះ។

នៅក្រោមបាវចនា រំលង៣បន្ទាត់ ចំកណ្តាលទំព័រ ត្រូវដាក់ពាក្យ **សារាចរអន្តរក្រសួង** ក្រោមពាក្យសារាចរអន្តរក្រសួង ដាក់ពាក្យ **ស្តីពី** ក្រោមពាក្យស្តីពី ដាក់ចំណងជើងនៃសារាចរអន្តរក្រសួង។

ខ- ខ្លឹមសារនៃអត្ថបទ

ខ.១- សេចក្តីផ្តើម ត្រូវយោងទៅរកលិខិតបទដ្ឋានគតិយុត្តដែលត្រូវវិភាគនិងពន្យល់ដើម្បីបកស្រាយបញ្ជាក់ខ្លឹមសារឱ្យបានច្បាស់ឬត្រូវបង្ហាញអំពីបញ្ហាដែលបានជួបប្រទះក្នុងការអនុវត្ត ដើម្បីឱ្យការអនុវត្តបន្តទទួលបានលទ្ធផលជាវិជ្ជមាន។

ខ.២- តួសេចក្តី ត្រូវចែងអំពីការកំណត់ខ្លឹមសារឬការបកស្រាយបញ្ហា ព្រមទាំងវិធានការណែនាំដែលត្រូវសហការអនុវត្តឱ្យបានច្បាស់លាស់តាមផ្លូវច្បាប់។

ខ.៣- អវសានបទ ត្រូវចែងថា ទទួលបានសារាចរអន្តរក្រសួងនេះ គ្រប់អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួង...(ឬស្ថាប័ន...) និងក្រសួង...(ឬស្ថាប័ន...)(ឈ្មោះក្រសួង/ស្ថាប័នដែលចេញសារាចរអន្តរក្រសួងនេះ)ត្រូវសហការ(ផ្សព្វផ្សាយ) អនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តមកក្រសួង(ឬស្ថាប័ន)រៀងៗខ្លួនវិញ។

គ- **រូបមន្តបញ្ចប់** នៅខាងក្រោមប៉ែកខាងស្តាំ ត្រូវចុះទីកន្លែងនិងកាលបរិច្ឆេទនៃសារាចរអន្តរក្រសួង។ នៅក្រោមទីកន្លែងនិងកាលបរិច្ឆេទ ស្របតាមទីតាំងនៅក្បាលលិខិត ត្រូវដាក់ **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង...** ឬ **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬរដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័ន)** ហើយនៅខាងក្រោម ត្រូវទុកចន្លោះសម្រាប់ហត្ថលេខានិងឈ្មោះរបស់រដ្ឋមន្ត្រីឬប្រធានស្ថាប័ន ឬប្រធានស្ថាប័នស្តីទីទាំងនោះ។

នៅប៉ែកខាងឆ្វេងទំព័រ ត្រូវដាក់ **កន្លែងទទួល** នៅក្រោមកន្លែងទទួល ត្រូវដាក់ឈ្មោះក្រសួង/ស្ថាប័ន អង្គភាពសំខាន់ៗដែលត្រូវជូនជ្រាបឬអនុវត្ត មានជាអាទិ៍ ទីស្តីការគណៈរដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី អគ្គនាយកដ្ឋាន នាយកដ្ឋាន រដ្ឋបាលរាជធានី ខេត្ត មន្ទីរជំនាញរាជធានី ខេត្ត រាជកិច្ច និងឯកសារ កាលប្បវត្តិ។

**សូមមើលគំរូទី៧៣** : ទម្រង់នៃសារាចរអន្តរក្រសួង នៅទំព័រទី១៨៥។

**គំរូទី៧៣**

ទម្រង់នៃសារាចរអន្តរក្រសួង

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

(សញ្ញាក្រសួង/ស្ថាប័នដើម)

**ក្រសួង/ស្ថាប័ន** : ...(ឈ្មោះក្រសួង/ស្ថាប័នដើម) **ក្រសួង/ស្ថាប័ន**... **ក្រសួង/ស្ថាប័ន**...

**លេខ** : ... (អក្សរកាត់របស់ក្រសួង/ស្ថាប័នដើម)

## សារាចរអន្តរក្រសួង
## ស្តីពី

(ចំណងជើងជាពុម្ពអក្សរខ្មែរយូនីកូដ Khmer OS Muol Light)

(សេចក្តីផ្តើម)

.................................................................................................................។

(តួសេចក្តី)

(គោលបំណង).........................................................................................។

(ខ្លឹមសារណែនាំ)....................................................................................។

(អវសានបទ)

ទទួលបានសារាចរអន្តរក្រសួងនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង...(ឬស្ថាប័ន...) និងក្រសួង...(ឬស្ថាប័ន...)(ឈ្មោះក្រសួង/ស្ថាប័នដែលចេញសារាចរអន្តរក្រសួងនេះ) ត្រូវសហការ(ផ្សព្វផ្សាយ)អនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍ពីលទ្ធផលនៃការអនុវត្តមកក្រសួង(ឬស្ថាប័ន)រៀងៗខ្លួនវិញ។

ថ្ងៃ.................. ខែ........ ឆ្នាំ....... .....ស័ក ព.ស. .....

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី......... ខែ......... ឆ្នាំ............

| | | |
|---|---|---|
| **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬ រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័ន)** | **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬ រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័ន)** | **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង... ឬ រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័ន)** |
| (ហត្ថលេខានិងត្រា) | (ហត្ថលេខានិងត្រា) | (ហត្ថលេខានិងត្រា) |
| **(គោរមងារនិង/ឬឈ្មោះ)** | **(គោរមងារនិង/ឬឈ្មោះ)** | **(គោរមងារនិង/ឬឈ្មោះ)** |

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋាន/នាយកដ្ឋាន
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរជំនាញរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ៤- ការបញ្ជូនសំណុំឯកសារទៅទីស្ដីការគណៈរដ្ឋមន្ត្រី

ក្រសួង ស្ថាប័នសាមីត្រូវរៀបចំសេចក្ដីព្រាងអត្ថបទដោយភ្ជាប់ជាមួយនូវកម្មវិធីនៃការកសាងសេចក្ដីព្រាងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ហើយបញ្ជូនទៅទីស្ដីការគណៈរដ្ឋមន្ត្រី។

### ៤.១- សេចក្ដីស្នើច្បាប់ដែលស្នើសុំឱ្យរាជរដ្ឋាភិបាលផ្ដល់អនុសាសន៍

សេចក្ដីស្នើច្បាប់ដែលគណៈកម្មការរបស់ព្រឹទ្ធសភាឬរដ្ឋសភាស្នើឱ្យរាជរដ្ឋាភិបាលផ្ដល់យោបល់ ត្រូវបញ្ជូនមកទីស្ដីការគណៈរដ្ឋមន្ត្រី។ បន្ទាប់ពីបានទទួលសំណើនោះ ទីស្ដីការគណៈរដ្ឋមន្ត្រីត្រូវបញ្ជូនសេចក្ដីស្នើច្បាប់ទៅឱ្យក្រសួង ស្ថាប័នជំនាញមានសមត្ថកិច្ចពិនិត្យនិងផ្ដល់យោបល់។

ក្រសួង ស្ថាប័នជំនាញត្រូវចាត់ចែងពិនិត្យនិងពិភាក្សាក្នុងក្របខ័ណ្ឌសមត្ថកិច្ចនិងបច្ចេកទេសរបស់ខ្លួន រួចលើកយោបល់កែសម្រួលបញ្ជូនទៅទីស្ដីការគណៈរដ្ឋមន្ត្រីវិញ ដោយភ្ជាប់ជាមួយនូវៈ

- លិខិតបញ្ជូនរបស់ក្រសួង ស្ថាប័នដែលចុះហត្ថលេខាដោយរដ្ឋមន្ត្រីឬប្រធានស្ថាប័ន
- របាយការណ៍ពន្យល់បកស្រាយអំពីចំណុចដែលក្រសួង ស្ថាប័នជូនយោបល់កែសម្រួលតាមចំណុចមាត្រានីមួយៗ ដោយធ្វើជាតារាងប្រៀបធៀបរវាងបទប្បញ្ញត្តិដើមដែលចែងក្នុងសេចក្ដីស្នើច្បាប់និងបទប្បញ្ញត្តិដែលស្នើចែងថ្មី តាមទម្រង់ដូចបានកំណត់ក្នុងកថាខណ្ឌនៃចំណុច ៣.២.៣ ស្ដីពីទម្រង់នៃអនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្ដីស្នើច្បាប់។

### ៤.២- សេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ

សេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗត្រូវរៀបចំនិងចែងជាលម្អិតឱ្យបានច្បាស់លាស់តាមការកំណត់នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

### ៤.៣- សេចក្ដីស្នើច្បាប់ឬសេចក្ដីព្រាងច្បាប់ដែលទាក់ទងនឹងវិស័យតុលាការ

អនុលោមតាមច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សេចក្ដីស្នើច្បាប់ឬសេចក្ដីព្រាងច្បាប់ដែលទាក់ទងនឹងការរៀបចំនិងការប្រព្រឹត្តទៅនៃវិស័យតុលាការ ត្រូវដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីផ្ដល់យោបល់ជាចាំបាច់។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវផ្ដល់យោបល់យ៉ាងយូរក្នុងរយៈពេល៣០ថ្ងៃ គិតពីថ្ងៃដែលបានទទួលសេចក្ដីស្នើច្បាប់ឬសេចក្ដីព្រាងច្បាប់ពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ក្នុងករណីប្រញាប់ រយៈពេលនេះអាចបន្ថយមកនៅត្រឹម១០ថ្ងៃ។

## ៥- ការពិនិត្យសំណុំឯកសារនៅទីស្ដីការគណៈរដ្ឋមន្ត្រី

ចំពោះសំណុំឯកសារនៃសេចក្ដីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលក្រសួង ស្ថាប័នសាមីស្នើសុំឱ្យទីស្ដីការគណៈរដ្ឋមន្ត្រីពិនិត្យនិងផ្ដល់យោបល់ ហើយមានការខ្វះខាតឯកសារ ពុំមានលក្ខណៈគ្រប់គ្រាន់ដូចមានចែងក្នុងចំណុច១.២ ទំព័រ១និងទំព័រ២ ទីស្ដីការគណៈរដ្ឋមន្ត្រីត្រូវជម្រាបជូនក្រសួង ស្ថាប័នសាមីឱ្យបំពេញចំណុចទាំងនោះឡើងវិញ។

សេចក្ដីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលទីស្ដីការគណៈរដ្ឋមន្ត្រីបានយល់ព្រមទទួលអាចដាក់ឆ្លងអង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យចុងក្រោយឬនីតិវិធីផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីឬតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី។

### ៥.១- ការពិនិត្យដោយអង្គប្រជុំជំនាញបច្ចេកទេស

អង្គប្រជុំជំនាញបច្ចេកទេសដឹកនាំដោយតំណាងក្រុមប្រឹក្សាអ្នកច្បាប់និងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ជាសហប្រធាន និងចូលរួមដោយតំណាងក្រសួង ស្ថាប័នសាមីនិងតំណាងផ្នែកជំនាញពាក់ព័ន្ធ ដើម្បីពិភាក្សាផ្លាស់ប្ដូរយោបល់លើទិដ្ឋភាពគោលនយោបាយ ទិដ្ឋភាពច្បាប់ ទិដ្ឋភាពសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងផ្លូវទស្សនៈ ហេតុការណ៍ ព័ត៌មាន និងពិភាក្សាផលប៉ះពាល់ ព្រមទាំងពិនិត្យកែលម្អ ទម្រង់ ខ្លឹមសារ បច្ចេកសព្ទ និងអក្ខរាវិរុទ្ធ (ពិនិត្យនិងកែដោយគណៈកម្មការភាសាវិទ្យាខ្មែរនៃទីស្ដីការគណៈរដ្ឋមន្ត្រី)។

សេចក្តីព្រាងអត្ថបទដែលបានឆ្លងអង្គប្រជុំជំនាញបច្ចេកទេសរួចហើយ ទីស្តីការគណៈរដ្ឋមន្ត្រីអាចរៀបចំដាក់ឆ្លងអង្គប្រជុំអន្តរក្រសួង។

**៥.២- ការពិនិត្យដោយអង្គប្រជុំអន្តរក្រសួង**

អង្គប្រជុំអន្តរក្រសួងដឹកនាំដោយរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីឬតំណាងជារដ្ឋលេខាធិការ ជាប្រធានអង្គប្រជុំ និងចូលរួមដោយតំណាងក្រសួង ស្ថាប័ន និងតំណាងផ្នែកជំនាញពាក់ព័ន្ធ ដើម្បីពិភាក្សាសម្របសម្រួលមតិយោបល់លើចំណុចដែលពុំទាន់ឯកភាពគ្នា មានជាអាទិ៍ ករណីត្រួតការកិច្ចឬករណីខ្វះចន្លោះការកិច្ចក្នុងការទទួលខុសត្រូវតាមវិស័យនិងអន្តរវិស័យ និងបំពេញបន្ថែមខ្លឹមសារធ្វើឱ្យសេចក្តីព្រាងអត្ថបទមានសង្គតិភាពនិងលក្ខណៈពេញលេញ។ បន្ទាប់មក ក្រសួងយុត្តិធម៌មានការកិច្ចពិនិត្យបន្ថែមលើជំពូកនិងមាត្រា ដែលចែងអំពីទោសប្បញ្ញត្តិ(សេចក្តីព្រាងច្បាប់) ជាមួយក្រសួង ស្ថាប័នសាមី រួចបញ្ជូនមកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីដាក់ប្រជុំត្រួតពិនិត្យជាចុងក្រោយ។ ការពិនិត្យទោសប្បញ្ញត្តិនៅក្រសួងយុត្តិធម៌ ចំពោះសេចក្តីព្រាងច្បាប់ធម្មតាត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ៤៥(សែសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ និងចំពោះសេចក្តីព្រាងច្បាប់មានការប្រញាប់ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ២១(ម្ភៃមួយ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសំណើបញ្ជូនពីទីស្តីការគណៈរដ្ឋមន្ត្រី។

**៥.៣- ការពិនិត្យដោយអង្គប្រជុំត្រួតពិនិត្យចុងក្រោយ**

សេចក្តីព្រាងអត្ថបទដែលបានឆ្លងអង្គប្រជុំអន្តរក្រសួងរួចហើយ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីអាចរៀបចំដាក់ឆ្លងអង្គប្រជុំត្រួតពិនិត្យចុងក្រោយ ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីឬសុំការសម្រេចពីនាយករដ្ឋមន្ត្រី។

**៥.៤- ការពិនិត្យដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី**

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់នាយករដ្ឋមន្ត្រីឬនាយករដ្ឋមន្ត្រីស្តីទី ដើម្បីពិភាក្សានិងសម្រេចរាល់សេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលស្នើឡើងដោយក្រសួង ស្ថាប័ន។

ក្រោយពីទទួលបានការឯកភាពពីអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីហើយ ក្រសួង ស្ថាប័នសាមីត្រូវសហការជាមួយក្រុមប្រឹក្សាអ្នកច្បាប់ ដើម្បីកែសម្រួលសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដោយយោងតាមសេចក្តីជូនដំណឹងស្តីពីលទ្ធផលនៃអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។ សេចក្តីព្រាងកែសម្រួលនេះត្រូវបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីចាត់ចែងបន្តតាមនីតិវិធីទៅតាមប្រភេទនៃសេចក្តីព្រាងនីមួយៗ។

**៥.៥- ការពិនិត្យនិងការផ្តល់អនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្តីស្នើច្បាប់**

បន្ទាប់ពីទទួលបានយោបល់ពីក្រសួង ស្ថាប័នជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រីត្រូវៈ

- ដាក់សេចក្តីស្នើច្បាប់ឆ្លងអង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យចុងក្រោយឬនីតិវិធីផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីឬតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី
- ដាក់ជូននាយករដ្ឋមន្ត្រីៈ
    - ឆ្លើយតបជាផ្លូវការដោយផ្តល់អនុសាសន៍ទៅរដ្ឋសភាឬព្រឹទ្ធសភា ប្រសិនបើមាន
    - សម្រេចលើការបញ្ជូនតំណាងទៅចូលរួមបំភ្លឺគណៈកម្មការរបស់រដ្ឋសភាឬព្រឹទ្ធសភាដែលរៀបចំសេចក្តីស្នើច្បាប់នោះ ឬបំភ្លឺអង្គសភាទាំងមូលជាមួយគណៈកម្មការរបស់រដ្ឋសភាឬព្រឹទ្ធសភា ក្នុងករណីចាំបាច់លើលក្ខណៈបច្ចេកទេស ប្រសិនបើមានការអញ្ជើញជាផ្លូវការពីរដ្ឋសភាឬព្រឹទ្ធសភា។

## ៦- ការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតក្រោយការប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងការចុះហត្ថលេខាអម

ការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតក្រោយការប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដើម្បីផ្ញើជូនប្រធានរដ្ឋសភា ឬថ្វាយព្រះមហាក្សត្រ ឬជូននាយករដ្ឋមន្ត្រី ត្រូវអនុវត្តតាមបែបបទដោយឡែក តាមប្រភេទនីមួយៗ។

**៦.១- សេចក្តីព្រាងច្បាប់**

ក្រសួង ស្ថាប័នសាមីត្រូវធ្វើទំនាក់ទំនងយកសុសកូពីនៃសេចក្តីព្រាងច្បាប់ពីទីស្តីការគណៈរដ្ឋមន្ត្រី រួចសហការជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់ ដើម្បីកែសម្រួលតាមស្មារតីនៃអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។ បន្ទាប់មក អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់ត្រូវរៀបចំលិខិតស្នើរបស់នាយករដ្ឋមន្ត្រីផ្ញើទៅប្រធានរដ្ឋសភាសុំពិនិត្យនិងអនុម័តសេចក្តីព្រាងច្បាប់ ដោយភ្ជាប់ជាមួយនូវសេចក្តីព្រាងច្បាប់និងសេចក្តីថ្លែងហេតុរបស់រាជរដ្ឋាភិបាល រួចចាត់បញ្ជូន

ទៅរដ្ឋសភា។ ដោយឡែក ចំពោះសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកា អគ្គលេខាធិការក្រុមប្រឹក្សាអ្នកច្បាប់ត្រូវផ្ញើទៅអគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិនូវរបាយការណ៍ស្តីពីលទ្ធផលនៃការប្រជុំពិនិត្យរបស់គណៈរដ្ឋមន្ត្រី ដោយភ្ជាប់ជាមួយនូវសេចក្តីព្រាងច្បាប់ដែលបានផ្ញើជូនទៅរដ្ឋសភា១ច្បាប់ផងដែរ។

**៦.២- ព្រះរាជក្រឹត្យ**

**៦.២.១- ព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ**

ក- ព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ ដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

សេចក្តីយោងក្នុងមូលបទខាងក្រោមបង្អស់ ត្រូវដាក់ថា «បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ និងឈ្មោះ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី... (លេខ) ខែ... (អក្សរ) ឆ្នាំ... (លេខ)»។

នៅទំព័របញ្ចប់ត្រូវរៀបចំដាក់ជូននាយករដ្ឋមន្ត្រីចុះហត្ថលេខាអមតែប៉ុណ្ណោះ ដោយដាក់ថា «បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា» រួចបញ្ជូនថ្វាយព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខាដោយមានភ្ជាប់ជាមួយនូវលិខិតស្នើនិងកំណត់មូលហេតុសង្ខេបឬលិខិតស្នើដែលចែងពីមូលហេតុសង្ខេប។

ខ- ព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ ដែលមិនបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី តែមានសំណើពីក្រសួង ស្ថាប័នសាមី

សេចក្តីយោងក្នុងមូលបទខាងក្រោមបង្អស់ ត្រូវដាក់ថា «បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ និងឈ្មោះ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា»។ ក្នុងករណីនេះ ត្រូវមានហត្ថលេខាអមរបស់នាយករដ្ឋមន្ត្រី ដោយដាក់ថា «បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា» និងមានហត្ថលេខាអមរបស់រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី ដើម្បីគោរពជូននាយករដ្ឋមន្ត្រី ដោយដាក់ថា «បានយកសេចក្តីគោរពជម្រាបជូន(គោរមងារ និងឈ្មោះ)នាយករដ្ឋមន្ត្រី»។ នៅពីក្រោមឃ្លានេះ ត្រូវដាក់មុខតំណែងរបស់រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី ហើយមានហត្ថលេខានិងឈ្មោះ ដោយគ្មានត្រានិងកាលបរិច្ឆេទទេ។

**៦.២.២- ព្រះរាជក្រឹត្យមានលក្ខណៈជាឯកត្តតូត ដែលនាយករដ្ឋមន្ត្រីប្រើឆន្ទានុសិទ្ធិស្នើឡើង**

សេចក្តីយោងក្នុងមូលបទខាងក្រោមបង្អស់ ត្រូវដាក់ថា «បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ និងឈ្មោះ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា» តែគ្មានហត្ថលេខាអមរបស់នាយករដ្ឋមន្ត្រីទេ។

**៦.២.៣- ព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោសនិង/ឬការលើកលែងទោស**

ការរៀបចំត្រូវអនុវត្តតាមច្បាប់និងនីតិវិធីជាធរមាន។

**៦.២.៤- ព្រះរាជក្រឹត្យស្តីពីការតែងតាំង/ផ្លាស់ប្តូរ/... ទៅក្រមនិងព្រះរាជអាជ្ញា**

ការរៀបចំត្រូវអនុវត្តតាមច្បាប់និងនីតិវិធីជាធរមាន។

**៦.២.៥- ព្រះរាជក្រឹត្យស្តីពីការផ្តល់គ្រឿងឥស្សរិយយស**

ការរៀបចំត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងបែបបទស្នើសុំគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា។

**៦.៣- អនុក្រឹត្យ**

**៦.៣.១- អនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ**

ក- អនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ ដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីឬសម្រេចតាមឆន្ទានុសិទ្ធិរបស់នាយករដ្ឋមន្ត្រី

អនុក្រឹត្យដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី សេចក្តីយោងក្នុងមូលបទខាងក្រោមបង្អស់ ត្រូវដាក់ថា «បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី...(លេខ) ខែ...(អក្សរ) ឆ្នាំ...(លេខ)»។ ក្នុងករណីសម្រេចតាមឆន្ទានុសិទ្ធិរបស់នាយករដ្ឋមន្ត្រី ត្រូវដាក់ថា «យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល»។ អនុក្រឹត្យទាំងពីរបែបនេះ ត្រូវដាក់ជូននាយករដ្ឋមន្ត្រីចុះហត្ថលេខា ដោយគ្មានហត្ថលេខាអមរបស់រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីទេ។

ខ- អនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ ដែលមិនបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី តែមានសំណើពីក្រសួង ស្ថាប័នសាមី

សេចក្តីយោងក្នុងមូលបទខាងក្រោមបង្អស់ ត្រូវដាក់ថា «យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័នសាមី)»។ ក្នុងករណីនេះ ត្រូវមានហត្ថលេខាអមរបស់រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីគោរពជូននាយករដ្ឋមន្ត្រី ដោយដាក់ថា «បានយកសេចក្តីគោរពជម្រាបជូន(គោរមងារ)នាយករដ្ឋមន្ត្រីសូមហត្ថលេខា»។ នៅពីក្រោមឃ្លានេះត្រូវដាក់មុខតំណែងរបស់រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី ហើយមានហត្ថលេខានិងឈ្មោះ ដោយគ្មានត្រានិងកាលបរិច្ឆេទទេ។

**៦.៣.២- អនុក្រឹត្យមានលក្ខណៈជាឯកត្តតូត**

ក្នុងករណីមានសំណើពីក្រសួង ស្ថាប័ន សេចក្តីយោងក្នុងមូលបទខាងក្រោមបង្អស់ ត្រូវដាក់ថា «យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័នសាមី)»។ ក្នុងករណីសម្រេចតាមឆន្ទានុសិទ្ធិរបស់នាយករដ្ឋមន្ត្រី ត្រូវដាក់ថា «យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល»។ អនុក្រឹត្យទាំងពីរបែបនេះមានតែហត្ថលេខារបស់នាយករដ្ឋមន្ត្រីប៉ុណ្ណោះ។

## ៧- ការបញ្ជូនសំណុំឯកសារទៅរដ្ឋសភា

សេចក្តីព្រាងច្បាប់ បន្ទាប់ពីបានការយល់ព្រមពីគណៈរដ្ឋមន្ត្រីរួចហើយ អគ្គលេខាធិការក្រុមប្រឹក្សាអ្នកច្បាប់ត្រូវបញ្ជូនទៅរដ្ឋសភាដោយភ្ជាប់ជាមួយនូវឯកសារដូចតទៅ៖

- លិខិតស្នើរបស់នាយករដ្ឋមន្ត្រី ជូនប្រធានរដ្ឋសភា
- សេចក្តីថ្លែងហេតុដែលបង្ហាញពីគោលបំណងនិងអត្ថប្រយោជន៍នៃការរៀបចំសេចក្តីព្រាង
- សេចក្តីព្រាងអត្ថបទដែលបានកែសម្រួលតាមការសម្រេចរបស់អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

ដោយឡែក ចំពោះសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលដាក់ជូនរដ្ឋសភាអនុម័តត្រូវភ្ជាប់ជាមួយនឹងលិខិតស្នើរបស់នាយករដ្ឋមន្ត្រីនូវឯកសារដូចមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

## ៨- ការប្រគល់ភារកិច្ចឱ្យទៅការពារសេចក្តីព្រាងច្បាប់នៅរដ្ឋសភានិងព្រឹទ្ធសភា

រាជរដ្ឋាភិបាលប្រគល់ភារកិច្ចឱ្យរដ្ឋមន្ត្រីជាប្រធានស្ថាប័នសាមី ទៅការពារសេចក្តីព្រាងច្បាប់នៅរដ្ឋសភានិងព្រឹទ្ធសភា។ ក្នុងករណីដែលរដ្ឋមន្ត្រីជាប្រធានស្ថាប័នមានធុរៈមិនអាចចូលរួមប្រជុំបានឬជាប់បំពេញបេសកកម្មនៅក្រៅប្រទេស នាយករដ្ឋមន្ត្រីចាត់តាំងសមាជិករាជរដ្ឋាភិបាលណាម្នាក់ជាតំណាង ដើម្បីទៅការពារជំនួសតាមកាលកំណត់របស់រដ្ឋសភានិងព្រឹទ្ធសភា។

## ៩- នីតិវិធីនិងវិធាននៃការសុំធ្វើវិសោធនកម្មច្បាប់និងសេចក្តីព្រាងច្បាប់

**៩.១- ការធ្វើវិសោធនកម្មច្បាប់ជាធរមាន**

ក្រសួង ស្ថាប័នសាមីអាចសុំធ្វើវិសោធនកម្មច្បាប់ជាធរមានបាន ប្រសិនបើពិនិត្យឃើញថាមានចំណុចដែលមិនអាចអនុវត្តបានក្នុងស្ថានភាពបច្ចុប្បន្នឬប៉ះពាល់ដល់ស្ថិរភាពសង្គម។ ចំពោះនីតិវិធីនៃការតាក់តែងសេចក្តីព្រាងនេះ ត្រូវដំណើរការរៀបចំដូចនីតិវិធីនៃការតាក់តែងសេចក្តីព្រាងច្បាប់ដែរ។

ចំពោះការធ្វើវិសោធនកម្មច្បាប់ជាធរមានដែលមានចំណុចត្រូវធ្វើវិសោធនកម្មចាប់ពីពាក់កណ្តាលឡើងទៅ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ថ្មីជំនួសច្បាប់ចាស់តែម្តង។

**៩.២- ការធ្វើវិសោធនកម្មសេចក្តីព្រាងច្បាប់ដែលគណៈរដ្ឋមន្ត្រីបានឯកភាព ហើយដែលស្ថិតនៅក្នុងរបៀបវារៈរបស់អង្គប្រជុំរដ្ឋសភា**

ក្នុងពេលដែលរដ្ឋសភាកំពុងប្រជុំពិភាក្សា រាជរដ្ឋាភិបាលអាចផ្ញើលិខិតទៅរដ្ឋសភា ដើម្បីសុំកែប្រែយ៉ាងជាក់លាក់លើខ្លឹមសារនៃសេចក្តីព្រាងច្បាប់ឬក៏អាចប្រគល់ភារកិច្ចឱ្យរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី ធ្វើទំនាក់ទំនង កែសម្រួលលើចំណុចដែលត្រូវកែប្រែ។ បទអន្តរាគមន៍នេះអាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមជាមុនពីគណៈរដ្ឋមន្ត្រីឬនាយករដ្ឋមន្ត្រី។

### ៩.៣-ការធ្វើវិសោធនកម្មសេចក្តីព្រាងច្បាប់ដែលគណៈរដ្ឋមន្ត្រីបានឯកភាព ហើយដែលស្ថិតនៅក្នុងគណៈកម្មការនៃរដ្ឋសភា

ការធ្វើវិសោធនកម្មសេចក្តីព្រាងច្បាប់ដែលស្ថិតនៅក្នុងគណៈកម្មការនៃរដ្ឋសភា រដ្ឋមន្ត្រីឬប្រធានស្ថាប័ន ឬតំណាងអាចសម្របសម្រួលធ្វើការកែប្រែលើពាក្យពេចន៍ ល្បះ អក្ខរាវិរុទ្ធខ្លះៗបាន។ ចំពោះសំណើកែប្រែយ៉ាងជ្រាលជ្រៅលើខ្លឹមសារនៃសេចក្តីព្រាងច្បាប់របស់ក្រសួង ស្ថាប័នសាមី ឬរបស់គណៈកម្មការរដ្ឋសភា ត្រូវសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ឬពីនាយករដ្ឋមន្ត្រីឡើងវិញ។

## ១០- ការចូលជាធរមាននៃច្បាប់ក្រោយពីការអនុម័តនិងការយល់ព្រមរបស់ស្ថាប័ននីតិប្បញ្ញត្តិ និងការចុះក្នុងរាជកិច្ច

ក្រោយពីទទួលបានអត្ថបទច្បាប់ដែលបានទទួលការអនុម័តពីរដ្ឋសភានិងទទួលការយល់ព្រមពីព្រឹទ្ធសភាហើយនោះ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់ត្រូវរៀបចំសេចក្តីព្រាងព្រះរាជក្រមជូននាយករដ្ឋមន្ត្រី ដើម្បីថ្វាយព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា។

លិខិតដែលរាជរដ្ឋាភិបាលត្រូវថ្វាយព្រះមហាក្សត្រមានដូចខាងក្រោម៖

- លិខិតរបស់នាយករដ្ឋមន្ត្រី ក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា
- សេចក្តីព្រាងព្រះរាជក្រម ដែលមានហត្ថលេខាអមរបស់រដ្ឋមន្ត្រីឬប្រធានស្ថាប័ន(ជាសមាជិករាជរដ្ឋាភិបាល) សាមីនិងរបស់នាយករដ្ឋមន្ត្រី និងច្បាប់ថ្វាយភ្ជាប់។

ច្បាប់ដែលព្រះមហាក្សត្រប្រកាសឱ្យប្រើតាមព្រះរាជក្រម ត្រូវចូលជាធរមានក្នុងរយៈពេល១០ថ្ងៃ នៅរាជធានីភ្នំពេញ និង២០ថ្ងៃនៅទូទាំងប្រទេស បន្ទាប់ពីថ្ងៃដែលព្រះអង្គបានឡាយព្រះហស្តលេខា ប៉ុន្តែបើចែងថា ជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ។ បន្ទាប់មក រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីត្រូវរៀបចំនិងចុះហត្ថលេខាលើសំណៅបានចម្លងត្រឹមត្រូវតាមច្បាប់ដើមនៃព្រះរាជក្រម ដើម្បីចែកផ្សាយ។

ចំពោះច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលត្រូវចុះផ្សាយក្នុងរាជកិច្ច រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីពិនិត្យនិងសម្រេច ហើយចុះហត្ថលេខាយល់ព្រមឱ្យចុះផ្សាយក្នុងរាជកិច្ច។ អគ្គនាយកដ្ឋានទទួលបន្ទុករាជកិច្ចនៃទីស្តីការគណៈរដ្ឋមន្ត្រីមានភារកិច្ចទទួលចុះក្នុងរាជកិច្ចនិងផ្សព្វផ្សាយឱ្យបានគ្រប់គ្រាន់តាមតម្រូវការរបស់ក្រសួង ស្ថាប័នបញ្ញាទិញ។

ក្រសួង ស្ថាប័នសាមីអាចយកទៅធ្វើការបោះពុម្ពសម្រាប់ប្រើចំពោះច្បាប់ដែលជាសំណៅបានចម្លងត្រឹមត្រូវតាមច្បាប់ដើមនិងបានចុះក្នុងរាជកិច្ចរួចហើយ។

បោះពុម្ពផ្សព្វផ្សាយដោយ

ទីស្តីការគណៈរដ្ឋមន្ត្រី

(ក្រុមប្រឹក្សាអ្នកច្បាប់)